## ជីវប្រវត្តិ

លោក **ទូច-គីមស្រ៊ាន** កើតនៅឆ្នាំ១៩៧៤ ក្នុងគ្រួសារកសិករ នៅក្នុងភូមិកាប៉ូ ឃុំអូរឫស្សី ស្រុកក្រចេះ ខេត្តក្រចេះ

## ការសិក្សា

២០០៩ បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរ នៅសាកលវិទ្យាល័យខេមរៈ

២០០៧ បរិញ្ញាបត្រអក្សរសាស្ត្រអង់គ្លេស នៅសាកលវិទ្យាល័យបៀលប្រាយ

២០០៣ សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិ នៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

២០០១ សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ នៅពុទ្ធិកវិទ្យាល័យសម្តេច **ជួន-ណាត**

១៩៩៦ ពុទ្ធិកបឋមសិក្សាវត្តសុន្ទរវង្ស ឃុំក្រចេះ ស្រុកក្រចេះ ខេត្តក្រចេះ

១៩៨០ សាលាបឋមសិក្សាភូមិកាប៉ូ ឃុំអូរឫស្សី ស្រុកក្រចេះ ខេត្តក្រចេះ

## មុខតំណែងនិងការងារ

សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរនៃទីស្តីការគណៈរដ្ឋមន្ត្រី

សមាជិកគណៈកម្មការភាសាវិទ្យាខ្មែរនៃទីស្តីការគណៈរដ្ឋមន្ត្រី

សមាជិកគណៈកម្មការនៃការបង្កើតពាក្យនិងកម្ចីពាក្យនៃទីស្តីការគណៈរដ្ឋមន្ត្រី

សមាជិកក្រុមជំនុំព្រះត្រៃបិដកនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ប្រធានសមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរនៃវត្តឧណ្ណាលោម

ISBN-13 : 978-99963-705-4-0
9 789996 370540

ជំនួយស្មារតី សទ្ទានុក្រមពាក្យថ្មី សាស្ត្រាចារ្យ ទូច-គីមស្រ៊ាន ព.ស.២៥៥៨ គ.ស.២០១៤

ជំនួយស្មារតី

# សទ្ទានុក្រមពាក្យថ្មី

សាស្ត្រាចារ្យ ទូច-គីមស្រ៊ាន

សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ

ព. ស. ២៥៥៨ គ. ស. ២០១៤

ជំនួយស្មារតី

# សទ្ទានុក្រមពាក្យថ្មី

សាស្ត្រាចារ្យ ទូច-គីមស្រ៊ាង

សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ

ព. ស. ២៥៥៨ គ. ស. ២០១៤

# សន្ធានុក្រមពាក្យថ្មី


រៀបរៀង : លោក ទូច-គីមស្រ៊ាង

ជំនួយការ : លោក អ៊ុន-សុភា

ឧត្តមទីប្រឹក្សា : ព្រះតេជព្រះគុណ **យស-ហ៊ុត** ខេមចារោ

: ព្រះតេជព្រះគុណ **លីម-ថេង** សោភណោ

: ឯកឧត្តម នាយឧត្តមសេនីយ៍ **តេង-សាវឌ្ឍ**

: ឯកឧត្តម ឧត្តមសេនីយ៍ឯក **ម៉ម-សំ**

: ឯកឧត្តម ឧត្តមសេនីយ៍ទោ **អឿ-សាវ៉ន**

: លោក **អៀង-សុផារ៉ា**

ពិនិត្យអក្ខរាវិរុទ្ធ : ព្រះតេជព្រះគុណ **ហ៊ែន-វិបុល** ឥន្ទជោតោ

: កញ្ញា **ផៃ-សារ៉ែម** កញ្ញា **ឆិញ-ឆីណា**

: លោក **ភោគ-ច័ន្ទវិបុល** លោក **វ៉ាន់-ផល្លី**

: សិស្ស **ហោ-មានលាភ**

រចនាក្រប : កញ្ញា **នូ-ស៊ីនួន**



ISBN-13 9789996 370540



បោះពុម្ពលើកទី១ ថ្ងៃពុធ ទី២៨ ខែឧសភា ឆ្នាំ២០១៤ រក្សាសិទ្ធិគ្រប់បែបយ៉ាង

ការថតចម្លងស្នាដៃរៀបរៀងនៃអ្នកនិពន្ធមកធ្វើអាជីវកម្មជាអំពើល្មើសច្បាប់



ឧបត្ថម្ភបោះពុម្ព : **សប្បុរសជន**

រោងពុម្ព : JSRC Printing House

អាសយដ្ឋានចែកចាយ : បណ្ណាគារសន្តិភាព បណ្ណាគារអន្តរជាតិ សាលាភ្នំពេញ...

# **អារម្ភកថា**

សៀវភៅសទ្ទានុក្រមពាក្យថ្មីនេះ ដែលលោក លោកស្រី និស្សិត អ្នកសិក្សាស្រាវជ្រាវកំពុងតែអាន បង្កើតឡើងក្នុងគោលបំណងបំពេញសំណូមពរលោកគ្រូ អ្នកគ្រូ អ្នកសិក្សាស្រាវជ្រាវទាំងឡាយដែលតែងតែចង់បានចំណេះដឹងអក្សរសាស្ត្រខ្មែរ ដើម្បីយល់ដឹងគំនិតល្អៗពីសទ្ទានុក្រមពាក្យថ្មី ដែលមនុស្សទូទៅមិនទាន់បានយល់ដឹងទៅលើពាក្យថ្មីភាគច្រើននិងមិនសូវចេះប្រើពាក្យថ្មីទាំងនោះឱ្យបានសមស្របផងដែរៗ

ការប្រមូលស្នាដៃរបស់អ្នកនិពន្ធទាំងឡាយ ពីអតីតកាលមករៀបរៀងជាសៀវភៅនេះឡើង គឺមានគោលបំណង គោលដៅ វិសាលភាព និយមន័យរួមចំណែកអភិរក្សនិងអភិវឌ្ឍភាសាជាតិយើងផងនិងចែករំលែកបទពិសោធ ព្រមទាំងទស្សនៈបុរាណនិងទស្សនៈថ្មីជុំវិញវិស័យភាសាខ្មែរយើងផង។

ក្នុងការសិក្សាកន្លងទៅគេបានកំណត់ថា **ភាសា អក្សរសាស្ត្រ** ជាមេកផាងសំខាន់ជាងគេនៃវប្បធម៌ ជាមេនៃប្រាជ្ញា ជាមេនៃការសិក្សា ជាមេនៃសិល្បៈ និងជាអត្តសញ្ញាណជាតិយ៉ាងសំខាន់បំផុត។

ប្រសិនបើមានកំហុសឆ្គងខ្លឹមសារដោយប្រការណាមួយ សូមអ្នកសិក្សាមេត្តាអធ្យាស្រ័យផងចុះ។ ខ្ញុំនឹងរង់ចាំទទួលយកកំហុសដោយសុច្ឆន្ទៈ មនសិការសោមនស្សនូវការកែលម្អពីសំណាក់លោកអ្នកសិក្សាស្រាវជ្រាវទាំងឡាយ។

រាជធានីភ្នំពេញ ១៥រោច ខែពិសាខ ឆ្នាំមមី ឆស័ក ព. ស. ២៥៥៨

ត្រូវនឹងថ្ងៃពុធ ទី២៨ ខែឧសភា ឆ្នាំ២០១៤

សាស្ត្រាចារ្យ **នួច-គឹមស្រ៊ាង**

បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរ

## **កតញ្ញូកតវេទិតាធម៌**

កូនសូមក្រាបថ្វាយបង្គំនិងលើកហត្ថាប្រណម្យឧទ្ទិសស្នាដៃនេះ ជូនចំពោះលោកឪពុក **ទុំ-យ៉េន** អ្នកម្ដាយ **អ៊ុំ-មាស** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតជីវិតកូន។

កូនសូមសម្ដែងនូវកតញ្ញូកតវេទិតាធម៌ ជាអនេកប្បការចំពោះលោកមានគុណទាំងទ្វេដែលបានផ្ដល់កំណើតដល់រូបកូននិងបានចិញ្ចឹមបីបាច់ ថែរក្សា ការពារ អប់រំរូបកូនឱ្យឃ្លាតចាកឆ្ងាយពីអវិជ្ជា។ ព្រះគុណដ៏មហាប្រសើរនេះ រូបកូនចងចាំអស់មួយជីវិត ហើយមិនអាចរកអ្វីយកមកតបស្នងសងគុណឱ្យស្មើបានឡើយ។

សៀវភៅដែលកូនបានរៀបរៀងនេះគ្រាន់តែជាស្នាដៃតូចមួយប៉ុណ្ណោះ តែវាជាសក្ខីភាពមួយបញ្ជាក់ថា រូបកូនមិនបណ្ដោយពេលវេលាឱ្យកន្លងផុតទៅដោយឥតប្រយោជន៍នោះទេ ហើយក៏មិនប្រើប្រាស់វាដើម្បីប្រព្រឹត្តអំពើមិនគួរគប្បីណាមួយនោះដែរ។

កូនសូមសច្ចាប្រព្រឹត្តតែកុសលកម្មនិងរស់នៅជាពលរដ្ឋល្អក្នុងសង្គមជាតិជារៀងដរាប។

រាជធានីភ្នំពេញ ១៥កើត ខែពិសាខ ឆ្នាំមមី ឆស័ក ព. ស. ២៥៥៨

ត្រូវនឹងថ្ងៃពុធ ទី២៨ ខែឧសភា ឆ្នាំ២០១៤

សាស្ត្រាចារ្យ **ទូច-គីមស្រ៊ាង**

បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរ

## **ឧទ្ទិសកថា**

សូមឧទ្ទិសស្នាដៃនេះថ្វាយ ប្រគេន ជូនចំពោះ

- បុព្វបុរសខ្មែរគ្រប់រូបដែលបានធ្វើពលិកម្មគ្រប់យ៉ាងដើម្បីការពារជាតិមាតុភូមិ

- កវី បណ្ឌិត អ្នកនិពន្ធ អ្នកប្រាជ្ញខ្មែរគ្រប់ជំនាន់ដែលបានខិតខំថែរក្សា ការពារវប្បធម៌ ភាសា អក្សរសាស្ត្រជាតិឱ្យបានរីកចម្រើនគង់វង្សរហូតមក

- សម្តេចព្រះមហាសុមេធាធិបតី **ជួន-ណាត** ជោតញ្ញាណោ ព្រះសង្ឃរាជថ្នាក់ទី១ គណៈមហានិកាយ ដែលព្រះអង្គបានបន្សល់ទុកស្នាព្រះហស្តដ៏ពិសេសសម្រាប់ខ្មែរគ្រប់ជំនាន់គឺ **វចនានុក្រមខ្មែរ**

- បុព្វការីជនរបស់ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំបាទទាំងអស់

សូមជួយទ្រទ្រង់វិស័យវប្បធម៌ អក្សរសាស្ត្រជាតិឱ្យកាន់តែរីកចម្រើនជានិច្ចនិរន្តរ៍។

រាជធានីភ្នំពេញ ១៥រោច ខែឧសភា ឆ្នាំមមី ឆស័ក ព. ស. ២៥៥៨

ត្រូវនឹងថ្ងៃពុធ ទី២៨ ខែឧសភា ឆ្នាំ២០១៤

សាស្ត្រាចារ្យ **នួច-គីមស្រ៊ាង**

បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរ

## នាមសប្បុរសជនអ្នកមានឧបការគុណក្នុងការងារធម្មទាន
## ដើម្បីដំណើរការសមាគមមន្ត្រទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរ

- **មណ្ឌលព័ត៌មានស្ត្រីកម្ពុជា** ព្រះតេជព្រះគុណ **យស-ហ៊ុត** ខេមចារោ
- CAM-PAINT **ថ្នាំពណ៌ជាត** **សាលារៀនវ៉េស្គឡាញន៍**
- លោក **ប៊ិច-ប៊ូឡែន** **សាលារៀនឈាត្សឡាញន៍**
- លោក **សោម-សម្បត្តិ** និង លោកស្រី **អ៊ុក-ចន្ថា**
- មហាឧបាសិកា **សុខ-អ៊ឹម** និង បុត្រ **ឆ្វ-ឆៃគៀង**
- ឯកឧត្តម **តេង-សាវង្ស** និង លោកជំទាវ **ស៊ាង-គីម**
- ឯកឧត្តម **ម៉ម-សំ** និង លោកជំទាវ **អ៊ិត-បុប្ផាផល្គុណ**
- ឯកឧត្តម **អឿ-សាវ៉ន** និង លោកជំទាវ **ពៅ-សារឿន**
- ឯកឧត្តម **ចាន់-សារ៉េត** និង លោកជំទាវ **ស៊ឹម-ថារី**
- ឯកឧត្តម **ស៊ិន-ឌឹម** និង លោកជំទាវ **ប៉េង-ហ៊ាង**
- ឯកឧត្តម **លី-វណ្ណនី** និង លោកជំទាវ **ប្រាក់-ចិន្តា**
- ឯកឧត្តម **ម៉ម-ឈាង** និង លោកជំទាវ **ឯម-មុំ**
- ឯកឧត្តម **ង៉ុយ-ហាក់** និង លោកជំទាវ **ង៉ូវ-សុខឡេង**
- ឯកឧត្តម **ឃួន-វចិត្រ** និង លោកជំទាវ **ឌី-នារី**
- ឧបាសក **អៀង-អឿន** និង ឧបាសិកា **អៀង-សាគីម**
- លោក **នុត-វ៉ានី** និង លោកស្រី **អ៊ុន-សោភា**
- លោក **ថាវ-វណ្ណា** និង លោកស្រី **ម៉ី-សុខឌី**
- លោក **គុយ-វ៉ាត** និង **លោកស្រី**
- លោក **អ៊ួង-គីមសេង** និង **លោកស្រី**
- លោក **គីម-ប៊ុន្នី** និង លោកស្រី **សុភ-ស្រី**

- សាស្ត្រាចារ្យ **ហ៊ុយ-ស្វ៉ាត** និង លោកស្រី **សាត-ផាន់ណា**
- លោក **យាង-ច័ន្ទវិទ្ធា** និង លោកស្រី **លី-ហាក់ហៀង**
- ឧបាសក **ទ៉ក់-ហ៊ាង** និង ឧបាសិកា **ម៉ឹង-សឿន**
- លោក **បូ-គីមលាង** និង លោកស្រី **ឈឹម-ស៊ីយ៉ាន**
- លោក **នួន-ហ៊ាន** នាយកសាលាប៉ែលធីទី១០ និង លោកស្រី **ឈឹម-ចន្ទកែវ**
- លោក **ចាន់-ធីតា** នាយកសាលាប៉ែលធីទី៥ និង លោកស្រី **ជឹម-ស្រីមនោ**
- លោក **ស្វ៉ាត-តស្តា** នាយកសាលាប៉ែលធីទី១ និង លោកស្រី **ឈឹម-ឡាលីន**
- លោក **គឹម-ធីរះ** នាយកសាលាប៉ែលធីទី១៣ និង លោកស្រី **ធូ-ជីន ជីន**
- លោក **ឆាច-សំពិសិដ្ឋ** និង លោកស្រី **ហៀត-ផាទីល័យ**
- លោក **ហួយ-ធីរិន** និង លោកស្រី **លាប-រស្មី**
- លោក **យូ-រ័ត្ន** និង លោកស្រី **ឈាំ-មួយជូ**
- លោក **អេង-ហ៊ី** និង លោកស្រី **លឹម-ខេង**
- លោក **ហ៊ាង-បូរ៉ា** និង លោកស្រី **អ៊ូម-សោភា**
- លោក **ឃៀង-សុគន្ធា** និង លោកស្រី **សូ-សុផាន់ណាទី**
- លោក **ពេជ្រ-ពិសិដ្ឋ** និង លោកស្រី **តាន-ដានី**
- លោក **ទ្រឹក-សុខនឹម** និង លោកស្រី **ហៀង-ឆវី**

# សេចក្ដីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណជាអតិបរមាចំពោះឧត្ដមភរិយា **ម៉ែន-សេងយ៉ុង** ហៅ **ស្រីចិន** និងក្រុមគ្រួសារដែលបានយោគយល់និងចែករំលែកពេលវេលាដើម្បីឱ្យខ្ញុំអាចមានឱកាសសិក្សាស្រាវជ្រាវប្រកបដោយជោគជ័យ។

ជាពិសេស សូមគោរពសម្ដែងការដឹងគុណដ៏ជ្រាលជ្រៅបំផុតសន្ដានចិត្ត ចំពោះ **សប្បុរសជន** ដែលមានសន្ដានចិត្តសប្បុរិសធម៌ឧបត្ថម្ភធម្មទានថវិកាជួយបោះពុម្ពសៀវភៅសទ្ទានុក្រមពាក្យថ្មី ក្នុងគោលដៅសំខាន់ផ្សព្វផ្សាយអក្សរសាស្ត្រខ្មែរ ដើម្បីឱ្យប្រជាពលរដ្ឋទូទៅបានយល់ដឹងពីគុណតម្លៃវប្បធម៌ភាសាអក្សរសាស្ត្រជាតិ ព្រមទាំងដើម្បីឱ្យដំណើរការសមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរ។

សូមថ្លែងអំណរគុណឯកឧត្ដម លោកជំទាវ សប្បុរសជន និងលោកអ្នកអាន ដែលបានជួយលើកស្ទួយគុណតម្លៃរៀបរៀង សៀវភៅរបស់ខ្ញុំនិងសូមមេត្តាអធ្យាស្រ័យកំហុសឆ្គងដោយប្រការផ្សេងៗ។ ខ្ញុំនឹងរីករាយទទួលយកការកែលម្អកំហុសដើម្បីឱ្យខ្ញុំបានបម្រើអស់លោកអ្នកអានកាន់តែប្រសើរជាងមុនថែមទៀត។ *សូមអរគុណ !*

រាជធានីភ្នំពេញ ១៥រោច ខែឧសភា ឆ្នាំមមី ឆស័ក ព. ស. ២៥៥៨

ត្រូវនឹងថ្ងៃពុធ ទី២៨ ខែឧសភា ឆ្នាំ២០១៤

បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរ

## អក្សរសង្ខេប

### ប្រើក្នុងសទ្ទានុក្រមពាក្យថ្មីនេះ

| | | |
|---|---|---|
| *កិ.* | : | កិរិយាសព្ទ |
| *កិ. វិ.* | : | កិរិយាវិសេសន៍ |
| *គុ.* | : | គុណសព្ទ |
| *ន.* | : | នាមសព្ទ |
| *វវ.* | : | វេវចនៈ |

# សទ្ទានុក្រមពាក្យថ្មី

## *ពេលបច្ចុប្បន្នភាពមានប្រើជាញឹកញាប់ !*

**កតាទសារ** *ន.* សំណុំរឿងទូទៅដែលគេដាក់ជូនតុលាការជំនុំជម្រះ។

**កតភាគេន** *ន.* ការរំលាយកិច្ចសន្យាចោល, កិរិយាបដិសេធកិច្ចសន្យាណាមួយចោល ដោយមកពីកិច្ចសន្យានោះមានវិការៈទៅដល់ឫសគល់នៃការព្រមព្រៀងគ្នា, ការបដិសេធកិច្ចសន្យាលក់ដោយមកពីការលក់វត្ថុណាមួយថោកជាងពាក់កណ្ដាលនៃថ្លៃដែលត្រូវលក់ក្នុងពេលនោះ :

❖ មានតែអ្នកលក់អចលនវត្ថុទេដែលប្ដឹងសុំកតិកាភេទបាន។

**កថាភាគ** *ន.* ជំពូក, វគ្គ :

❖ ក្នុងរឿងមួយនេះអ្នកនិពន្ធបានចែកជា៥កថាភាគ។

**កម្មសិក្សា** *ន.* ពេលរៀនធ្វើការ, ស្ថានភាពបណ្ដោះអាសន្ន :

❖ ខ្ញុំធ្វើការសព្វថ្ងៃនៅក្នុងកម្មសិក្សានៅឡើយ។

**កម្មសិក្សាការី** *ន.* ឬ *គុ.* អ្នករៀនធ្វើការ, មន្ត្រីបម្រុងរាជការ; ដែលនៅក្នុងពេលរៀនធ្វើការ, ដែលនៅជាមន្ត្រីបម្រុងរាជការ :

❖ លោកសុខ ជាលេខាធិការកម្មសិក្សាការីនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ។

**កម្មសិទ្ធិករ** *ន.* ម្ចាស់កម្មសិទ្ធិ, អ្នកដែលមានសិទ្ធិប្រើប្រាស់សិទ្ធិអាស្រ័យផលនិងសិទ្ធិចាត់ចែងលើវត្ថុណាមួយ។

**កសិផល** *ន.* ផលដែលបានមកពីកសិកម្ម។ ផលិតផលទាំងនោះរួមមាន :

១- ផលដំណាំដែលបានដាំដុះកំពុងលូតលាស់ឬផលដំណាំដែលត្រូវដាំដុះ

២- ទំនិញជលផលដែលផលិតក្នុងប្រតិបត្តិការវារីវប្បកម្ម

៣- សត្វចិញ្ចឹមគ្រប់ប្រភេទរាប់ទាំងកូនសត្វកើតហើយឬមិនទាន់កើត

៤- ទំនិញផ្គត់ផ្គង់ដែលប្រើឬផលិតនៅក្នុងប្រតិបត្តិការកសិកម្ម

៥- ផលដំណាំដែលប្រមូលបានឬផលដែលទទួលបានពីសត្វចិញ្ចឹមគ្រប់ប្រភេទហើយមិនទាន់កែច្នៃ។

**កសិពាណិជ្ជកម្ម** *ន.* ឧស្សាហកម្មមួយដែលទាក់ទងនឹងការផលិតនិងការលក់ផលិតផលផលិតកម្ម ជាពិសេសគ្រប់គ្រងដោយក្រុមហ៊ុនធំៗ។ ជាទូទៅកសិពាណិជ្ជកម្ម មាននៅក្នុងបណ្ដាប្រទេសអភិវឌ្ឍដែលផ្ទុយទៅនឹងបែបផែនផលិតកម្មរបស់កសិករ។

❖ ដំណាំកៅស៊ូ, ដំណាំដូងប្រេង...។

**ការិយាធិបតេយ្យ** *ន.* ប្រព័ន្ធរដ្ឋបាលរបស់អង្គភាពមួយដែលតាមរយៈប្រព័ន្ធនេះការបែងចែកការងារត្រូវបានគេរៀបចំជាឋានានុក្រម ដើម្បីអនុវត្តភារកិច្ចជំនាញដោយឈរលើមូលដ្ឋាននៃវិធានផ្ទៃក្នុង ព្រមទាំងនីតិវិធីរបស់អង្គភាពនេះ។ ពាក្យនេះត្រូវបានគេប្រើសំដៅទៅលើរដ្ឋបាលរបស់រដ្ឋាភិបាលនិងជាពិសេសចំពោះមន្ត្រីរាជការនៅក្នុងជួររដ្ឋាភិបាល ព្រមទាំងមន្ត្រីបម្រើសេវាសាធារណៈផ្សេងៗ។ តាមន័យអវិជ្ជមានគេតែងប្រើពាក្យនេះដើម្បី

សម្គាល់ប្រព័ន្ធរដ្ឋបាលសាំញ៉ាំអនុញ្ញាតឱ្យមន្ត្រីរាជការ ឆ្លៀតយកអំណាចដែលរដ្ឋប្រគល់ឱ្យទៅបម្រើបុព្វសិទ្ធិផ្ទាល់ខ្លួន ដែលនាំឱ្យប៉ះពាល់ដល់ប្រយោជន៍របស់អ្នកដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន :

❖ នៅសហរដ្ឋអាមេរិកការិយាធិបតេយ្យនេះបានរីកដុះដាលដែលធ្វើឱ្យខូចប្រយោជន៍របស់វណ្ណៈអធន ហើយបានដកហូតយកអំណាចពីវណ្ណៈនេះ។

**កាលាទិករណ៍** *ន.* ការអនុវត្តអ្វីមួយមុនពេលដែលបានគ្រោងទុក; ការគិតទុកពីព្រឹត្តិការណ៍នៅពេលអនាគត :

❖ កាលាទិករណ៍នៃការទូទាត់ប្រាក់ចំណេញ។

**កាលានុវត្តភាព** *ន.* ឱកាសដ៏ល្អសម្រាប់ធ្វើអ្វីមួយប្រកបដោយជោគជ័យ។

**ក្រុមប្រឹក្សាភិបាល** *ន.* ក្រុមប្រឹក្សាដែលមានសមាជិកជាតំណាងម្ចាស់ភាគហ៊ុន ហើយតែងតាំងដោយលក្ខន្តិកៈឬមហាសន្និបាតនៃក្រុមហ៊ុនណាមួយ ដើម្បីដឹកនាំការងាររបស់ក្រុមហ៊ុននោះ។ ក្រុមប្រឹក្សាភិបាលអាចមានក្នុងក្រុមហ៊ុន សមាគមអង្គការមិនមែនរដ្ឋាភិបាល ធនាគាររដ្ឋឬឯកជន ស្ថាប័នហិរញ្ញវត្ថុ។

**ខន្តបញ្ញាកម្ម** *ន.* ការផ្គុំបញ្ចូលក្នុងអង្គការណាមួយ។

**គណនេយ្យកិច្ច** *ន.* មុខរបររបស់គណនេយ្យករ។

**គណនេយ្យភាព** *ន.* ការទទួលខុសត្រូវ; ភាពដែលអាចយល់ឬពន្យល់បាន។

**គណៈវិនិច្ឆ័យ** *ន.* ក្រុមប្រឹក្សាតុលាការ, បញ្ជីគណៈវិនិច្ឆ័យ, បញ្ជីក្រុមប្រឹក្សាតុលាការ។

**គុហាវិទ្យា** *ន.* វិទ្យាសាស្ត្រសិក្សាអំពីគុហាដែលរួមមានកំណកំណើតការវិវត្ត ទម្រង់ពពួកសត្វនិងរុក្ខជាតិមីក្រូអាកាសធាតុនិងការប្រើប្រាស់ដោយមនុស្ស។

**គុហាសាស្ត្រ** *ន.* ក្បួនរៀនមើលឬរិះរកវត្ថុដែលកើតពីក្នុងរូងភ្នំដូចជាត្បូងថ្មឬថ្មកែវជាដើម :

❖ អ្នកបច្ចេកទេសចិនពីរនាក់ដែលចេះស្ទាត់ជំនាញខាងគុហាសាស្ត្របានមកជួយប្រទេសខ្មែរយើងក្នុងការស្រាវជ្រាវត្បូងថ្ម។

**គេហកិច្ច** *ន.* កិច្ចការក្នុងផ្ទះ, ការងារក្នុងផ្ទះ, ការងារសម្រាប់មេផ្ទះ :

❖ ស្ត្រីខ្មែរគួរតែរៀនអំពីគេហកិច្ចឱ្យបានចេះដឹងច្រើន។

**គេហចរ** *ន.* ផ្ទះដែលគេអាចដឹកនាំទៅទីដទៃទៀតបានមានរាងរៅដូចជារោងមានកង់សម្រាប់រុញជាដើម។

**គោលការណ៍** *ន.* ហេតុការណ៍ដែលជាគោល, ហេតុដែលមានសារៈសំខាន់ :

❖ គោលការណ៍របស់សមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរគឺពង្រីកអក្សរសាស្ត្រជាតិឱ្យបានទូលំទូលាយ។

**គោលច្បាប់** *ន.* គោលការណ៍នៃច្បាប់, ខសំខាន់ៗជាមូលដ្ឋាននៃច្បាប់, ខដើមរបស់ច្បាប់។

**គោលដៅ** *ន.* លទ្ធផលចុងបញ្ចប់ដែលមនុស្សម្នាក់ឬគម្រោងណាមួយចង់ធ្វើឱ្យបានសម្រេច។

**គ្រន្ថី** *ន.* ប្រដាប់អវយវៈមានសណ្ឋានជាសំបុក :

❖ ក្នុងខ្លួនមនុស្សយើងមានគ្រនីជាច្រើនដូចជាគ្រនីជីវណិកជាដើម។

**ឃោសនិក** *ន.* អ្នកនិយាយឃោសនា, អ្នកដើរផ្សាយដំណឹង។

**ឃោសិត្រ** *ន.* ផ្នែកខាងលើនៃបំពង់ខ្យល់ដែលសម្រាប់បញ្ចេញនូវសូរសំឡេង, អវយវៈក្នុងបំពង់កដែលសម្រាប់បញ្ចេញសំឡេង :

❖ សំឡេងធំនិងតូចតែងតែចេញមកតាមឃោសិត្រទាំងអស់។

**ចក្ខុខស័យ** *ន.* ទិដ្ឋភាពឬរូបភាពក្នុងអារម្មណ៍ពីអ្វីដែលគេចង់បានទៅអនាគតវែងឆ្ងាយ; ការអាចមើលឬស្រមៃឃើញអនាគតដែលអាចបាន។

**ចក្របាលត្រី** *ន.* នាយរក្សាមណ្ឌលឬត្រួតត្រាតាមមណ្ឌលថ្នាក់ទី១ :

❖ នាយតម្រួតម្នាក់ដែលស្គាល់ខ្ញុំមានសក្តិជាចក្របាលត្រី។

**ចក្របាលឯក** *ន.* មេរក្សាមណ្ឌលឬត្រួតត្រាមណ្ឌលថ្នាក់ទី១។

**ចិត្តសាស្ត្រ១** *ន.* វិទ្យាសាស្ត្រដែលសិក្សាអំពីចិត្តគំនិត សកម្មភាពរបស់ចិត្តគំនិត អារម្មណ៍ ការទទួលអារម្មណ៍ :

❖ ចិត្តសាស្ត្រពិសោធ, ចិត្តសាស្ត្រកុមារ។

**ចិត្តសាស្ត្រ២** *ន.* សំណុំផ្នត់គំនិតមនោសញ្ចេតនាប្រតិកម្មរបស់ជនណាម្នាក់ឬរបស់ក្រុមណាមួយ :

❖ ចិត្តសាស្ត្រខ្មែរ, ចិត្តសាស្ត្រអាមេរិក។

**ចិន្តន័យ** *ន.* សំណុំន័យបន្ទាប់បន្សំរបស់ពាក្យមួយក្រៅពីន័យដើមរបស់ពាក្យនោះ។

**ឆន្ទានុសិទ្ធិ** *ន.* អំណាចដែលប្រគល់ដល់ចៅក្រមឱ្យរើសយកតាមចិត្តរបស់ខ្លួននូវមធ្យោបាយណាមួយដែលមានចែងនៅក្នុងច្បាប់ ដើម្បីដោះស្រាយបញ្ហាណាមួយ។ សិទ្ធិរបស់ចៅក្រមក្នុងការជ្រើសរើសយកវិធីណាមួយដើម្បីដោះស្រាយវិវាទ។

**ជនិតា** *ន.* ឧបករណ៍ដែលផ្តល់ចរន្តអគ្គិសនីមានដូចជា ថ្មពិល អាគុយ ឌីណាម៉ូ អាំងទែណាទ័រ។ ជនិតាមានកម្លាំងអគ្គិសនីចលករនិងរេស៊ីស្តង់ខាងក្នុងផងដែរ។

**ជីវធនលាភ** *ន.* ធនលាភមួយជីវិត។

**ឋាននាមវិទ្យា** *ន.* ការសិក្សាអំពីដើមកំណើតនៃឈ្មោះទីកន្លែងនិងទំនាក់ទំនងរបស់ទីកន្លែងជាមួយនឹងភាសាដែលបាត់បង់ទៅ :

❖ ភ្នំដូនពេញជាឋាននាមខ្មែរ។

**ឋានលេខវិទ្យា** *ន.* វិទ្យាសាស្ត្រដែលសិក្សាអំពីវិធីគាងសណ្ឋានដីដោយចំណោលធាតុរបស់សណ្ឋានដីទៅលើផ្ទៃរាបនិងការធ្វើផែនទីឋានលេខវិទ្យា។

**ឋានលេខា** *ន.* គំនូសដែលគេដៅកម្ពស់ដីឬព្រៃភ្នំ :

❖ លោកសុខកំពុងតែរៀនពិនិត្យឋានលេខាលើផែនដីភូមិសាស្ត្រ។

**ឋានសមាជិក** *ន.* សមាជិកដែលជាប់មុខងារ, សមាជិកមានមុខមាត់ :

❖ លោកនីជាអតីតឋានសមាជិកក្នុងក្រុមកាកបាទក្រហមខ្មែរ។

**ឋានសិទ្ធិ** *ន.* សិទ្ធិតាមទីកំណើត, សិទ្ធិទទួលបានសញ្ជាតិតាមកំណើត។

**តតិយតា** *ន.* សន្ទឹកបង្កាន់ដៃលើកទីបី :

❖ ពេលខ្ញុំធ្វើបាត់លិខិតទុតិយតាទៅខ្ញុំក៏ទៅសុំលិខិតតតិយតាម្ដងទៀត។

**តន្តិនិយម** *ន.* លទ្ធិរបស់ពួកអ្នកនិពន្ធខាងផ្នែកការសិក្សា, ការនិយមរបស់ពួកអ្នកនិពន្ធខាងការត្រាប់ក្បួនបុរាណ។

**តារាសាស្ត្រ** *ន.* វិជ្ជាខាងការរៀនពិនិត្យមើលផ្កាយ :

❖ ជនជាតិចេះតារាសាស្ត្រពូកែជាងគេសម័យដើមគឺជនជាតិឥណ្ឌា។

**តុល្យបញ្ញត្តិ** *ន.* ច្បាប់តែងតាំងឱ្យស្មើគ្នា, ច្បាប់ស្មើគ្នា :

❖ ក្រសួងយុត្តិធម៌បានប្រជុំថៅក្រមដើម្បីធ្វើនូវតុល្យបញ្ញត្តិមួយស្ដីពីអាករនៃពន្ធ។

**ទស្សនាទាន** *ន.* ការពិចារណាអំពីគំនិតឬអំពីផែនការអ្វីមួយ។ របៀបពិសេសក្នុងការបញ្ចេញឬបង្ហាញគំនិតឬក៏ផែនការ។

**ទារកភាព** *ន.* ភាពរឡិករឡក់, ភាពជាកូនក្មេងតូច, អំពើរឡិករឡក់ :

❖ ប្អូនប្រុសខ្ញុំធំហើយតែវានៅតែមានទារកភាពនៅឡើយ។

**ទារកវប្បកម្ម** *ន.* វិធីចិញ្ចឹមទារក, របៀបចិញ្ចឹមកូនតូច :

❖ ស្ត្រីជាមាតាគួរតែចេះនូវទារកវប្បកម្មឱ្យបានច្រើន។

**ទិនសភា** *ន.* ទីប្រជុំដែលគេមកប្រជុំជារៀងរាល់ថ្ងៃ :

❖ ប្រទេសខ្មែរយើងគេមិនទាន់ឃើញមានទិនសភានៅឡើយទេ។

**ទុតយតា** *ន.* សន្លឹកបង្កាន់ដៃលើកទីពីរ :

❖ សព្វថ្ងៃខ្ញុំកាន់វិក្កយបត្រទុតិយតាដែលហាងលក់កង់ចេញឱ្យ។

**ទុរុបយោគ** *ន.* ការបំពានឬការភ័ន្តច្រឡំ។ ការប្រើប្រាស់សិទ្ធិឬការប្រើប្រាស់សិទ្ធិមិនល្អ មិនត្រឹមត្រូវ ហួសកម្រិតព្រំដែនមួយដែលច្បាប់បានកំណត់។

**ទុស្សុបិន** *ន.* សុបិនអាក្រក់ :

❖ យប់មិញខ្ញុំដេកលក់ហើយមានទុស្សុបិន។

**ទូតបណ្ណ** *ន.* បណ្ណឬលិខិតសម្រាប់ប្រើប្រាស់ខាងកិច្ចការទូត, លិខិតដែលគេប្រើជាផ្លូវការទូត :

❖ លោកអគ្គលេខាធិការនៃក្រសួងការបរទេសបានឱ្យទូតបណ្ណដល់ខ្ញុំ។

**ទូរចរ** *ន.* អ្នកដើរផ្លូវឆ្ងាយ, អ្នករកស៊ីផ្លូវឆ្ងាយ :

❖ ជនជាតិអារ៉ាប់ច្រើនតាំងខ្លួនជាទូរចរ។

**ទូរបញ្ជា** *ន.* ឧបករណ៍អេឡិចត្រូនិកសម្រាប់បញ្ជាគ្រឿងយន្តណាមួយពីចម្ងាយ; សកម្មភាពក្នុងការបញ្ជាគ្រឿងយន្តណាមួយពីចម្ងាយ។

**ទូរសារ** *ន.* ឧបករណ៍សម្រាប់ផ្ញើឯកសារថតចម្លងសំបុត្រឬរូបភាព...។

**ទេពកោសល្យ** *ន.* ការប៉ិនប្រសប់, ភាពឈ្លាសវៃ, ភាពវាងវៃ :

❖ សម្ដេចទ្រង់ប្រកបដោយទេពកោសល្យខ្ពស់ រកជនណាម្នាក់មកប្រៀបប្រដូចពុំបានឡើយ។

**ទេពនិទាន** *ន.* រឿងរ៉ាវរបស់ទេវតា, រឿងព្រះអាទិទេពនិងវីរបុរសក្នុងជំនាន់ដើម :

❖ ហោរាម្នាក់ចេះនូវទេពនិទានយ៉ាងពូកែ។

**ទេសរដ្ឋមន្ត្រី** *ន.* រដ្ឋមន្ត្រីដែលមានយសសក្តិថ្នាក់ខ្ពស់ជាងរដ្ឋមន្ត្រី, រដ្ឋមន្ត្រីរបស់ប្រទេស។

**ទ្វិធា** *ន.* ផ្នែកពីរ, ចំនួនដែលចែកជាពីរ :

❖ ពាក្យគណិតវិទ្យា : ចំនួននេះត្រូវតាមរបៀបទ្វិធា។

**ទ្វិសភានិយម** *ន.* របបនយោបាយមានសភាពីរដែលមានសភាតំណាងរាស្ត្រនិងព្រឹទ្ធសភា :

❖ ប្រទេសបារាំងនិងសហរដ្ឋអាមេរិកជាប្រទេសដែលប្រកាន់យកប្រព័ន្ធទ្វិសភានិយម។

**ទ្វេធាតុ** *ន.* អ្វីដែលកើតឡើងដោយឯកតាពីរ, អ្វីដែលបង្ហាញទិដ្ឋភាពពីរ :

❖ ជំហាមទ្វេធាតុ គឺទំនាក់ទំនងរវាងលក្ខណៈខុសគ្នារបស់ប្រព័ន្ធសទ្ទតាញឬថ្លង់ មានខ្យល់ឬគ្មានខ្យល់ មុខឬក្រោយ បិទឬបើក។

**ទ្វេបថ** *ន.* អ្វីដែលឃ្លាតពីគ្នាជាពីរផ្លូវ, ផ្លូវបែកជាពីរ :

❖ នៅមន្ទីរសម្ភពមួយនោះគេឃើញការរៀបចំទីផ្កាល្អណាស់ដោយមានវិថីជាទ្វេបថ។

**ទ្វេពន្ធភាព១** *ន.* បុរសឬស្ត្រីទាំងឡាយដែលមានអាពាហ៍ពិពាហ៍ពេញច្បាប់មិនទាន់រំលាយ ហើយបានទៅរៀបអាពាហ៍ពិពាហ៍ដោយពេញច្បាប់ម្តងទៀត។

**ទ្វេពន្ធភាព២** *ន.* ប្រភេទបទល្មើសមជ្ឈិមដែលអយ្យការចោទប្រកាន់បានដោយចិត្តឯងឬចោទតាមបណ្តឹងរបស់សហព័ទ្ធណាមួយ ដែលបានប្តឹងមក

អាពាហ៍ពិពាហ៍ពេញច្បាប់, ជាកិច្ចសន្យាពេញច្បាប់រវាងបុរសម្នាក់និងស្ត្រីម្នាក់ដែលប្ដេជ្ញាថា នឹងរួមសមគ្គសង្វាសជាមួយគ្នាស្របច្បាប់ហើយនិងបានចុះក្នុងបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុក្កូលដ្ឋាន។ បើមិនដូច្នោះទេគេអាចចាត់ទុកថាជាគូកំណាន់ឬសហាយនឹងគ្នា។

**ធនិកាធិបតេយ្យ** *ន.* របបគ្រប់គ្រងរដ្ឋដែលអំណាចនយោបាយស្ថិតនៅក្នុងកណ្ដាប់ដៃអ្នកដែលមានទ្រព្យសម្បត្តិច្រើនជាងគេ។

**ធម្មនុញ្ញភាព** *ន.* ភាពស្របតាមរដ្ឋធម្មនុញ្ញនៃលិខិតបទដ្ឋាន។ តុលាការធម្មនុញ្ញឬក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកត្រួតពិនិត្យធម្មនុញ្ញភាពនៃលិខិតបទដ្ឋាន។

**ធម្មានុរូប** *គុ.* ដែលត្រូវតាមច្បាប់, ដែលស្របច្បាប់, ដែលសមគួរតាមធម៌, ដែលមានទំនងដ៏សមគួរតាមធម៌, ដែលស្របទៅតាមធម៌, ដែលសមរម្យត្រឹមត្រូវតាមច្បាប់។ ដែលមានគុណភាពស្របទៅតាមច្បាប់ឬត្រូវនឹងសេចក្ដីតម្រូវរបស់ច្បាប់, អ្វីដែលពេញលក្ខណៈច្បាប់ឬស្របទៅតាមច្បាប់, ដែលទទួលស្គាល់ដោយច្បាប់, ដែលធ្វើឱ្យទទួលស្គាល់តាមច្បាប់។

**ធម្មានុរូបកម្ម** *ន.* ការធ្វើឱ្យជនគ្មានគុណភាពតាមច្បាប់ឱ្យក្លាយជាជនមានគុណភាពបរិបូរតាមច្បាប់, ការបំពេញតាមទម្រង់ច្បាប់។ លិខិតដែលបំពេញតាមច្បាប់ឱ្យឥតខាន់ស្លាទទួលបាននូវទ្រព្យសម្បត្តិ ជាកូនមានខាន់ស្លាតទៅ :

❖ ឪពុកម្ដាយដែលរស់នៅជាមួយគ្នាដោយមិនបានរៀបការពេញច្បាប់ទេឈ្មោះថាជាប្ដីប្រពន្ធគ្មានខាន់ស្លា។ កូនដែលកើតពីប្ដីប្រពន្ធនេះឈ្មោះ

ថាកូនឥតខាន់ស្លាដូចគ្នា។ ប៉ុន្តែកូននេះអាចមានខាន់ស្លាឬការទទួលស្គាល់តាមផ្លូវច្បាប់ នៅពេលណាដែលឪពុកម្ដាយគេបានរៀបការត្រឹមត្រូវតាមច្បាប់ឡើងវិញ។

**ធម្មានុរូបភាព** *ន.* ភាពត្រូវតាមច្បាប់, ភាពត្រឹមត្រូវតាមច្បាប់។

**ធារាសាស្ត្រ** *ន.* ក្បួនរៀនអំពីផ្លូវទឹក, ប្រព័ន្ធផ្លូវទឹកនៅក្នុងប្រទេសមួយឬតំបន់មួយ :

❖ ក្រុមឧត្ដុនិយមបានបញ្ជូននិស្សិតខ្មែរពីររូបឱ្យទៅរៀនធារាសាស្ត្រកសិកម្មនៅក្រុងឡុងនៃចក្រភពអង់គ្លេស។

**ធារី** *ន.* អ្នកទទួលកិច្ចការ, អ្នករ៉ាប់រងភារកិច្ច :

❖ នៅប្រទេសវៀតណាមមានធារីខ្មែរនៅធ្វើការអបរដ្ឋនេះ។

**ធុរកិច្ច** *ន.* ការធ្វើជំនួញពាណិជ្ជកម្ម, ការវិនិយោគ។

**ធុរជន** *ន.* ពាណិជ្ជករ, អ្នកជំនួញ។

**នគរូបនីយកម្ម** *ន.* វិធានគតិយុត្តដែលបង្កើតឡើងសម្រាប់ធ្វើឱ្យបានសម្រេចនូវអភិវឌ្ឍន៍ប្រកបដោយសណ្ដាប់ធ្នាប់ល្អនៃទីប្រជុំជននានា, ការអភិវឌ្ឍនិងការកើនឡើងខាងបរិមាណនៃប្រជាជនរស់នៅក្នុងទីក្រុង :

❖ ច្បាប់ស្ដីពីនគរូបនីយកម្មត្រូវបានរដ្ឋសភាអនុម័តឱ្យប្រើរួចហើយ។

**នរនាមវិទ្យា** *ន.* វិទ្យាសាស្ត្រឬការសិក្សាអំពីដើមកំណើតឬក៏ប្រវត្តិនាមនៃមនុស្ស។

**នរមាត្រ១** *ន.* វិធីវាស់វែងខ្លួនមនុស្សប្រើក្នុងនរវិទ្យា។

**នរមាត្រ២** *ន.* បច្ចេកទេសសម្គាល់ភិនភាគជនល្មើស ដោយផ្អែកលើរង្វាស់មនុស្សនិងលើសញ្ញាផ្ទាល់ខ្លួនខ្លះដូចជាទម្រង់សរីរាង្គមាន ត្រចៀក ច្រមុះ ជើងជាដើម។

**នវកជន** *ន.* មនុស្សស៊ីវិល័យ,មនុស្សសម័យថ្មី :

❖ គេនិយាយថាខ្ញុំជានវកជនម្នាក់ដែរ។

**នវកម្ម** *ន.* ការបង្កើតកាតព្វកិច្ចថ្មីមួយដើម្បីយកទៅជំនួសកាតព្វកិច្ចចាស់ :

❖ ការយកស្រែស្ដែងទៅដាក់បញ្ចាំជំនួសស្រែទួលដែលបញ្ចាំពីថ្ងៃមុន។

**នវានុវត្តជន** *ន.* អ្នកអនុវត្តបែបថ្មី; អ្នកដែលបង្កើតកសាងឬបញ្ចូលអ្វីមួយថ្មីទៅក្នុងវិស័យណាមួយ។

**នវានុវត្តន៍** *ន.* ការបញ្ចូលមកថ្មី, ការមកដល់ថ្មី, ការអនុវត្តបែបថ្មី :

❖ មនុស្សម្នាក់នេះទើបនឹងធ្វើនវានុវត្តន៍មកកាន់ខេត្តកំពង់ធំ។

**នានាភាព** *ន.* លក្ខណៈឬភាពនៃអ្វីៗដែលមានច្រើននិងប្លែកៗគ្នា។

**នាមលេខា** *ន.* គំនូសសញ្ញាជាសម្គាល់ឈ្មោះរបស់ខ្លួន :

❖ គេពុំសូវប្រើពាក្យនាមលេខាដូចជាហត្ថលេខាឡើយ។

**នាយកដ្ឋាន** *ន.* អង្គភាពរដ្ឋបាលចំណុះរបស់ក្រសួងរដ្ឋលេខាធិការដ្ឋានឬអគ្គនាយកដ្ឋានដឹកនាំដោយនាយកឬប្រធាននាយកដ្ឋាន។ នាយកដ្ឋានចែកចេញជាការិយាល័យចំណុះមួយចំនួន ដែលដឹកនាំដោយនាយការិយាល័យ

ឬប្រធានការិយាល័យ។ ជួនកាលគេប្រើពាក្យទីចាត់ការជំនួសក៏មានដូចជា ទីចាត់ការគយ ទីចាត់ការកិច្ចការគរុកោសល្យ...។

**នាយការ** *ន.* អ្នកត្រួតត្រាការ, អ្នកចាត់ចែងការ :

❖ មិត្តខ្ញុំបីនាក់បានចូលក្របខណ្ឌជានាយការពេញលក្ខណៈហើយ។

**នាយដ្ឋាន** *ន.* កន្លែងចាត់ការរបស់នាយ, កន្លែងរបស់នាយ :

❖ នាយដ្ឋានកងវរសេនាតូចមួយកងនៅត្មាតពងស្ថិតនៅខាងមុខបន្ទាយ។

**នាវាឥណ្ឌា** *ន.* នាវាឬយន្តហោះដឹកទំនិញធំៗ។

**នាវាចារី** *ន.* អ្នកធ្វើអាជីវកម្មជំនួញនាវា។

**និកម្មភាព** *ន.* បាតុភូតសេដ្ឋកិច្ចនៅក្នុងសង្គមដែលប្រជាពលរដ្ឋមួយចំនួនមានសមត្ថភាពការងារ ប៉ុន្តែស្ថិតនៅក្នុងសភាពមិនអាចរកការងារធ្វើបាន។

**និកម្មវេលា** *ន.* ពេលគ្មានការងារធ្វើ, សម័យអសកម្មភាពក្នុងឧស្សាហកម្ម។

**និក្ខិតឥណ្ឌា** *ន.* ទឹកប្រាក់ដែលផ្ញើទុកនៅស្ថាប័នហិរញ្ញវត្ថុ, ប្រាក់តម្កល់។

**និក្ខេបករ** *ន.* អ្នកខ្ចីប្រាក់ហើយមានរបស់ទ្រព្យដាក់ធានា។

**និក្ខេបគាហកៈ** *ន.* ជនដែលបានឱ្យប្រាក់ទៅឱ្យនិក្ខេបករហើយទទួលបានផលប្រយោជន៍ប្រាតិភោគលើទ្រព្យសម្បត្តិដែលជានិក្ខេបនោះ។

**និក្ខេបីយ** *គុ.* ដែលអាចដាក់បញ្ចាំបាន។

**និគមជន** *ន.* អ្នកដែលតាំងលើទឹកដីអាណានិគមដោយខ្លួនឯងផ្ទាល់ឬតាមរយៈឪពុកម្ដាយនាំមក។

**និគ្រោះ** *ន.* ការបង្ក្រាប, ការកម្ចាត់លែងឱ្យមានកម្លាំងចម្រើនទៅទៀត, ការផ្តាញ់ផ្តាលបង្ក្រាប។

**និច្ចការ** *ន.* កិច្ចការដែលត្រូវធ្វើជានិច្ច, ការដែលត្រូវធ្វើជារៀងរាល់ពេល :

❖ ការអានសៀវភៅ គឺជានិច្ចការរបស់ខ្ញុំ។

**និច្ចលនិយម** *ន.* ការប្រកាន់នូវរបៀបមិនកម្រើក, លទ្ធិប្រកាន់យកការមិនកម្រើកឬផ្លាស់ប្តូរទៅជាប្រការណានីមួយ :

❖ អ្នកសច្ចំខន្តីគេហៅថា អ្នកប្រកាន់និច្ចលនិយមក៏បាន។

**និច្ចលភាព** *ន.* ភាពមិនកម្រើក, ភាពឥតរញ្ជួយ, ភាពឥតរង្គើ, ភាពគ្មានចលនា។

**និដ្ឋិតកម្ម** *ន.* កិច្ចការដែលគេធ្វើសម្រេចហើយ, ការដែលគេធ្វើរួចហើយ :

❖ បូជនីយដ្ឋានឯករាជ្យជិតបានដល់និដ្ឋិតកម្មហើយ។

**និទាយាទភាព** *ន.* ស្ថានភាពនៃមត៌កដែលគ្មានទាយាទទទួល ហើយដែលមត៌កនោះនឹងក្លាយទៅជាប្រយោជន៍របស់រដ្ឋ :

❖ និទាយាទភាពរបស់បុគ្គលដែលគ្មានបងប្អូនកូនចៅសាច់ញាតិ។

**និទ្ទណ្ឌភាព** *ន.* ការអាចប្រើប្រាស់តួនាទីឬមុខតំណែងរបស់អ្នកណាម្នាក់ដើម្បីគេចវេះពីការដាក់ទោស ដែលកើតឡើងដោយអំពើខុសច្បាប់ឬដោយការបំពានទៅលើសិទ្ធិអ្នកដទៃ។ ការគ្មានដាក់ទោស។

**និទ្ទនភាព** *ន.* ធនក្ស័យនៃពាណិជ្ជករដោយកំហុសនានា, ប្រធានជាហេតុនាំឱ្យឥណទាយកលែងជឿទុកចិត្តក្នុងកិច្ចប្រាស្រ័យ។ ភាពពុំមានលទ្ធភាពបង់ប្រាក់សំណាងទៅម្ចាស់បំណុលរបស់ពាណិជ្ជករ បន្ទាប់ពីគេបានប្រព្រឹត្តបទល្មើសណាមួយមក :

❖ ពាណិជ្ជករម្នាក់បានរត់ពន្ធទំនិញខុសច្បាប់រដ្ឋ ហើយត្រូវភ្នាក់ងារមានសមត្ថកិច្ចចាប់យកទំនិញទាំងអស់។ ពេលនោះគាត់គ្មាននៅសល់ទុនទៀតទេ មិនតែប៉ុណ្ណោះគាត់ថែមទាំងជំពាក់បំណុលគេទៀត ស្ថានភាពនេះគេហៅថា និទ្ទនភាព។

**និន្នវារណ៍១** *ន.* ការហាមឃាត់របស់រដ្ឋមិនឱ្យនាវាបរទេសចេញពីកំពង់ផែរបស់ខ្លួន។

**និន្នវារណ៍២** *ន.* ការហាមឃាត់មិនឱ្យនាំចេញនូវទំនិញខុសច្បាប់មួយចំនួនដូចជាគ្រឿងអាវុធ និងគ្រាប់រំសេវឬគ្រឿងញៀនឆ្ពោះទៅកាន់រដ្ឋណាមួយជាកំណត់។ និន្នវារណ៍អាចអនុវត្តបានទាំងនៅពេលមានសង្គ្រាមនិងនៅពេលមានសន្តិភាព។ នៅពេលមានសង្គ្រាមការអនុវត្តនិន្នវារណ៍មានទម្រង់ជាការរាំងខ្ទប់សេដ្ឋកិច្ច។ នៅពេលមានសន្តិភាពគេអនុវត្តនិន្នវារណ៍ជាមធ្យោបាយដើម្បីគាបសង្កត់នយោបាយ និងសេដ្ឋកិច្ចចំពោះប្រទេសមួយផ្សេងទៀត។ ការហាមឃាត់ជាបណ្តោះអាសន្នមិនឱ្យនាវាចេញពីកំពង់ផែ; ការហាមមិនឱ្យផ្សាយ; ការរឹបអូស។

**និរាសជន** *ន.* បុគ្គលដែលគ្មានសញ្ជាតិ ពីព្រោះជននោះបានបោះបង់សញ្ជាតិរបស់ខ្លួនឬត្រូវបានតុលាការប្រកាសដកសញ្ជាតិចេញ ហើយពុំទាន់បានទទួលសញ្ជាតិថ្មីពីរដ្ឋណាមួយទៀតនៅឡើយ។

**និមុត្តិបណ្ណ** *ន.* ចំណារនិងហត្ថលេខាដែលម្ចាស់បំណុលបានចុះលើលិខិតមួយសម្រាប់ឱ្យកូនបំណុលទុកជាភស្តុតាងថាបានសងបំណុលរួចហើយ។

**និយ័ត** *គុ.* ដែលទៀងទាត់, ដែលមានជារៀងរាល់ពេល :

❖ ខ្ញុំតែងតែទៅធ្វើការរាល់ថ្ងៃជាទម្លាប់និយ័តរបស់ខ្ញុំ។

**និយតកម្ម១** *ន.* ការធ្វើឱ្យទៀងទាត់, ការធ្វើឱ្យមានភាពទៀងទាត់ឡើង :

❖ សិស្សម្នាក់បានសូមសាលាក្រុងឱ្យធ្វើនិយតកម្មលើលិខិតរបស់ខ្លួន។

**និយតកម្ម២** *ន.* ការធ្វើលិខិតគតិយុត្តឬលិខិតនីតិវិធីណាមួយដែលមិនស្របច្បាប់ឱ្យមានភាពស្របទៅនឹងបញ្ញត្តិច្បាប់ ដែលនាំឱ្យលិខិតនោះមានលក្ខណៈត្រឹមត្រូវអាចយកទៅអនុវត្តបាន។

**និយតករ** *ន.* វត្ថុឬអ្វីៗដែលអាចត្រួតពិនិត្យឬកែតម្រូវអ្វីមួយជាប្រចាំ។

**និយតភាព** *ន.* ភាពដ៏ទៀងទាត់, ភាពដ៏ពិតប្រាកដ :

❖ ដោយសារនិយតភាពក្នុងកិច្ចការរបស់លោក ទើបបានជាលោកមានកេរ្តិ៍ឈ្មោះល្បីល្បាញ។

**និយាម១** *ន.* ស្តង់ដាឬគំរូដែលគេទទួលស្គាល់ជាទូទៅ។ ស្តង់ដាឬកម្រិតរង្វាស់អាកប្បកិរិយាឬបំណិន ដែលគេទទួលស្គាល់ជាទូទៅក្នុងសហគមន៍ឬសង្គមមួយ :

❖ ភេរវកម្មជាការរំលោភលើនិយាមរបស់សង្គមដែលមានអរិយធម៌។

**និយាម២** *ន.* លក្ខណវិនិច្ឆ័យឬគោលការណ៍កំណត់ប្រភេទទំនិញ ត្រូវកំណត់ប្រភេទទំនិញ ត្រូវផលិតឬលក្ខខណ្ឌបច្ចេកទេសផលិតកម្ម :

❖ និយាមផលិតភាព គឺផលិតភាពមធ្យមនៃសាខាសេដ្ឋកិច្ចណាមួយ។

**និរាករ** *កិ.* លុបចោល, លែងឱ្យប្រើតទៅទៀត, ទុកជាឥតបានការ, លែងមានអានុភាពអនុវត្តតទៅទៀត។

**និរាករណ៍** *ន.* អានុភាពតែសម្រាប់ទៅថ្ងៃអនាគតមានន័យថា លិខិតដែលត្រូវបាននិរាករ លែងមានអានុភាពអនុវត្តចាប់គិតពីថ្ងៃលុបទៅអនាគតប៉ុណ្ណោះ។ និរាករណ៍មានពីរប្រភេទ :

១- និរាករណ៍ដោយច្បាស់លាស់ : បើសិនជាមានបញ្ជាក់នៅក្នុងបទបញ្ជាថ្មី ថាបទបញ្ជាណាមួយត្រូវនិរាករ។

២- និរាករណ៍ដោយតុណ្ហីភាព : ការលុបបទបញ្ជាមុនតាមរយៈការចេញបទបញ្ជាថ្មីជំនួស។ មានន័យថាបទបញ្ជាចាស់ដែលមានបញ្ញត្តិផ្ទុយនឹងបទបញ្ជាថ្មីត្រូវនិរាករដោយស្ងាត់ស្ងៀមឬដោយតុណ្ហីភាព។ ការលុបចោល,

ការមិនឱ្យអនុវត្តតទៅទៀត, ការប្រកាសលែងឱ្យប្រើច្បាប់ដែលមានពីមុនមកដោយសារតែមានច្បាប់ថ្មីមួយទៀតមកជំនួស។

**និរុត្តិវិទ្យា** *ន.* វិទ្យាសាស្ត្រសិក្សាអំពីធម្មជាតិរបស់ពាក្យ ជាពិសេសលើការវិវត្តរបស់ពាក្យភាសា, ការសិក្សាអំពីអត្ថបទអក្សរសិល្ប៍ ឯកសារសរសេរដែលមានទំនាក់ទំនងទៅនឹងអរិយធម៌ឬអ្នកនិពន្ធណាមួយ ព្រមទាំងសិក្សាអំពីដើមកំណើតពាក្យនិងទំនាក់ទំនងទាំងឡាយរបស់ពាក្យទាំងនោះ :

❖ អ្នកឯកទេសខាងឯកទេសផ្នែកនិរុត្តិវិទ្យា។

**និវត្តជន** *ន.* បុរសឬស្ត្រីដែលស្ថិតក្នុងវ័យចូលនិវត្តន៍, អ្នកដែលត្រូវឈប់សម្រាកពីការងារ។

**និវេទន៍** *ន.* សេចក្តីថ្លែង, សេចក្តីប្រកាស។

**និវេទនបណ្ណ** *ន.* បញ្ជីរាយមុខទំនិញក្នុងការដឹកជញ្ជូនតាមនាវាឬតាមមធ្យោបាយផ្សេងទៀត។

**និស្លាបនា** *កិ.* រុះរើចេញ, បំផ្លាញឱ្យខូច :

❖ ការផ្សំផ្គុំកើតជារូបរាងឡើងជាកិច្ចលំបាកពេក ប៉ុន្តែបើនិស្លាបនាវិញគឺងាយបំផុត។

**និស្សន្ទវត្ថុ** *ន.* របស់ដែលក្លាយមកពីរបស់ដទៃ :

❖ អង្ករគឺជានិស្សន្ទវត្ថុដែលក្លាយមកពីស្រូវ។

**នីតិរដ្ឋ** *ន.* រដ្ឋអាស្រ័យច្បាប់, រដ្ឋមានប្រព័ន្ធច្បាប់, រដ្ឋមានការអនុវត្តច្បាប់ និងការគោរពច្បាប់ដោយពេញលេញមានប្រព័ន្ធទទួលខុសត្រូវ និងយុត្តិធម៌ជាក់លាក់។

**នីត្យានុកូល** *គុ.* ដែលត្រឹមត្រូវតាមច្បាប់, ដែលអនុលោមតាមច្បាប់, ដែលកើតមកពីច្បាប់, ដែលច្បាប់គាក់តែងមក, ដែលអនុញ្ញាតដោយច្បាប់។

**នីត្យានុកូលកម្ម** *ន.* នីតិវិធីដែលមន្ត្រីរាជការណាម្នាក់បានបញ្ជាក់ទទួលស្គាល់ថាហត្ថលេខាទាំងឡាយលើលិខិតមួយត្រឹមត្រូវតាមច្បាប់ :

❖ នីត្យានុកូលកម្មសំបុត្រកំណើតឬសញ្ញាបត្រ។

**នីត្យានុកូលភាព** *ន.* គោលការណ៍ជាមូលដ្ឋាននៃសកម្មភាពរបស់រដ្ឋបាលដែលផ្តល់ការធានាជាន់ដំបូងដល់ពលរដ្ឋ។ គោលការណ៍នោះគឺរដ្ឋបាលសាធារណៈអាចធ្វើសកម្មភាពបានតែក្នុងក្របខណ្ឌ ដែលច្បាប់បានកំណត់ប៉ុណ្ណោះ។

**បក្កភាពផលិតផល** *ន.* ភាពដែលផលិតផលឈានដល់ចំណុចខ្ពស់ចុងក្រោយនៃជីវិតពាណិជ្ជកម្មរបស់ខ្លួន។

❖ អ្នកបច្ចេកទេសទីផ្សារត្រូវរៀបចំផែនការទីផ្សារពីវដ្តជីវិតផលិតផលជាពិសេសនៅដំណាក់កាលបក្កភាពផលិតផល។

**បដិការគុណ** *ន.* ការទទួលដឹងគុណជាថ្មី, ការដឹងគុណ, ការធ្វើគុណតបទៅវិញ។

**បដិកោសលទច័យ** *ន.* ការត្រួតមើលលើការពិនិត្យរបស់អ្នកជំនាញ, ការត្រួតមើលលើសេចក្ដីរាយការណ៍របស់អ្នកជំនាញ។

**បដិក្ខិត** *គុ.* ដែលទំនាស់, ដែលច្រាសទៅវិញ, ដែលផ្ទុយ។

**បដិគ្គាហកដ្ឋាន** *ន.* កន្លែងសម្រាប់ទទួលប្រាក់បង់ពន្ធទូទៅ, កន្លែងបង់ពន្ធ។

**បដិចារកម្ម** *ន.* ការស៊ើបសួរអ្នកធ្វើចារកម្ម, ការអង្កេតរកពួកចារបុរស។

**បដិដុល្លារូបនីយកម្ម** *ន.* ការដកប្រាក់ដុល្លារសហរដ្ឋអាមេរិកពីចរាចរណ៍រូបិយវត្ថុនៅលើទីផ្សារ។

**បដិនាននាម** *ន.* អ្នកឈរឈ្មោះ។ អាណត្តិគាហកៈដែលធ្វើអ្វីៗដើម្បីផលប្រយោជន៍របស់អាណត្តិទាយក ប៉ុន្តែធ្វើឱ្យគេឃើញនឹងយល់ថាខ្លួនធ្វើដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនដោយរ៉ាប់រងបុគ្គលនៃកិច្ចសន្យាដោយផ្ទាល់ខ្លួន។

**បដិបក្ខភាព** *ន.* ការស្អប់ខ្ពើមរវាងមនុស្សឬក្រុមមនុស្ស។ ភាគីមួយក្នុងទំនាស់ដែលប្រឆាំងនឹងគូបដិបក្ខ គេហៅថាអ្នកទំនាស់ឬអ្នកប្រឆាំង :

❖ បដិបក្ខភាពរវាងដើមចោទនិងចុងចោទ, បដិបក្ខភាពរវាងទ្រឹស្ដីប្រជាធិបតេយ្យនិងទ្រឹស្ដីកុម្មុយនីស្ត...។

**បដិពាណិជ្ជ** *ន.* បដិពាណិជ្ជឬកិច្ចព្រមព្រៀងទូទាត់ដោះដូរកើតឡើងនៅពេលដែលភាគីមួយនៃកិច្ចសន្យាប្រគល់ទំនិញ សេវាកម្ម បច្ចេកវិជ្ជាឬរបស់មានតម្លៃផ្សេងៗទៀតទៅនឹងភាគីមួយទៀត ហើយជាថ្នូរដែលភាគីមួយទៀតផ្ដល់ទំនិញ សេវាកម្ម បច្ចេកវិជ្ជាឬរបស់មានតម្លៃឱ្យទៅភាគីទីមួយ។

ប្រទេសជាច្រើននៅអាស៊ីអាគ្នេយ៍ អឺរ៉ុបខាងកើត និងអាហ្វ្រិកជាប្រពៃណីមានការពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងទូទាត់ដោះដូរ។ ប្រទេសសិង្ហបុរីគឺជាមជ្ឈមណ្ឌលពាណិជ្ជកម្មដោះដូរទំនិញចម្បងប្រចាំតំបន់នៅអាស៊ីអាគ្នេយ៍នេះ។

**បដិរូប** *ន.* រូបសំណាក, រូបគំនូរមនុស្ស, រូបប្រៀប, រូបផ្ទៀបប្រដូច។

**បដិវិញ្ញាសា** *ន.* វិញ្ញាសាដែលសម្រាប់ត្រួតពិនិត្យលើវិញ្ញាសាណាមួយ។

**បដិសច្ចៈ** *ន.* វត្ថុផ្ទុយនឹងការពិត, អ្វីដែលពុំពិតប្រាកដ។

**បដិសព្ទ** *ន.* ពាក្យដែលមានន័យឈមគ្នាដូចជា ញើផ្ទុយនឹងឈ្មោល, តូចផ្ទុយនឹងធំ, អាក្រក់ផ្ទុយនឹងល្អ...។

**បដ្ឋនាលិខិត** *ន.* លិខិតដែលពលរដ្ឋផ្ញើជូនទៅរដ្ឋសភាដើម្បីប្តឹងតវ៉ាពីការរំលោភបំពានរបស់រដ្ឋឬថ្លែងមតិស្តីពីការកែប្រែច្បាប់។

**បឋមតា** *ន.* សន្លឹកលិខិតទី១, សន្លឹកដើម :

- ❖ វិក្កយបត្រនេះ គឺជាវិក្កយបត្របឋមតា។

**បណ្ណាសារដ្ឋាន** *ន.* ទីសម្រាប់តម្កល់លិខិតផ្សេងៗដែលមានសារៈសំខាន់ដូចបញ្ជីអត្រានុកូលដ្ឋានជាដើម។

**បត្យាប័ន** *ន.* នីតិវិធីដែលរដ្ឋមួយសុំទៅរដ្ឋមួយទៀតឱ្យប្រគល់ជនដែលបានប្រព្រឹត្តបទល្មើសមកឱ្យតុលាការប្រទេសរបស់ខ្លួន ដើម្បីជំនុំជម្រះទោសតាមរយៈកិច្ចព្រមព្រៀងមួយ ដោយកំណត់បទល្មើសអ្វីមួយដែលត្រូវអនុវត្ត។

**បទបញ្ញត្តិ** *ន.* សេចក្ដីជាច្បាប់, សេចក្ដីបង្គាប់ជាច្បាប់, ខសំខាន់របស់លិខិតក្នុងតុលាការ, លិខិតគតិយុត្ត, ខដែលចែងក្នុងមាត្រានីមួយៗរបស់ច្បាប់ដើម្បីចាប់បង្ខំឱ្យប្រព្រឹត្តតាមឬហាមឃាត់មិនឱ្យប្រព្រឹត្តអ្វីមួយ :

❖ បទបញ្ញត្តិទូទៅ (សេចក្ដីបង្គាប់ជាទូទៅ)។

**បមាណដ្ឋាន** *ន.* ទីសម្រាប់ដាក់ជាគំរូ, ទីសម្រាប់ដាក់ជាមាត្រា, ទីសម្រាប់ដាក់ជាខ្នាត, កន្លែងនៃការប្រមាណ :

❖ អ្នកជំនួញម្នាក់បានតាំងបមាណដ្ឋាននៅផ្សារថ្មីសម្រាប់លក់វិទ្យុ។

**បមាណីយកម្ម** *ន.* ការធ្វើតាមគំរូតែមួយ, ការរៀបចំតាក់តែងនិងការអនុវត្តនៃការទាមទារដោយបង្ខំជាឯកសណ្ឋាន នៅក្នុងផ្នែកណាមួយនៃសកម្មភាពមនុស្ស (ឧស្សាហកម្ម កសិកម្ម វិទ្យាសាស្ត្រ តិកនិក វប្បធម៌ សុខាភិបាល...) កម្មវត្ថុនៃបមាណីយកម្ម គឺជាមុខទំនិញរូបី (ច្បាស់លាស់) នានាធម្មនិយាម (គោលការណ៍ដែលទុកជាវិធាន) នានាសញ្ញា (ការហៅ)...។ ក្នុងគោលបំណងសម្រាប់ផលិតកម្មយ៉ាងច្រើន។ បមាណីយកម្មមានមុខងារយ៉ាងសំខាន់ក្នុងសកម្មភាពសេដ្ឋកិច្ច។ លទ្ធផលច្បាស់លាស់នៃបមាណីយកម្មបានយល់ព្រមនិងអនុម័តដោយអង្គការមានសមត្ថកិច្ចណាមួយ ជាបទដ្ឋាន (បមាណីយ) កម្មសិទ្ធិសង្គមនៃមធ្យោបាយផលិតកម្ម រួមអនុញ្ញាតឱ្យប្រើបមាណីយកម្មក្នុងឋានៈជាមូលដ្ឋាននៃការរៀបចំនិងតិកនិក ដើម្បីដឹកនាំគ្រប់គ្រងសេដ្ឋកិច្ចជាតិក្នុងរបៀបផែនការ។

**បរទត្ថភាព** *ន.* ការគិតប្រយោជន៍ឱ្យអ្នកដទៃ, ការធ្វើប្រយោជន៍ឱ្យជនដទៃ :

❖ បណ្ឌិតខ្លះមានបរទត្ថភាពដ៏ប្រសើរលើសបណ្ឌិតដទៃទៀត។

**បរទេសី** *ន.* ជនអ្នកមកពីប្រទេសដទៃ, មនុស្សប្រទេសក្រៅ។

**បរមតសញ្ញ័យ** *ន.* បញ្ហាមិនសមហេតុផលរបស់ប្រាក់សន្សំ គឺភាពដែលផ្ទុយនឹងមតិធម្មតា ដែលពន្យល់ស្រាយបំភ្លឺនូវព្រឹត្តិការណ៍ជាបំណងនៃការសន្សំប្រាក់របស់ប្រទេសមួយទាំងមូល អាចនាំឱ្យមានការចុះថយនៃផលទុនជាតិ។ (ចំណូលជាតិ) ដោយគ្មានកំណើនពិតនៃប្រាក់សន្សំសរុបផងទេ។

**បរមានុភាព** *ន.* អំណាចខ្ពស់បំផុត, អានុភាពខ្ពង់ខ្ពស់។

**បរសំយោគ** *ន.* ពាក្យដែលកើតឡើងដោយការបូកបញ្ចូលផ្នត់ដើមនិងផ្នត់ចុង :

❖ ពាក្យ វិសមតាព កើតឡើងដោយការបញ្ចូលផ្នត់ដើម វិ និងផ្នត់ចុង តាព ទៅលើឫស សម។

**បរិភព្វ** *ន.* ពាណិជ្ជកម្មមានបំណងចង់បានចំណេញ។ យុត្តិសាស្ត្របារាំងបានប្រើលក្ខណៈនេះ ដើម្បីអ្នកលេងបណ្ណាភាគហ៊ុនស្ថិតនៅក្រោមការគ្រប់គ្រងនៃនីតិពាណិជ្ជកម្មឬដើម្បីបញ្ជាសសកម្មភាពរបស់សមាគម សហជីព និងក្រុមសាមគ្គីពីនីតិពាណិជ្ជកម្មនេះ ប៉ុន្តែម្យ៉ាងទៀតមានសកម្មភាពរដ្ឋប្បវេណីខ្លះមានបំណងចង់បានចំណេញដែរ :

❖ សិប្បករ គ្រូពេទ្យ គ្រូបង្រៀន...។

**បរិកប្បសេដ្ឋកិច្ច** *ន.* ការរកស៊ីប្រថុយឬការឆ្លៀតឱកាសដើម្បីរកចំណេញខាងផ្នែកសេដ្ឋកិច្ច។

**បរិការណ៍** *ន.* ព្រឹត្តិការណ៍ទាំងឡាយដែលកើតមុននិងក្រោយណាមួយ។ បរិការណ៍រួមមាន :

១- អត្ថបទទាំងមូលដែលនៅមុខឬក្រោយប្រយោគឬសេចក្ដីណាមួយ

២- កាលៈទេសៈឬសភាពការណ៍ទូទៅ ដែលព្រឹត្តិការណ៍ណាមួយស្ថិតនៅ :

❖ នៅក្នុងបរិការណ៍នេះស្ថានភាពពិភពលោកប្រែប្រួល...។

**បរិចរ** *គុ.* ដែលទៅពីកន្លែងមួយទៅកន្លែងមួយទៀត, ដែលមិននៅនឹងកន្លែងតែមួយ :

❖ គេឃើញជនជាតិចិន វៀតណាមច្រើនតែជាឈ្មួញបរិចរ។

**បរិចារកិច្ច** *ន.* ការនៅបម្រើគេ, ការបម្រើគេ។

**បរិច្ចត្តតាហារៈ** *ន.* អ្នកទទួលនូវសម្បត្តិទ្រព្យដែលជនណាមួយលះបង់ឱ្យ។

**បរិច្ចត្តបុគ្គល** *ន.* មនុស្សដែលគេលែងរាប់រក, អ្នកដែលគេបោះបង់ចោល។

**បរិច្ចាគី** *ន.* បុរសដែលបរិច្ចាគទ្រព្យសម្បត្តិ, ប្រុសអ្នកលះបង់ធនធាន។

**បរិជាននា** *ន.* ការដឹង, ការស្គាល់ :

❖ លោកធំខ្លះធ្វើហាក់ដូចជាពុំមានបរិជាននាចំពោះអ្នកតូចសោះ។

**បរិត្តផរណា** *ន.* ការដកចំនួនរូបិយវត្ថុមួយភាគចេញពីទីផ្សារដែលលើសពីចំនួនត្រូវការចរាចររបស់សាច់ប្រាក់ ដើម្បីធ្វើឱ្យចំនួនក្រដាសរូបិយវត្ថុសមាមាត្រនឹងតម្រូវការចាំបាច់សម្រាប់ចរាចរ។ បរិត្តផរណាជាដំណើរការផ្ទុយពីអតិផរណា។

**បរិធាន** *ន.* ប្រដាប់វិទ្យាសាស្ត្រដែលអាចបង្កើតចេញជាអ្វីមួយ :

❖ ប្រដាប់ថតរូបនេះគេហៅថាបរិធានថតរូប។

**បរិនាវាចរណ៍** *ន.* ការធ្វើដំណើរតាមនាវាព័ទ្ធជុំវិញ, ការធ្វើដំណើរព័ទ្ធជុំវិញតាមនាវា។

**បរិបទ១** *ន.* សំណុំអត្ថបទមានពាក្យសំនួនសេចក្ដីឃ្លាសម្រាប់បញ្ជាក់ន័យ :

❖ ពាក្យអាចមានន័យបានលុះត្រាតែស្ថិតនៅក្នុងបរិបទ។

**បរិបទ២** *ន.* សំណុំស្ថានភាពដែលព្រឹត្តិការណ៍កើតមាន ហើយស្ថានភាពទាំងនោះផ្ដល់តម្លៃឬន័យទៅឱ្យព្រឹត្តិការណ៍ទាំងនោះ :

❖ បរិបទសង្គម

❖ បរិបទនយោបាយ។

**បរិបរៈ** *គុ.* ដែលមិននៅមួយកន្លែង, ដែលចល័តពីកន្លែងមួយទៅកន្លែងមួយ :

❖ អ្នកជំនួញបរិបរៈ

❖ ពេទ្យបរិបរៈ។

**បរិពន្ធភូមិ** *ន.* ដីដែលគ្មានច្រកចេញមកកាន់ផ្លូវសាធារណៈណាមួយក្រៅពីឆ្លងកាត់ដីរបស់គេដែលព័ទ្ធជុំវិញ។

**បរិលាភ** *ន.* ប្រាក់រង្វាន់របស់អាជ្ញាសាលាមេធាវី...។ តាមអត្រាកំណត់របស់ច្បាប់រដ្ឋ។

**បរិវចនៈ** *ន.* ពាក្យពន្យល់សេចក្ដី, ពាក្យសម្រាប់ពន្យល់ន័យ។

**បរិវត្ត** *ន.* រូបមន្តដែលមានសេចក្ដីឱ្យយកទៅអនុវត្តបាន។

**បរិវិសកម្ម** *ន.* ការសុំចុះឈ្មោះចូលក្នុងបញ្ជីអ្វីមួយ, ការសុំចុះឈ្មោះចូលជាសមាជិកក្នុងបញ្ជីអ្វីមួយ។ លិខិតគតិយុត្តដែលបុគ្គលម្នាក់សន្យាថានឹងទិញ :

- ❖ បរិវិសកម្មចំពោះកាតព្វកិច្ចឬចំពោះការខ្ចី
- ❖ បរិវិសកម្មស្នាដៃនឹងត្រូវបោះពុម្ពផ្សាយបរិវិសកម្មភាគហ៊ុន។

**បរិវិសករ១** *ន.* អ្នកសុំចុះឈ្មោះក្នុងបញ្ជីអ្វីមួយ, អ្នកដែលបានចុះឈ្មោះក្នុងបញ្ជីរួចហើយ។

**បរិវិសករ២** *ន.* រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើកិច្ចសន្យាចូលជាសមាជិកក្រុមហ៊ុនភាគហ៊ុនដោយនាំយកភាគទុនមកដាក់ មានចំនួនទឹកប្រាក់ស្មើនឹងចំនួនដែលចុះនៅក្នុងបណ្ណនោះ។

**បរិសិដ្ឋ** *ន.* សេចក្ដីបន្ថែម, ការបន្តពីភាគធំ :

- ❖ សេចក្ដីមួយឃ្លាខាងក្រោយនេះជាបរិសិដ្ឋរបស់អ្នកនិពន្ធ។

**បរិស្ថាន** *ន.* មជ្ឈដ្ឋាននៅជុំវិញខ្លួនទាំងអស់ឬសំណុំលក្ខខណ្ឌក្រៅទាំងអស់ដែលមានឥទ្ធិពលដល់ជីវិត និងការលូតលាស់របស់ឯកត:ឬបណ្តាភាវៈ។ បរិស្ថានរួមមាន :

១- បរិស្ថានធម្មជាតិ : បរិស្ថានរូបឬបរិស្ថានគ្មានជីវិត (កត្តាទឹកដីនិងកត្តាអាកាសធាតុ សីតុណ្ហភាព សំណើម ភ្លៀង ព្រិល...) និងបរិស្ថានជីវៈឬបរិស្ថានមានជីវិត (មនុស្ស ពពួកសត្វ ពពួករុក្ខជាតិ)។

២- បរិស្ថានវប្បធម៌ : អគារ ហេដ្ឋារចនាសម្ព័ន្ធទីក្រុង ប្រព័ន្ធស្រោចស្រព រោងចក្រ ចម្ការដំណាំ សង្គមមនុស្ស សកម្មភាពសង្គម...។ ជួនកាលគេប្រើពាក្យបរិស្ថានក្នុងន័យចង្អៀតដូច “បរិស្ថានជំនួញ, បរិស្ថានការងារ”។

**បសន្នភាព** *ន.* ភាពថ្លាបរិសុទ្ធ; បើជាទឹកគឺទឹកដែលគេអាចទទួលទានបាន។

**បសាទចិត្ត** *ន.* ចិត្តថ្លាស្អាត, ចិត្តជ្រះថ្លា :

❖ យើងខ្ញុំសូមសរសើរចំពោះបសាទចិត្តសប្បុរសជនដែលបានជួយឧបត្ថម្ភធម្មទានថវិកាបោះពុម្ពសៀវភៅផ្សេងៗ។

**បហារិក១** *ន.* ជនដែលចេញរូបិយាណត្តិឬមូលប្បទានបត្រ។

**បហារិក២** *ន.* បុគ្គលដែលបង្គាប់ឱ្យបុគ្គលផ្សេងទៀតបង់ប្រាក់តាមរយៈការប្រើរូបិយាណត្តិ។

**បាណវិទ្យា** *ន.* សាខានៃសត្តវិទ្យាដែលសិក្សាអំពីសត្វល្អិត។

**ធាលិត** *ន.* កូនកំព្រាដែលនៅជាអនីតិជនស្ថិតនៅក្រោមអាណាព្យាបាលនៃជនណាម្នាក់។

**បិដ្ឋិតាហក:** *ន.* អ្នកទទួលបិដ្ឋិលេខ។

**បិដ្ឋិលេខ** *ន.* វិធីធម្មតាក្នុងការផ្ទេរផលបត្រពាណិជ្ជកម្ម។ វិធីក្នុងការផ្ទេរផលបត្រពាណិជ្ជកម្មដោយសារមានចុះហត្ថលេខា នៅលើខ្នងនៃផលបត្រនេះដោយអនុប្បទាយី ដែលបញ្ជាទៅកូនបំណុលឱ្យបង់ប្រាក់តាមចំនួនដែលបានចុះក្នុងផលបត្រនោះឱ្យទៅអនុប្បទានិក។

**បិដ្ឋិលេខកម្ម** *ន.* ការផ្ទេរផលបត្រពាណិជ្ជកម្មឬមូលប្បទានបត្រដោយការចុះហត្ថលេខានៅលើខ្នងលិខិត (ផលបត្រពាណិជ្ជកម្មឬមូលប្បទានបត្រ) នោះដែលម្ចាស់លិខិតបញ្ជាទៅឥណាយិក (កូនបំណុល, ធនាគារ) ឱ្យផ្ដល់ប្រាក់ទៅឱ្យម្ចាស់លិខិតថ្មី។

**បិដ្ឋិលេខជន** *ន.* អ្នកធ្វើបិដ្ឋិលេខ។

**បុគ្គលភាពគតិយុត្ត** *ន.* លក្ខណៈពេញច្បាប់នៃបុគ្គលឬភាពជាបុគ្គលពេញច្បាប់ដែលច្បាប់ទទួលស្គាល់ថាមានសិទ្ធិនិងកាតព្វកិច្ច :

- ❖ កូនក្នុងផ្ទៃម្ដាយមិនទាន់មានបុគ្គលភាពគតិយុត្តទេ។

**បុណ្ណាធូត** *ន.* បុគ្គលដែលបានទទួលអំណាចពេញទីដើម្បីតំណាងរដ្ឋាភិបាលក្នុងកិច្ចចរចាណាមួយ។

☞ *ទទ.* ឯកអគ្គរាជទូតពេញសមត្ថភាព។

**បុត្តសម្ព័ន្ធ** ន. ប្រភេទក្រុមហ៊ុនដែលមានដើមទុនជាង៥០%ជារបស់ក្រុមហ៊ុនមួយទៀតហៅថា "ក្រុមហ៊ុនមេ"។ បុត្តសម្ព័ន្ធអាចមានឯករាជ្យតាមផ្លូវច្បាប់ តែតាមផ្នែកហិរញ្ញវត្ថុនិងសេដ្ឋកិច្ចត្រូវរណបទៅនឹងក្រុមហ៊ុនមេ។

**បុននិយោជន៍** ន. ការទិញនូវទ្រព្យរបស់អ្វីមួយដោយប្រើប្រាស់ថ្លៃលក់របស់មួយផ្សេងទៀតធ្វើជាមធ្យោបាយ។

**បុននីហរណកម្ម** ន. ការនាំចេញទៅវិញនូវទំនិញដែលបាននាំចូលដោយមិនបានកែច្នៃអ្វីទាំងអស់។

**បុនប្បហារ** ន. ការលក់ដូរនូវឧបករណ៍បំណុលដែលអាចជួញដូរបានដែលធ្លាប់បានលក់ម្តងរួចមកហើយដោយធនាគារមួយ។ ប្រតិបត្តិការនេះច្រើនតែធ្វើជាមួយនឹងធនាគារកណ្តាល។

**បុនផលិតកម្ម** ន. បុនផលិតកម្មគឺជាការធ្វើឡើងវិញជាថ្មីនិងជានិច្ចរហូតនូវដំណើរការរបស់ផលិតកម្មសង្គម។ គ្រប់បុនផលិតកម្មសង្គមនិងទ្រព្យសម្ភារៈឬផលិតផលសង្គម សរុបរួមមានបញ្ចូលបុនផលិតកម្មនៃកម្លាំងពលកម្មនិងទំនាក់ទំនងពលកម្ម។ បុនផលិតកម្មមានពីរយ៉ាងគឺ បុនផលិតកម្មសាមញ្ញ និងបុនផលិតកម្មទូលាយ។ បុនផលិតកម្មសាមញ្ញ គឺជាដំណើរការផលិតកម្មដែលប្រព្រឹត្តទៅពីមួយឆ្នាំទៅមួយឆ្នាំទៀតនៅក្នុងសមាមាត្រដដែល; ចំណែកឯបុនផលិតកម្មទូលាយ មានសមាមាត្រកាន់តែធំទូលាយច្រើនជាងមុនទៅទៀត។

**បុនហិរញ្ញប្បទាន** *ន.* ការសងប្រាក់ខ្លះឬទាំងអស់នៃកម្ចីដើមទុនរបស់សហគ្រាសណាមួយដែលទើបបានទទួលកម្ចីថ្មីទៀត (តាមធម្មតាកម្ចីថ្មីៗទាំងនោះតែងមានអត្រាការប្រាក់ទាបជាងមុន)។

**បុប្ផារម្ភកាល** *ន.* ពេលដែលផ្កាឈើចាប់ផ្ដើមផ្កាឡើង, រដូវផ្ការីកចាប់ផ្ដើមផ្កា។

**បុព្វញាតិ** *ន.* ពួកជនដែលកើតមុនពួកជនមួយពួកទៀត :

❖ ឪពុកម្ដាយ ជីដូនជីតា...ជាបុព្វញាតិរបស់កូនចៅ ចៅទួត។

**បុព្វលាភហានិភ័យ** *ន.* បុព្វលាភឬប្រាក់ចំណូលដែលត្រូវតែបង់បន្ថែមដោយយោងតាមកម្រិតនៃហានិភ័យ។

**បុរេមា** *ន.* សិទ្ធិបើកឱ្យជនណាម្នាក់បានធ្វើអ្វីមុនជនឯទៀត, សិទ្ធិជាអាទិភាព។

**បុរាណនរវិទ្យា** *ន.* សាខានៃនរវិទ្យាដែលសិក្សាអំពីកំណកំណើតការវិវត្តផ្នែករូបកាយនិងវប្បធម៌លក្ខណៈពូជសាសន៍ ទំនៀមទម្លាប់សង្គម និងជំនឿរបស់មនុស្សដើមដំបូង។

**បុរាណនិទាន** *ន.* និទានជាន់ដើម, រឿងព្រេង។

**បុរាណភូមិវិទ្យា** *ន.* វិទ្យាសាស្ត្រដែលសិក្សាអំពីភូមិវិទ្យាក្នុងធរណីកាលដូចជារបាយនៃទ្វីបនិងសមុទ្រ សណ្ឋានដី អាកាសធាតុ... ក្នុងប្រវត្តិផែនដី។

**បុរាណវត្ថុវិទ្យា** *ន.* វិទ្យាសាស្ត្រដែលសិក្សាអំពីសង្គមមនុស្សសម័យបុរាណតាមរយៈសំណល់នៃរបស់របរប្រើប្រាស់ ឧបករណ៍ពលកម្ម អាវុធ ជម្រកភូមិករ

ផ្នូរខ្មោចដែលគេជីកកកាយឃើញ។ ចំណេះខាងការពិនិត្យមើលរបស់បុរាណ, ចំណេះខាងវត្ថុបុរាណសម័យ។

**បុរាណអាកាសធាតុវិទ្យា** *ន.* វិទ្យាសាស្ត្រដែលសិក្សាអំពីអាកាសធាតុនៅលើផែនដីកាលពីសម័យដើមតាមរយៈការសិក្សាសំបកផែនដី, ការសិក្សាកត់ត្រាអំពីផូស៊ីលនិងភស្តុតាងរូបដទៃទៀត។

**បុរេគណនី** *ន.* ការគិតរាប់ចំនួនទុកជាមុន, ការគ្រោងបញ្ជីទុកជាមុន :

❖ ការិយាល័យគណនេយ្យបានធ្វើនូវបុរេគណនីមួយដើម្បីទុកចាយនៅឆ្នាំ២០១៥។

**បុរេនិច្ឆ័យ** *ន.* ការមានមតិអវិជ្ជមានមិនសមហេតុផលលើអ្នកដែលខុសពីខ្លួនជាពិសេសដោយសាររឿងពូជសាសន៍ ភេទ សាសនា...។ ដោយពុំបានដឹងរឿងច្បាស់លាស់ឬធ្លាប់មានបទពិសោធជាមួយនឹងអ្នកទាំងនោះ។ ការវិភាគទំនាស់នឹងបង្ហាញឱ្យឃើញនូវបុរេនិច្ឆ័យ ព្រមទាំងរូបភាពអវិជ្ជមាននិងចរិតឯទៀតៗដែលគូភាគីមានអំពីគ្នាទៅវិញទៅមក។

**បុរេនិមិត្ត** *ន.* ការប្រមើលមើលមុន, និមិត្តខាងដើម, បុព្វនិមិត្ត, ហេតុដំណើរមុន :

❖ មុននឹងគេធ្វើកិច្ចការអ្វីនីមួយៗគេត្រូវធ្វើបុរេនិមិត្ត។

**បុរេប្រទាន** *ន.* ប្រាក់មួយភាគបើកឱ្យមុនពេលសាមីជនបំពេញកាតព្វកិច្ចរបស់ខ្លួនដែលបានព្រមព្រៀងគ្នារួចហើយ។

**បុរេប្រវត្តិសាស្ត្រ** *ន.* រយៈពេលនៃប្រវត្តិសាស្ត្ររបស់មនុស្សជាតិមុនរយៈពេលដែលគេកត់ត្រាទុកជាឯកសារ ៖

❖ ស្ថានីយបុរេប្រវត្តិសាស្ត្រ។

**បុរេភាព** *ន.* សិទ្ធិឬហេតុកើតមុនគេដែលគេអាចយកទៅជំទាស់និងបណ្ដឹកម្មសិទ្ធិ ឧស្សាហកម្ម ហើយដែលឱ្យបណ្ដឹងនេះមោឃៈ។

**បុរេរថ** *ន.* រថឬយានសម្រាប់ទៅយកការណ៍ឬចាត់ការនៅខាងមុខគេ។

**បុរេអវសិដ្ឋ** *ន.* ប្រាក់ដែលនៅសល់ជំពាក់ពីលើកមុន, ការសេសសល់ពីលើកមុន, ប្រាក់កម្រៃដែលបើកមិនទាន់អស់នៅសល់ពីលើកមុន, ប្រាក់សោធន ៖

❖ គ្រឹះស្ថានជំនួញយ៉ាងធំមួយបានសុំឱ្យថៅកែម្នាក់សងប្រាក់ដែលជាបុរេអវសិដ្ឋឱ្យគ្រប់ចំនួន។

**បូតប្រតិបក្ស** *គុ.* ដែលសម្រាប់រារាំងកុំឱ្យអតិសុខុមប្រាណកើតចម្រើនឡើងបាន ៖

❖ ទឹកកំបោរ, ទឹកក្រេស៊ីលគេហៅថា វត្ថុបូតិប្រតិបក្ស។

**បេឡាករ** *ន.* អ្នកទទួលឬបញ្ចេញប្រាក់ក្នុងអង្គភាព ស្ថាប័ន ក្រុមហ៊ុន។ បច្ចុប្បន្នគេច្រើនប្រើពាក្យបេឡាករនេះជាង ព្រោះខ្លីជាងពាក្យបេឡាធិការ។

**បេឡានិច័យ** *ន.* ការដាក់ប្រាក់ទុកនៅក្នុងបេឡា។

**បេយ្យាលន័យ** *ន.* ន័យសង្ខេប, សេចក្ដីបំប្រួញ ៖

❖ ន័យមួយឃ្លានេះ គឺជាបេយ្យាលន័យរបស់អ្នកនិពន្ធ។

**ប្រជាប្រិយភាព** *ន.* ភាពដែលជាទីនិយមពេញចិត្តដល់ប្រជាជន :

❖ ប្រជាប្រិយភាពរបស់អ្នកដឹកនាំ។

**ប្រជាសាស្ត្រ** *ន.* វិទ្យាសាស្ត្រដែលសិក្សាអំពីបរិមាណប្រជាជន។

**ប្រជាសិទ្ធិ** *ន.* សេចក្តីសម្រេចរបស់ប្រជារាស្ត្រ, សេចក្តីព្រមព្រៀងរបស់រាស្ត្រ :

❖ ដោយមានប្រជាសិទ្ធិអំពីរាស្ត្រអ្នកស្រុកស្មោងទើបបានជាលោកថាបានជាប់ជាតំណាងរាស្ត្រ។

**ប្រតបក្ស** *ន.* អ្នកដែលប្រឈមមុខដាក់គ្នាទៅវិញទៅមកក្នុងទំនាស់។ អាចហៅបានថា គូប្រឆាំង, ភាគីជំទាស់, អ្នកមានជម្លោះ។

**ប្រតិបត្តិការ** *ន.* ការងារដែលធ្វើ, អំពើដែលប្រព្រឹត្ត :

❖ ទាហានមួយកងវរសេនាតូចបានទៅធ្វើប្រតិបត្តិការនៅប៉ែកខាងជើងនៃភ្នំប្រសិទ្ធិ៍។

**ប្រជាគណិតវិទ្យា** *ន.* វិទ្យាសាស្ត្រសិក្សាអំពីចំនួនទម្រង់របាយនិងការអភិវឌ្ឍរបស់ប្រជាជនដើម្បីរៀបចំស្ថិតិស្តីពីកត្តានានាដូចជា អត្រាកំណើត អត្រាមរណៈ អាពាហ៍ពិពាហ៍ ការលែងលះ អាយុរស់នៅ ការផ្លាស់លំនៅ...។

**ប្រតិភូកម្ម** *ន.* ការផ្ទេរសមត្ថកិច្ចឱ្យអ្នកក្រោមឱវាទផ្ទាល់ប្រតិបត្តិការងារជំនួស។ ប្រតិភូកម្ម នេះមានពីរបែប :

១- ប្រតិភូកម្មអំណាច : ការរៀបចំយ៉ាងជាក់លាក់អំពីសមត្ថកិច្ចរវាងអាជ្ញាធររដ្ឋបាលទាំងឡាយ។ អ្នកដែលទទួល ប្រតិភូកម្ម នេះក្លាយជាម្ចាស់

អំណាចដែលគេប្រគល់ឱ្យហើយ មានសិទ្ធិគ្រប់គ្រាន់ក្នុងការចេញសេចក្ដីសម្រេចផ្សេងៗ។ អ្នកដែលបានប្រគល់ប្រតិភូកម្មនោះគឺបាត់សិទ្ធិក្នុងក្របខណ្ឌច្បាប់ហើយគ្មានសិទ្ធិចេញសេចក្ដីសម្រេចលើអ្វីដែលខ្លួនបានផ្ទេរនោះឡើយ។

២- ប្រតិភូកម្មហត្ថលេខា : បែបបទមួយក្នុងការបែងចែកតួនាទីដើម្បីចេញសេចក្ដីសម្រេច។ អ្នកដែលទទួលប្រតិភូកម្មមានសិទ្ធិចេញសេចក្ដីសម្រេចក្នុងនាមអ្នកប្រគល់ប្រតិភូកម្មនោះ។

**ប្រតិលិខិត** *ន.* លិខិត (កិច្ចសន្យាជាលាយលក្ខណ៍អក្សរ) ដើម្បីកែប្រែខ្លឹមសារឬអានុភាពនៃលិខិតចេញមុខ។

**ប្រតិទេយ្យន៍តយ** *ន.* ឯកសារប្រកាសប្រាប់ដល់ភ្នាក់ងារគយអំពីមុខទំនិញនាំចូលឬនាំចេញរបស់ក្រុមហ៊ុន ដែលហុចផលទៅឱ្យជាអំពើអតីតកាលមានអានុភាពធាក់ថយក្រោយ។

**ប្រតិសកម្ម** *ន.* គុណភាពដែលហុចផលទៅឱ្យ ជាអំពើអតីតកាលមានអានុភាពធាក់ថយក្រោយ។

**ប្រតិសកម្មភាព** *ន.* លក្ខណៈរាថយក្រោយ, ភាពរាថយក្រោយ។ លក្ខណៈនៃលិខិតគតិយុត្ត ដែលមានអានុភាពអនុវត្តថយក្រោយទៅលើអំពើឬហេតុការណ៍ដែលកើតមុនលិខិតឬច្បាប់នោះ :

- ❖ កិច្ចចាត់ការរបស់លោកនាយកសាលានេះហាក់ដូចជាប្រព្រឹត្តទៅក្នុងប្រតិសកម្មភាព។

**ប្រទសិទ្ធិ** *ន.* សិទ្ធិដែលមានបន្តមកពីអ្នកដទៃ, អំណាចដែលមានចំពោះមុខ, អ្នកដែលទទួលសិទ្ធិពីគេដើម្បីខ្លួនឯងផងជំនួសអ្នកដទៃផង។

**ប្រតិស្រពណ៍** *ន.* សេចក្ដីយល់ព្រម, ការយល់ព្រម, ការគាប់ចិត្ត, ការរីករាយ, ការប្ដេជ្ញា :

❖ ប្រធានខ្ញុំហាក់ដូចជាមានប្រតិស្រពណ៍ចំពោះខ្ញុំខ្លះដែរ។

**ប្រទានកម្ម** *ន.* កិច្ចសន្យាផ្ទេរកម្មសិទ្ធិទ្រព្យណាមួយរបស់ជនម្នាក់ទៅជនម្នាក់ទៀតដែលព្រមទទួលយកទ្រព្យនោះ ជាអំណោយជាសំណងថ្លៃការឬជារង្វាន់ឬក៏ដើម្បីដាក់ធុរៈអ្វីមួយទៅអ្នកទទួល។ ប្រទានកម្មជាប្រាក់ឬវត្ថុមិនអាចរើរុះវិញបានទេវៀរលែងតែអ្នកទទួលមិនព្រមបំពេញបន្ទុក ដែលអ្នកផ្ដាំឱ្យធ្វើ :

❖ ពាណិជ្ជករបានធ្វើប្រទានកម្មម៉ាស៊ីនភ្លើងដល់រដ្ឋាភិបាល ដើម្បីផ្គត់ផ្គង់អគ្គិសនីនៅតាមផ្លូវសាធារណៈ។

**ប្រជាធិបតេយ្យកម្ម** *ន.* ការធ្វើឱ្យមានប្រជាធិបតេយ្យឬការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ។

**ប្រព្រឹត្តិកម្ម** *ន.* ការព្យាបាលរោគ, ការរក្សាព្យាបាលជំងឺតាមវិធីពេទ្យ, ការតុបតែងឬពិនិត្យនូវរបស់អ្វីមួយ :

❖ លោកគ្រូពេទ្យម្នាក់បានធ្វើប្រព្រឹត្តិកម្មចំពោះអ្នកជំងឺទូទៅដោយឥតរើសមុខ។

**ប្រព្រឹត្តិការ** *ន.* កិច្ចការដែលធ្វើជានិច្ចជាធម្មតា, មុខងារ :

❖ ខ្ញុំមានប្រព្រឹត្តិការជាអ្នកនិពន្ធរឿងប្រលោមលោក។

**ប្រវេសន៍១** *ន.* ការទទួលយក, ការព្រមតាម, ការបានជាប់ឈ្មោះ :

❖ ពាក្យសុំផ្លាស់របស់ខ្ញុំបានទទួលនូវប្រវេសន៍ហើយ។

**ប្រវេសន៍២** *ន.* ការភៀសខ្លួនចូលទៅក្នុងទីណាមួយ, ការលបចូលទៅក្នុងប្រទេសណាមួយ :

❖ ជនជាតិបរទេសជាច្រើនម៉ឺននាក់បានធ្វើប្រវេសន៍ចូលមករស់នៅក្នុងប្រទេសកម្ពុជាយើង។

**ប្រសិទ្ធភាព** *ន.* ការធ្វើឱ្យសម្រេច, អំណាចដ៏ខ្លាំងក្លា :

❖ ធាតុបរមាណូមានប្រសិទ្ធភាពដ៏លើសលុប។

**ប្រាតិភោគ** *ន.* ការដាក់ទ្រព្យសម្បត្តិអ្វីមួយឬយកមនុស្សទីបីមកធ្វើជាធ្វូរធានាសម្រាប់ឱ្យម្ចាស់បំណុលងាយស្រួលក្នុងការប្រមូលឥណទេយ្យ (បំណុល) របស់ខ្លួនមកវិញ។

**ផលិតករ** *ន.* អ្នកបង្កើតផល, អ្នកធ្វើឱ្យបានសម្រេចជាផល :

❖ កសិករជាផលិតករសំខាន់ជាងគេបំផុតក្នុងលោក។

**ពលករ** *ន.* ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលស្ថិតនៅគ្រប់ដំណាក់កាលទេសន្តរប្រវេសន៍ការងារ ចាប់ពីពេលចុះកិច្ចសន្យាសេវារកការងារឱ្យធ្វើរហូតដល់ពេលធ្វើមាតុភូមិនិវត្តន៍។ ទន្ទឹមនឹងនេះក៏រាប់បញ្ចូលប្រជាពលរដ្ឋខ្មែរ

ទាំងពីរភេទដែលទៅធ្វើកម្មសិក្សាផង និងធ្វើការងារផងនៅបរទេសហើយមានកិច្ចសន្យាត្រឹមត្រូវ ដែលទទួលស្គាល់ដោយក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

**ពលភាព** *ន.* កម្លាំង :

❖ សូមឱ្យអក្សរសាស្ត្រខ្មែរមានពលភាពលើអក្សរសាស្ត្របរទេស។

**ពលសម្បទាន** *ន.* កម្លាំងដែលជំរុញបុគ្គលម្នាក់ឱ្យធ្វើអ្វីមួយ :

❖ ការស្រេកឃ្លានជាពលសម្បទានដ៏ពិសេសនិងខ្លាំងក្លាមួយ។

**ពហិការ១** *ន.* វិធីរបស់រដ្ឋមួយដែលផ្ដាច់ទំនាក់ទំនងខាងនយោបាយសេដ្ឋកិច្ចឬពាណិជ្ជកម្ម ដែលមានជាមួយនឹងរដ្ឋមួយទៀតឬជាមួយនឹងពលរដ្ឋនៃរដ្ឋនោះដើម្បីប្រឆាំងនឹងអំពើរបស់រដ្ឋនោះនិងដើម្បីជាការគាបសង្កត់ផង; អំពើរួមគ្នាមិនធ្វើកិច្ចការពាណិជ្ជកម្មជាមួយនឹងអ្នកណាម្នាក់ទៀត។

**ពហិការ២** *ន.* ការបញ្ឈប់គ្រប់ទំនាក់ទំនងជាមួយនឹងបុគ្គលក្រុមមនុស្សឬប្រទេសណាមួយដើម្បីគាបសង្កត់ឬសងសឹក។

**ពហុធា** *ន.* ផ្នែកច្រើន, ផ្លូវច្រើន (ពាក្យប្រើក្នុងអក្ខរលេខសាស្ត្រ) គេត្រូវតែរកចំណោទនេះតាមវិធីផ្សេង ព្រោះជាចំណោទពហុធា។

**ពហុនិយម១** *ន.* ជំនឿលើការអត់ឱននិងការទទួលស្គាល់នូវភាពខុសៗគ្នាជាពិសេសនៃគំនិត, តម្លៃ...។

**ពហុនិយម២** *ន.* សង្គមមួយបែបដែលមានវប្បធម៌ផ្សេងៗគ្នាអាចរក្សានូវទំនៀមទម្លាប់របស់ខ្លួនបាន។

**ពហុនិយម៣** *ន.* ជំនឿដែលអំណាចអាចចែករំលែករវាងគណបក្សមួយចំនួនបាន។

**ពហុន័យ** *ន.* ពាក្យដែលមានន័យច្រើន:

❖ ស្ពាប (ស្ពាបសត្វ), ស្ពាប (ស្ពាបយន្តហោះ), ស្ពាប (ផ្នែកម្ខាងនៃជួរទ័ព) ទាំងនេះជាពហុន័យនៃពាក្យស្ពាប។

**ពហុបច្ចេកទេស** *ន.* តិកនិកចម្រុះគ្រប់បែបយ៉ាង, វិជ្ជាពិសេសទូទៅ :

❖ អ្នកប្រាជ្ញខ្មែរយើងចេះនូវពហុបច្ចេកទេសខ្លះដែរ។

**ពហុបទី** *ន.* សត្វដែលមានជើងច្រើន :

❖ ម្រើមព្រះក្តី, ក្អែបក្តីឈ្មោះថាពហុបទី។

**ពហុភាគី** *ន.* ផ្នែកឬភាគីច្រើនដូចជា ក្នុងការពិភាក្សាឬការព្រមព្រៀង។ ពហុភាគីនិយម គឺជាទ្រឹស្តីដែលចែងថាប្រទេសនានាគួរធ្វើការងារការបរទេសរបស់ខ្លួនដោយព្រមទទួលការផ្តល់យោបល់ឬការចូលរួមពីប្រទេសឯទៀតៗ។

**ពហុភាព** *ន.* សំឡេងភាគច្រើនដោយប្រៀប។

**ពហុវប្បកម្ម** *ន.* ការដាំដំណាំចម្រុះច្រើននៅពេលតែមួយក្នុងតំបន់ណាមួយ។

**ពហុវប្បធម៌** *គុ.* ដែលមានពាក់ព័ន្ធទៅនឹងវប្បធម៌ខុសៗគ្នាជាច្រើន។

**ពាណិជ្ជកិច្ច** *ន.* លិខិតគតិយុត្តដែលស្ថិតនៅក្រោមវិធាននៃនីតិពាណិជ្ជកម្ម ដោយសារតែធម្មជាតិរបស់វាដូចជា ការទិញដើម្បីលក់ទៅវិញឬដោយសារ តែរូបភាពរបស់វា ដូចជារូបិយាណត្តិឬដោយសារតែឋានៈរបស់ម្ចាស់លិខិត ជាពាណិជ្ជករ :

❖ ការទិញរូបិយាណត្តិដើម្បីលក់វិញ, កិច្ចការជំនួញរបស់ពាណិជ្ជករ ជាពាណិជ្ជកិច្ច។

**ពាណិជ្ជនីយកម្ម** *ន.* ការធ្វើពាណិជ្ជកម្ម។ ការដែលផលិតកររៀបចំដាក់ លក់ផលិតផលថ្មីមួយនៅក្នុងទីផ្សារ។

**ពាណិជ្ជសញ្ញា** *ន.* សញ្ញាដែលបញ្ជាក់ដោយស្ថាប័នមានសមត្ថកិច្ចដើម្បី តាងឱ្យក្រុមហ៊ុនឬផលិតផលណាមួយ...។ ពាណិជ្ជសញ្ញា អាចជារូបភាព ពាក្យឬជាការបូកបញ្ចូលទាំងរូបភាពទាំងពាក្យ។

**ពិរុទ្ធជន១** *ន.* ជនដែលត្រូវគេប្ដឹងជាបទអាជ្ញាដោយចោទថា បានប្រព្រឹត្ត បទល្មើស ប៉ុន្តែអយ្យការទើបតែផ្ដើមចោទប្រកាន់ មិនទាន់ចោទប្រកាន់ជា ស្ថាពរនៅឡើយទេ។

**ពិរុទ្ធជន២** *ន.* ជនដែលចៅក្រមស៊ើបអង្កេតកំពុងឃុំខ្លួនជាបណ្ដោះអាសន្ន ដើម្បីស្រាវជ្រាវរកភស្តុតាង (ឧ. ឈ្មោះ **ក** កំពុងព្យាយាមលួចរត់ចេញពី កន្លែងកើតហេតុ (ឃាតកម្ម)។ ត្រូវនគរបាលយុត្តិធម៌ចាប់ឃាត់ខ្លួនបញ្ជូន មកអយ្យការៗក៏ធ្វើការផ្ដើមចោទប្រកាន់ (ហៅថាដីកាសន្និដ្ឋានបញ្ជូនរឿង

ឱ្យស៊ើបសួរ) ទៅចៅក្រមស៊ើបអង្កេតៗក៏បានចេញដីកាឃុំខ្លួនឈ្មោះ **ក** ជាបណ្ដោះអាសន្ន។ ឈ្មោះ **ក** នេះហៅថា **ពិរុទ្ធជន**។

**ពិរុទ្ធភាព** *ន.* ស្ថានភាពរបស់បុគ្គលដែលជាប់ពិរុទ្ធ គឺបុគ្គលដែលគេសន្និដ្ឋានថាបានប្រព្រឹត្តបទល្មើសដោយចេតនាឬអចេតនា។ ការបង្ហាញភស្ដុតាងពិរុទ្ធភាពរបស់បុគ្គលត្រូវចោទតាមធម្មតាជាបន្ទុករបស់ភាគីអ្នកប្ដឹងចោទ។

**ពិរុទ្ធហេតុ** *ន.* អំពើឬហេតុដែលអាចចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌនិងអាចចោទបាន :

- ❖ អំពើលួចទ្រព្យអ្នកដទៃជាពិរុទ្ធហេតុ។

**ព្យសនកម្ម** *ន.* ការខូចខាតឬការវិនាសអន្តរាយដល់រូបកាយក្ដី ដល់សម្ភារៈក្ដី ដល់ទឹកចិត្តក្ដី ដែលបណ្ដាលមកពីអំពើនៃអ្នកដទៃ។

**ព្យាកុលភាព** *ន.* ភាពច្រឡូកច្រឡំគ្នា, ការឥតរបៀបរៀបរយ។ មនុស្សម្នាក់ជាកូនបំណុលផង ជាម្ចាស់បំណុលផង នៃជនតែម្នាក់ហៅថា ព្យាកុលភាព :

- ❖ ប្រទេសណាមានពលរដ្ឋបានរំលោភច្បាប់ប្រទេសនោះតែងតែជួបប្រទះនូវព្យាកុលភាពជានិច្ច។

**ព្យាបាលិត** *ន.* ក្មេងដែលកំព្រាឪពុកម្ដាយ ហើយនៅក្រោមអាណាព្យាបាលរបស់ជនដទៃ។

**ព្យាសកម្ម** *ន.* វិធីសាស្ត្រនិងបទបញ្ញត្តិនៃការងារ ក្រិតខ្នាតឧបករណ៍មាត្រាសាស្ត្រ។

**ព្រឹទ្ធបុរស១** *ន.* នាយកមហាវិទ្យាល័យ :

❖ ព្រឹទ្ធបុរសមហាវិទ្យាល័យវិទ្យាសាស្ត្រ។

**ព្រឹទ្ធបុរស២** *ន.* សមាជិកដែលមានអតីតភាពយូរយារជាងគេក្នុងមុខងារខ្លះ :

❖ ព្រឹទ្ធបុរសនៃអង្គទូត។

**ព្រះរាជក្រឹត្យ** *ន.* សេចក្ដីសម្រេចរបស់ព្រះមហាក្សត្រ។

**ព្រះសង្វារ** *ន.* ត្រាសម្រាប់ស្ដេចសោយរាជ្យ :

❖ គេបានប្រថាប់ព្រះសង្វារលើព្រះហស្ដលេខារបស់ព្រះអង្គ។

**ភណ្ឌនិកេតន៍** *ន.* របស់ជាជំនួយការសិក្សា, របស់ទុកសម្រាប់ឱ្យសិស្សរៀន :

❖ នៅសាលាបឋមសិក្សាខ្លះពុំសូវមានភណ្ឌនិកេតន៍គ្រប់គ្រាន់ទេ។

**ភណ្ឌរថ** *ន.* រថផ្ទុកទំនិញផ្សេងៗ, ឡានធំសម្រាប់ដឹកអីវ៉ាន់ផ្សេងៗ :

❖ គេហាមមិនឱ្យពួកភណ្ឌរថបើកបរលើមហាវិថីព្រះបាទនរោត្ដម។

**ភតិបតី** *ន.* ម្ចាស់វត្ថុដែលជួលវត្ថុរបស់ខ្លួនឱ្យទៅគេ, ម្ចាស់ផ្ទះជួល។

**ភតិសន្យា** *ន.* កិច្ចសន្យាដែលប្ដេជ្ញាអំពីការជួលអចលនវត្ថុ :

❖ ទោះជាភតិបតីជាអ្នកជួលវត្ថុឱ្យគេស្លាប់ទៅក្ដីក៏ភតិសន្យាត្រូវតែនៅប្រតិបត្តិបានតទៅទៀត។ បើភតិកអ្នកជួលស្លាប់វិញ ភតិសន្យានឹងលែងយកមកប្រតិបត្តិបាន លុះត្រាតែទាយាទឬសន្តតិជនលែងចង់ជួលតទៅទៀត។

**ភតសន្យាបតី** *ន.* កម្មសិទ្ធិករដែលបានជួលចលនវត្ថុឬអចលនវត្ថុរបស់ខ្លួនឱ្យទៅមនុស្សម្នាក់ទៀតតាមរយៈកិច្ចសន្យាជួលមួយ :

❖ កិច្ចសន្យាជួលផ្ទះអាចត្រូវលុបចោលដោយភតិសន្យាបតីក្នុងករណីដែលអ្នកជួលមិនគោរពលក្ខខណ្ឌក្នុងកិច្ចសន្យា។

**ភារប្បទាយី** *ន.* អ្នកដែលប្រគល់កិច្ចការរបស់ខ្លួនឱ្យបុគ្គលផ្សេងទៀតដែលហៅថាអាណត្តិចាត់ចែងជំនួសខ្លួន, អ្នកប្រគល់សិទ្ធិ, អ្នកប្រគល់អាណត្តិ :

❖ ប្រធានអនុញ្ញាតកម្មករលក់សាំងជំនួសខ្លួនហៅថា ភារប្បទាយី។

**ភាសាវិទ្យា** *ន.* ការសិក្សាពីភាសាមនុស្សដោយពណ៌នាអំពីភាសានានានៅក្នុងពិភពលោក ប្រវត្តិភាសានិងមុខងាររបស់ភាសានឹងភាសា។ ម្យ៉ាងទៀតការសិក្សាដែលមានលក្ខណៈវិទ្យាសាស្ត្រទៅលើភាសានានាក្នុងលោក។ ភាសាវិទ្យាគេអាចសិក្សាពីសម្ព័ន្ធ ន័យ វចនសព្ទ ប្រវត្តិភាសា ...ដែលមានការសិក្សាទាំងនោះមានលក្ខណៈខុសពីវេយ្យាករណ៍។

**មច្ឆវប្បកម្ម** *ន.* ការចិញ្ចឹមត្រី :

❖ ប្រជាជនខ្មែរខ្លះធ្វើមច្ឆវប្បកម្ម។

**មច្ឆវប្បករ** *ន.* អ្នកចិញ្ចឹមត្រី :

❖ លោកសុខជាមច្ឆវប្បករគំរូក្នុងសហគមន៍របស់គាត់។

**មជ្ឈការ** *ន.* ប្រព័ន្ធរដ្ឋមួយដែលអំណាចធ្វើការសម្រេចផ្សេងៗស្ថិតនៅក្នុងដៃអាជ្ញាធរកំពូលឬកណ្ដាល, ការធ្វើឱ្យជាកណ្ដាល :

❖ អ្នកនយោបាយម្នាក់បានធ្វើមជ្ឈការនូវរឿងវិវាទនៃប្រជាជនឡាវ។

**មជ្ឈត្តកម្ម** *ន.* វិធីដោះស្រាយវិវាទដោយមជ្ឈត្តករហើយសេចក្ដីសម្រេចរបស់មជ្ឈត្តករចង់ឱ្យភាគីឱ្យអនុវត្តតាម។

**មជ្ឈត្តករ** *ន.* បុគ្គលដែលអាជ្ញាកណ្ដាលទទួលភារកិច្ចតាមកិច្ចសន្យាដើម្បីដោះស្រាយវិវាទតាមរយៈមជ្ឈត្តកម្ម។

**មជ្ឈត្តការ** *ន.* ការផ្សះផ្សាវិវាទដោយប្រើប្រាស់វេទិកាមជ្ឈត្តកម្មហើយអាចស្ថិតនៅក្នុងឬនៅក្រៅក្របខណ្ឌនៃការគ្រប់គ្រងរបស់ស្ថាប័នផ្សះផ្សាអចិន្ត្រៃយ៍។

**មជ្ឈត្តភាព** *ន.* ភាពជាអ្នកកណ្ដាល, ភាពជាអាជ្ញាកណ្ដាល :

❖ ចៅក្រមត្រូវតែមានមជ្ឈត្តភាពក្នុងការដោះស្រាយវិវាទ។

**មជ្ឈន្តិកៈ** *គុ.* ដែលអាចកែប្រែជារបៀបថ្មីបាន, ដែលអាចកាឡៃបាន :

❖ នយោបាយប្រទេសខ្លះជានយោបាយមជ្ឈន្តិកៈ។

**មណ្ឌលវារីចរណ៍** *ន.* មណ្ឌលសម្រាប់លេងទឹក, កន្លែងគេងូតទឹកកម្សាន្ត។

**មាត្រដ្ឋាន** *ន.* ការបំប្រួញដោយត្រឹមត្រូវតាមខ្នាត, ការប្រមាណតាមកំណត់រង្វាស់ខ្នាត :

❖ នៅក្នុងផែនទីនេះមានមាត្រដ្ឋាន១/១ 000។

**មាត្រសាស្ត្រ** *ន.* វិទ្យាសាស្ត្រនិងការគ្រប់គ្រងទម្ងន់និងរង្វាស់រង្វាល់។

**មូលទោស** *ន.* ទោសដាក់ពន្ធនាគារនិងទោសពិន័យ។

**មូលធននិយម** *ន.* លទ្ធិប្រកាន់យកប្រាក់ជាធំ, លទ្ធិនិយមតែអ្នកមាន :

❖ គេថាសហរដ្ឋអាមេរិកប្រកាន់នូវមូលធននិយម។

**មូលធននីយកម្ម១** *ន.* ការផ្ដល់ទុនទៅឱ្យក្រុមហ៊ុនណាមួយផ្សេងទៀត។

**មូលធននីយកម្ម២** *ន.* រចនាសម្ព័ន្ធនៃមូលធនរបស់ក្រុមហ៊ុនឬស្ថាប័នណាមួយដែលនៅក្នុងនោះ មូលធនត្រូវបានបែងចែកជាមូលធនបានមកពីភាគហ៊ុននិងមូលធនបានមកពីការខ្ចីបុល។ ជាបន្តទៅទៀតមូលធនដែលបានមកពីភាគហ៊ុនត្រូវបានបែងចែកទៅជាមូលធនភាគហ៊ុនធម្មតា និងភាគហ៊ុនអនុគ្រោះ។

**មូលធនិក** *ន.* អ្នកដែលកាន់លទ្ធិមូលធននិយម, អ្នកដែលប្រកាន់យកប្រាក់ជាធំ, នាយទុន :

❖ ជនជាតិបារាំងខ្លះជាមូលធនិកពេញទី។

**មូលបត្រ** *ន.* ឯកសារបញ្ជាក់ច្បាប់កម្មសិទ្ធិ (មូលបត្រកម្មសិទ្ធិ) ឬឥណទេយ្យផលបត្រពាណិជ្ជកម្ម បណ្ណរតនាគារ សញ្ញាបណ្ណភាគហ៊ុន។

**មូលបទ** *ន.* បុព្វហេតុដែលគេរៀបរាប់នៅខាងមុខច្បាប់ឬប្រកាសណាមួយ :

❖ សេចក្ដីទាំងអស់នេះជាមូលបទរបស់ក្រសួងសង្គមកិច្ច។

**មូលប្បទានបត្រ** *ន.* ក្រដាសឬលិខិតសម្គាល់សម្រាប់បើកប្រាក់ពីធនាគារ, ក្រដាសជាតំណាងក្រដាសប្រាក់របស់ធនាគារ :

❖ ធនាគារបានឱ្យមូលប្បទានបត្រមួយសន្លឹកដល់ខ្ញុំដែលមានតម្លៃជាប្រាក់៥លានរៀល។

**មូលរូប** ៖ អ្វីជាគំរូដែលទុកសម្រាប់ធ្វើការ, រូបគំរូដែលគេត្រូវធ្វើតាម :

❖ នៅការិយាល័យសាលាក្រុងភ្នំពេញមានតាំងនូវមូលរូបជាច្រើន។

**មូលសាស្ត្រ** ៖ គោលការណ៍, វិធានទូលំទូលាយឬទ្រឹស្តីដែលផ្តល់នូវមូលដ្ឋាន ឬប្រភពដើមគំនិតដើមដែលគួរសន្និដ្ឋានថាជាមូលដ្ឋានឬច្បាប់។

**មោឃកម្មការ** ៖ ការលុបចោលជាប្រតិសកម្ម ពោលគឺការលុបចោលដែលមានអានុភាពថយក្រោយនូវលិខិតគតិយុត្តណាមួយ ដោយមកពីការមិនគោរពតាមនូវលក្ខខណ្ឌនៃការបង្កើតលិខិតនោះ។ មោឃកម្មការនេះជូនកាលមានអានុភាព លើកលែងគូភាគីឱ្យផុតពីការអនុវត្តនូវកាតព្វកិច្ចទាំងអស់ ជួនកាលបង្ខំឱ្យគូភាគីប្រគល់សងគ្នាទៅវិញទៅមកនូវអ្វីៗដែលខ្លួនបានទទួល។

**មោឃភាព១** ៖ សភាពនៃលិខិតគតិយុត្តត្រឹមត្រូវតាមច្បាប់ណាមួយដែលក្លាយទៅជាគ្មានប្រសិទ្ធភាព ដោយសារមានហេតុការណ៍មួយបានកើតឡើងក្រោយពេលបានបង្កើតលិខិតនោះ :

❖ មតកសាសន៍បណ្តាំអ្នកដែលស្លាប់ទៅហើយ ត្រូវចាត់ទុកជាគ្មានតម្លៃបើអច្ចយទានលាភី គឺអ្នកទទួលអំណោយពីអ្នកដែលស្លាប់ទៅបានស្លាប់មុនអ្នកធ្វើមតកសាសន៍ ពោលគឺជាអ្នកផ្តល់មតកសាសន៍នេះឈ្មោះហៅថា មោឃភាពមតកសាសន៍។

**មោឃភាព២** ៖ ទណ្ឌកម្មដែលប្រកាសដោយចៅក្រមលុបបំបាត់ចោលជាប្រតិសកម្មនូវលិខិតគតិយុត្តណាដែលបានបំពេញតាមលក្ខខណ្ឌច្បាប់កំណត់ :

❖ មោឃភាពនៃកិច្ចសន្យាដោយអសមត្ថភាពនៃភាគីណាម្នាក់។

**យតនភាព** *ន.* ភាពជាអ្នកខំខ្នះខ្នែង, ភាពរៀសរវៃ :

❖ អ្នកប្រាជ្ញមានយតិភាពគួរឱ្យសរសើរ។

**យថាទស្សន៍** *ន.* គំនូរតាងបែបធរណីមាត្រអំពីសំណង់ឬសំណុំសំណង់តាមយថាហេតុក្នុងបរិបទរបស់វា ដូចដែលវាបានប្រត្យក្សនឹងភ្នែករបស់អ្នកសង្កេត។

**យថាភាព** *ន.* សភាវៈនៃការពិត, ភាពត្រឹមត្រូវតាមច្បាប់ :

❖ ការតវ៉ារបស់ពលរដ្ឋឱ្យអ្នកដឹកនាំដោះស្រាយវិបត្តិជា យថាភាព។

**យថាន័យ** *ន.* ន័យមិនប្រែប្រួល, ន័យជាមូលដ្ឋានរបស់ពាក្យមួយដែលមិនយោលទៅតាមបរិបទ :

❖ យថាន័យរបស់ពាក្យ (យប់) គឺរយៈពេលបន្ទាប់ពីពេលថ្ងៃ ចាប់ពីពេលថ្ងៃលិចដល់ពេលថ្ងៃរះ។

**យថាភូតកម្ម** *ន.* ការបញ្ជាក់ដោយសារការី។

**យន្តការ** *ន.* បែបផែននៃការប្រព្រឹត្តទៅនៃអ្វីមួយដែលគេប្រៀបប្រដូចទៅនឹងគ្រឿងម៉ាស៊ីន :

❖ យន្តការទីផ្សារសេរី គឺជាកត្តាចាំបាច់សម្រាប់ប្រទេសកម្ពុជាដើម្បីប្រកួតប្រជែងសេដ្ឋកិច្ចជាមួយនឹងប្រទេសជិតខាង។

**យន្តការស្វ័យនិយតកម្ម** *ន.* វិធីសាស្ត្រសម្រាប់ធ្វើឱ្យប្រព័ន្ធមួយមានដំណើរការទៅបានដោយសារមានការកែតម្រូវដោយខ្លួនឯងផ្ទាល់។

**យន្តូបនីយកម្ម** *ន.* ការប្រើប្រាស់គ្រឿងយន្តជំនួសកម្លាំងមនុស្សឬសត្វ, ការដាក់នូវគ្រឿងម៉ាស៊ីនឬប្រព័ន្ធម៉ាស៊ីនជំនួសកម្មករ ចំពោះប្រត្តិបត្តិការប្រើកម្លាំងកាយលំបាកៗ រីឯការបញ្ជាទៅលើម៉ាស៊ីននិងការថែទាំជួសជុលក្លាយជាមុខងារចម្បងរបស់កម្មករទៅវិញ។ យន្តូបនីយកម្មធ្វើឡើងក្នុងគោលបំណងក្នុងការលើកកម្ពស់នូវផលិតភាពការងារ និងប្រសិទ្ធភាពនៃផលិតកម្ម។ យន្តូបនីយកម្មសម្រេចបាននូវកម្មវត្ថុសង្គមជាមូលដ្ឋានដូចជាការសម្រាលការងារនិងកែលម្អលក្ខខណ្ឌការងាររបស់កម្មករ លើកតម្កើងកម្រិតវប្បធម៌និងបច្ចេកទេសបង្កើនប្រាក់បៀវត្ស បង្កើនភាពងាយស្រួលផ្នែកសម្ភារៈ និងជាទូទៅលុបបំបាត់ភាពខុសគ្នាសំខាន់រវាងពលកម្មខួរក្បាលនិងពលកម្មប្រើកម្លាំងកាយ។

**តតយុត្ត** *គុ.* ដែលទាក់ទងនឹងច្បាប់។

**យុត្តាធិការ** *ន.* ការបំពេញសមត្ថកិច្ចផ្នែកតុលាការឬសិទ្ធិក្នុងការប្រើអំណាចផ្លូវការដើម្បីធ្វើសេចក្តីសម្រេចចិត្តតាមផ្លូវច្បាប់។ រង្វង់ព្រំដែនអំណាចខាងតុលាការឬរដ្ឋបាល (ក្នុងការគ្រប់គ្រងដែនដីឬក្នុងតួនាទី)។

**យុត្តិធម៌អន្តរកាល** *ន.* យុទ្ធសាស្ត្រស្វែងរកគតិយុត្តនិងការទទួលខុសត្រូវប្រើឡើងដើម្បីដោះស្រាយបញ្ហាអតីតកាល, ការអនុវត្តក្នុងរយៈកាលក្រោយ

ទំនាស់ឬក្រោយរបបផ្តាច់ការណាមួយ ក្នុងគោលបំណងកសាងសង្គមមួយប្រកបដោយយុត្តិធម៌ប្រជាធិបតេយ្យនិងសន្តិភាព។

**យុត្តិនិសេធ** *ន.* យុត្តិនិសេធជាប្រភេទបទល្មើសមួយដែលប្រព្រឹត្តដោយចៅក្រមនៅពេលបំពេញមុខងារជាសាធារណៈ។ កាលដែលចៅក្រមប្រកែកមិនព្រមជំនុំជម្រះរកយុត្តិធម៌ឱ្យគូភាគីក្តី ទោះបីបើមានការឈ្លៀសពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក៏ដោយ។

**យុត្តិសាស្ត្រ** *ន.* វិធីសាស្ត្រខាងច្បាប់, ការសិក្សាអំពីច្បាប់និងទស្សនវិជ្ជាខាងច្បាប់, វិធីដែលខាងសាលាជម្រះក្តីធ្លាប់បានជំនុំជម្រះក្តីឬសម្រេចកន្លងទៅទម្លាប់ដែលធ្វើដោយសាលាជម្រះក្តី ដើម្បីអនុវត្តនូវវិធានណាមួយតាមរបៀបមួយពិតប្រាកដ, ការដោះស្រាយស្របគ្នាឬសេចក្តីសម្រេចប្រហាក់ប្រហែលគ្នារបស់សាលាជម្រះក្តីលើបញ្ហាច្បាប់។

**យុទ្ធនីតិ** *ន.* ក្បួនច្បាប់ខាងវិធីច្បាំង, ច្បាប់ដែលគេប្រកាសឡើងក្នុងគ្រាដែលប្រទេសមានសង្គ្រាម :

- ❖ នាយទាហានខ្លះពុំស្ទូវចេះនូវយុទ្ធនីតិឡើយ។

**យោធពលខេមរភូមិន្ទ** *ន.* កងកម្លាំងទាហានរបស់ខ្មែរដែលស្ថិតនៅជុំវិញព្រះរាជាណាចក្រកម្ពុជា :

- ❖ កងយោធពលខេមរភូមិន្ទមានទាហានស្មោះជាងរាប។

**យោធាប្រតព័ន្ធ** *ន.* ការចូលចិត្តក្នុងភាពជាទាហាន, សេចក្ដីស្ម័គ្រខាងធ្វើជាទាហាន :

❖ ប្រជាជនខ្មែរគួរបង្កើតយោធាប្រតិព័ន្ធគ្រប់គ្នាកាលបើមានសង្គ្រាម។

**យោពូនកម្ម** *ន.* ភាពមើលទៅឃើញនៅក្មេង, ការធ្វើឱ្យនៅក្មេង, ការធ្វើឱ្យក្មេង :

❖ អ្នកប្រាជ្ញវិទ្យាសាស្ត្រសព្វថ្ងៃនេះកំពុងរិះរកនូវវិធីធ្វើយោពូនកម្មដល់មនុស្សទូទៅ។

**រង្គដ្ឋាន** *ន.* បន្ទប់ធំក្នុងសកលវិទ្យាល័យឬសាលារៀនធំដែលមានធ្វើជាថ្នាក់ៗសម្រាប់អង្គុយស្ដាប់ឧទ្ទេសរបស់សាស្ត្រាចារ្យឬគ្រូបង្រៀនរួម។

**រង្គមណ្ឌល** *ន.* កន្លែងរបាំ, កន្លែងច្រៀងរាំ, មន្ទីរពិសោធន៍ដែលមានថ្នាក់អង្គុយជាថ្នាក់ :

❖ នៅក្នុងវិទ្យាល័យស៊ីសុវត្ថិមានរង្គមណ្ឌលពីរកន្លែង។

**រចនាបថ១** *ន.* បែបបទឬរបៀបពិសេសនៃបុគ្គលម្នាក់ៗដែលសម្ដែងឡើងជាទូទៅក្នុងការនិពន្ធក្នុងការត្រាប់តាមរចនាបថរបស់អ្នកនិពន្ធណាមួយ។

**រចនាបថ២** *ន.* ទម្រង់ភាសាសម្រាប់សកម្មភាពមជ្ឈដ្ឋានឬក្នុងក្រុមសង្គមណាមួយ :

❖ រចនាបថរដ្ឋបាល។

**រចនាបថ៣** *ន.* ទឹកដៃសិល្បៈសម្រាប់បង្ហាញឱ្យឃើញពីលក្ខណៈផ្ទាល់របស់សិល្បករសម័យកាលឬសម្រាប់ប្រទេសណាមួយ :

❖ រចនាបថភ្នំដា

❖ រចនាបថរ៉ូម៉ាំង។

**រចនាសម្ព័ន្ធ** *ន.* រូបរាង, គ្រឿងការកសាង, អ្វីដែលរចនារួមគ្នា :

❖ អ្វីដែលប្រទាក់ប្រទងគ្នាក៏គេហៅថា រចនាសម្ព័ន្ធ ដែរ។

**រដ្ឋទេយ្យ** *ន.* ភាសីសម្រាប់ប្រទេស :

❖ សូមបងរដ្ឋទេយ្យឱ្យអ្នកទារភាសីខ្លះៗផង។

**រដ្ឋទេយ្យករ** *ន.* អ្នកទារពន្ធភាសី, មេផ្សារ :

❖ ដោយសារគាត់ធ្វើជារដ្ឋទេយ្យករទើបបានជាគាត់មានផ្ទះថ្មនៅ។

**រដ្ឋាធិសី** *ន.* ក្សត្រគ្រងរាជ្យ, ស្ដេចដែលកំពុងស្ថិតនៅក្នុងរាជ្យសម្បត្តិ។

**រតនាភរណៈ** *ន.* គ្រឿងអម្ពរ, ដាំត្បូង។

**រសមោចនា** *ន.* ការបញ្ចេញមក, ការបន្ទោបង់ចោល :

❖ គ្រូពេទ្យបានធ្វើរសមោចនាដល់អ្នកជំងឺដើម្បីពិសោធមើល។

**រុក្ខវប្បកម្ម** *ន.* ការបណ្ដុះពូជឈើ, ការដាំឬផ្សាំកូនឈើផ្សេងៗ, ដំណាំដើមឈើឬកូនឈើដើម្បីប្រើប្រាស់ឬក៏លម្អ។ រុក្ខវប្បកម្មសម្ដែងឡើងដោយសួនឈើ :

❖ ប្រជាជនកម្ពុជាភាគច្រើននៅសម័យបច្ចុប្បន្នបានបង្កើនប្រាក់ចំណូលរបស់ខ្លួនតាមរយៈវិស័យរុក្ខវប្បកម្មយ៉ាងផុសផុល។

**រុក្ខវប្បករ** *ន.* អ្នកបណ្ដុះកូនឈើ :

❖ មនុស្សទូទៅចូលចិត្តរុក្ខវប្បករនៅក្នុងពិភពលោក។

**រូបបរិវត្តន៍** *ន.* ការផ្លាស់ប្ដូររូប, ការប្រែកាយនៃរូប :

❖ ដង្កូវមួយនេះកំពុងធ្វើរូបបរិវត្តន៍ដើម្បីឱ្យទៅជាមេអំបៅ។

**រូបវន្តបុគ្គល** *ន.* មនុស្សដែលមានកម្លាំងស្វាហាប់, បុគ្គលដែលបង្ហាញជារូបរាង, ជនដែលមានរូបជាសម្អាង។

**រូបិយវត្ថុ** *ន.* ប្រាក់សម្រាប់ចាយ, ក្រដាសប្រាក់សម្រាប់ចាយ :

❖ ប្រសិនបើខ្វះរូបិយវត្ថុហើយយើងនឹងធ្វើអ្វីក៏មិនសូវបានល្អ។

**រូបិយាណត្តិ** *ន.* ផលបត្រពាណិជ្ជកម្មដែលឥណទាយក (ម្ចាស់បំណុល បញ្ជាទៅឥណាយិក (កូនបំណុល) ឱ្យបង់ប្រាក់ត្រឹមត្រូវគ្រប់ចំនួនទៅតាមឥណប្រតិទាន (ថ្លៃសងបំណុល) ជូនទៅបុគ្គលណាមួយ។

**លក្ខណៈវិនិច្ឆ័យ** *ន.* បែបបទឬគោលការណ៍ដែលគេប្រើប្រាស់សម្រាប់ធ្វើការវិនិច្ឆ័យ ការវាយតម្លៃ ឬធ្វើសេចក្ដីសម្រេចចិត្ត។

**លទ្ធកម្ម១** *ន.* ការរើសបុគ្គលម្នាក់ក្លាយជាអ្នកទទួលអគ្រានុកូលដ្ឋានថ្មី។ ការបានកើតឡើងជាភោគីឬជាកម្មសិទ្ធិករនៃវត្ថុណាមួយ ដោយការងាររបស់ខ្លួនក្ដី ដោយដូរក្ដី ដោយសន្ធិកម្មក្ដី ដោយទិញក្ដី។

**លទ្ធកម្ម២** *ន.* ការទទួលនឹងរៀបចំដំណើរការដេញថ្លៃជាសាធារណៈនូវទំនិញ ឬការដ្ឋានសំណង់។ ការទទួលវត្ថុអ្វីមួយដោយលំបាកនិងដោយប្រុងប្រយ័ត្ន។

**លទ្ធករ** *ន.* អ្នកដែលទទួលបាននូវកម្មសិទ្ធិឬសិទ្ធិណាមួយពីកម្មសិទ្ធិករឬម្ចាស់កម្មសិទ្ធិដែលគេបង្វែរមកឱ្យខ្លួនដោយចេតនាឬតាមច្បាប់។

**លទ្ធជន** *ន.* ជនដែលក្លាយជាម្ចាស់លើកម្មសិទ្ធិអ្វីមួយដោយការទិញដូរប្តូរគ្នាឬដោយការបន្តមត៌ក។

**លទ្ធពន្ធ** *ន.* ការគ្រប, ការពាស, ការបិទមកវិញ :

❖ គេធ្វើលទ្ធពន្ធលើហិបប្រាក់មួយដើម្បីទុកពិនិត្យទៅថ្ងៃក្រោយ។

**លទ្ធិបដិទាន** *ន.* ផ្នែកធានារ៉ាប់រង។

**លាភការ** *ន.* រង្វាន់, ឈ្នួលនៃការងារ, ប្រាក់ជាសគុណនៃកិច្ចការអ្វីមួយ។

**លោកនិត** *ន.* ច្បាប់សម្រាប់លោក, ច្បាប់សម្រាប់ប្រទេស, ច្បាប់សម្រាប់ធ្វើជាពលរដ្ឋល្អ :

❖ ដើម្បីកែទម្រង់ចរិយាសិស្សឱ្យទៅជាពលរដ្ឋល្អទៅថ្ងៃក្រោយគេបង្រៀននូវវិជ្ជាលោកនីតិជាបែបថ្មី។

**លោហិតម្ភ:** *ន.* ធាតុទឹកដែលមាននៅក្នុងអាការៈនៃខ្លួនមនុស្សយើង បំពង់ឈាមដែលហូរចុះឡើង :

❖ បើអ្នកចង់ដឹងថា តើលោហិតម្ភៈនៅក្នុងខ្លួនមនុស្សយើងដូចម្តេចនោះសូមមើលក្បួនវិទ្យាសាស្ត្រ។

**លោហិតវិទ្យា** *ន.* វិទ្យាសាស្ត្រដែលសិក្សាពីឈាមនិងកំណកំណើតនៃជាលិកាឈាម។

**លោហិតសិទ្ធិ** *ន.* សិទ្ធិតាមលោហិត, សិទ្ធិទទួលបានសញ្ជាតិតាមលោហិត។

**លោហៈស្វាប្បការកម្ម** *ន.* សំណុំមធ្យោបាយនិងបច្ចេកទេសជីកយករ៉ែលោហធាតុដោយច្រោះ ចម្រាញ់ ស្លតិចដើម្បីផលិតលោហធាតុសុទ្ធឬសំលោហៈ។

**វចនវិទ្យា** *ន.* ផ្នែកមួយនៃភាសាវិទ្យាដែលសិក្សាអំពីវាក្យសព្ទ ប្រវត្តិពាក្យនិងមុខងាររបស់ពាក្យ។

**វដកបក្សី** *ន.* សត្វស្លាបជើងខ្លីហើយចូលចិត្តលោត :

❖ សត្វចាប, សារិកាកែវ, គ្រលីងគ្រលោងជាដើមឈ្មោះថា វដកបក្សី។

**វាក្យខណ្ឌ** *ន.* សង្កាត់របស់ពាក្យ :

❖ ក្នុងប្រយោគនេះមាន២វាក្យខណ្ឌ។

**វាតបាល** *ន.* បង្អួច :

❖ ព្រះរាជាទ្រង់ប្រថាប់នៅក្បែរវាតបាលនៃព្រះរាជដំណាក់។

**វាយនភណ្ឌ** *ន.* គ្រឿងតម្បាញ, របស់ដែលកើតមកពីគ្រឿងតម្បាញ :

❖ ក្នុងខែនេះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពុំបើករូបិយបណ្ណឱ្យបញ្ជាទិញនូវវាយនភណ្ឌពីប្រទេសក្រៅឡើយ។

**វាយនភាព** *ន.* តំណាក់តំណែង (របៀបផ្គុំ) នៃក្រុមភាគល្អិតផ្សេងៗរបស់ដី (ដីឥដ្ឋ ល្បាប់ ហ្លត់ខ្សាច់ ក្រួសល្អិត)។

**វារីចរណ៍** *ន.* ការធ្វើដំណើរតាមផ្លូវទឹក :

❖ ថ្ងៃអាទិត្យនេះខ្ញុំនឹងធ្វើវារីចរណ៍កម្សាន្តតាមផ្ទៃទន្លេសាប។

**វារីវប្បកម្ម** *ន.* ការចិញ្ចឹមត្រីសិប្បីសត្វនិងការដាំរុក្ខជាតិទឹកខ្លះនៅក្នុងទឹកសាបឬទឹកប្រៃក្រោមលក្ខខណ្ឌត្រួតពិនិត្យ និងការគ្រប់គ្រងកំណត់មួយ។ វារីវប្បកម្មអាចប្រព្រឹត្តទៅនៅក្នុងស្រះ អាង វាលស្រែ...។

**វារីសាស្ត្រ** *ន.* វិជ្ជាខាងទឹក, ក្បួនរៀនពីធាតុទឹក :

❖ អ្នកឧតុនិយមម្នាក់កំពុងសិក្សានូវវារីសាស្ត្រ។

**វិកតិកាភេទ** *ន.* ការរំលាយចោលនូវលិខិតមួយដូចជាកិច្ចសន្យាតាមអំណាចនៃសេចក្តីសម្រេចរបស់តុលាការ ធ្វើឱ្យលិខិតនោះលែងមានអានុភាពអនុវត្តទៅថ្ងៃអនាគត :

❖ វិកតិកាភេទកិច្ចសន្យាលក់។

**វិការដ្ឋាន** *ន.* អាការៈកម្រើកដៃជើង មុខមាត់ដើម្បីឱ្យគេឃើញ :

❖ សិស្សវិទ្យាល័យស៊ីសុវត្ថិបានសម្តែងវិការដ្ឋានគួរឱ្យចង់ទស្សនា។

**វិក្រឹតការ** *ន.* ការបណ្តុះបណ្តាលលើមន្ត្រីនៅក្នុងមុខតំណែងដើម្បីបង្កើនសមត្ថភាពឱ្យកាន់តែជ្រៅជ្រះថែមទៀត។

**វិខនិជកម្ម** *ន.* ការដកនូវអង្គធាតុខនិជឬអំបិលខនិជចេញពីទឹកឬអង្គធាតុវារនានា។

**វិតណានី** *ន.* ការជម្រះបញ្ចើទឹកប្រាក់យ៉ាងដាច់ស្រេច :

❖ គាត់បានឱ្យធនាគារខ្មែរធ្វើវិគណនីក្នុងឆ្នាំ២០១៤។

**វិចិត្រកម្ម** *ន.* ការផាត់ថ្នាំពណ៌, ការលាបពណ៌ :

❖ ជាងស៊ុយពូកែធ្វើវិចិត្រកម្មលើសគេទាំងអស់។

**វិចិត្រកម្មាល័យ** *ន.* ទីតម្កល់ទុកឬតាំងរូបគំនូរផាត់ពណ៌ :

❖ នៅក្នុងក្រសួងឃោសនាការមានវិចិត្រកម្មាល័យបីកន្លែង។

**វិចិត្រសាលជំនួញ** *ន.* លម្អបើកសម្រាប់ដើរចេញចូលក្នុងការងារជួញដូរ។

**វិចិត្រសិល្ប៍** *ន.* សិល្បៈដ៏ល្អឆើតជំនាញយ៉ាងវិចិត្រ :

❖ គេភ្ជាប់ផ្នែកវិចិត្រសិល្ប៍នឹងផ្នែកសិក្សាធិការ។

**វិជ្ជាថានចក្ខុរោគ** *ន.* កន្លែងពិនិត្យឬសិក្សាអំពីជំងឺភ្នែក :

❖ គ្រូពេទ្យឫទ្ធិនៅធ្វើការនៅវិជ្ជាថានចក្ខុរោគ។

**វិជ្ជាថានជីវសាស្ត្រ** *ន.* កន្លែងពិនិត្យឬសិក្សាអំពីសត្វមានជីវិត :

❖ វិជ្ជាថានជីវសាស្ត្រតាំងនៅក្រសួងកសិកម្ម។

**វិជ្ជាថានបដិបក្ខឧម្មត្តករោគ** *ន.* កន្លែងសិក្សាអំពីគ្រឿងការពារជំងឺឆ្កួត :

❖ វិជ្ជាថានបដិបក្ខឧម្មត្តករោគ ស្ថិតនៅមហាវិថីបារាំងសែសក្រោយមន្ទីរពេទ្យព្រះកេតុមាលា។

**វិជ្ជាថានអភិរក្ស** *ន.* កន្លែងសម្រាប់ថែទាំអ្វីផ្សេងៗ, កន្លែងសម្រាប់តម្កល់ទុកនូវអ្វីនីមួយ :

❖ នៅមន្ទីរពេទ្យព្រះកេតុមាលាមានវិជ្ជាថានអភិរក្សមួយកន្លែង។

**វិជ្ជាយត្តភាព** *ន.* ពាក្យបច្ចេកទេសពិសេសសម្រាប់សិល្បៈខាងវិទ្យាសាស្ត្រសារព័ន :

❖ ពាក្យតិកនិកជាវិជ្ជាយត្តភាពសម្រាប់ពួកអ្នកវិទ្យាសាស្ត្រ។

**វិជ្ឈកោណ** *ន.* ខ្សែពុះកាត់ពីម្ខាងទៅម្ខាង :

❖ ផ្ទៃដីជាមណ្ឌលមួយកន្លែងនេះមានវិជ្ឈកោណ៥០ម៉ែត្រ។

**វិតកម្មធនសាធារណៈ** *ន.* ការឆ្លៀតយកប្រាក់សាធារណៈប្រើខុសច្បាប់។

**វិធវកាល** *ន.* ពេលនៅទំនេរ, ភាពជាអ្នកពោះម៉ាយ, ភាពជាអ្នកមេម៉ាយ :

❖ ពេលពូខ្ញុំស្លាប់ទៅរាជការបានចេញសំបុត្រវិធវកាលឱ្យប្រពន្ធគាត់។

**វិធវភាព** *ន.* ភាពទំនេរគ្មានប្ដី, ភាពមេម៉ាយ។

**វិធីសារុ** *ន.* របៀបការងារ, បែបបទ, របៀបរៀបរយ :

❖ អ្នកណាចេះនូវវិធីសារុពិតប្រាកដគេនឹងឱ្យកាន់ការក្រសួងនេះ។

**វិនិច្ឆយនីយ** *ន.* ជនដែលត្រូវតុលាការជំនុំជម្រះឱ្យ, អ្នកដែលត្រូវឆ្លើយដោះសាខ្លួនចំពោះមុខចៅក្រម, អ្នកមានសិទ្ធិឱ្យតុលាការជំនុំជម្រះ។

**វិប្រជា** *ន.* ពួករាស្ត្រផ្សេងៗ, ចំណោមរាស្ត្រប្លែកៗគ្នាជាច្រើន :

❖ នៅក្នុងចំណោមមនុស្សដែលបានមកកាន់ទីប្រជុំនេះគេឃើញមានវិប្រជាជាច្រើន។

**វិភាគភណ្ឌ** *ន.* គ្រឿងប្រដាប់សម្រាប់ធ្វើការវិភាគ, គ្រឿងប្រដាប់សម្រាប់វែកញែកឱ្យជាក់ច្បាស់អំពីអ្វីមួយ :

❖ ប្រដាប់ផ្ទុះក្ដី ប្រដាប់ពង្រីកក្ដី គឺជាវិភាគភណ្ឌសម្រាប់គ្រូពេទ្យ។

**ខនាគសហសម្ព័ន្ធ** *ន.* ការវិភាគទៅលើកត្តាផ្សេងៗដែលមានការទាក់ទងគ្នាទៅវិញទៅមក :

❖ ការវិភាគដើម្បីរកមើលកត្តាដែលនាំឱ្យមានការប្រែប្រួលជាមុនពេលមានបម្រែបម្រួលផលិតផល។

**ខនាគី** *គុ.* ដែលវែកញែកដោយជាក់ច្បាស់ :

❖ គេចាត់ទុកនៅថ្នាំអាស្ពិរីននេះថាជាឱសថវិភាគីក៏បាន។

**ខនាជន៍** *ន.* អ្វីៗដែលឧបត្ថម្ភឬផ្ដល់ឱ្យជាទៀងទាត់ (ភាគច្រើនការឧបត្ថម្ភជាប្រាក់), ប្រាក់កម្រៃ, ស្បួយ :

❖ គេនឹងឱ្យវិភាជន៍ដល់ខ្ញុំនៅចុងខែមីនានេះ។

**ខនេឧ** *ន.* ការកែប្រែសារជាតិនៃវត្ថុណាមួយឱ្យខុសចាកន័យ ចាកតម្លៃ ចាកទីដៅដើមរបស់វា ដើម្បីឱ្យមានព្យសនកម្មណាមួយ។

**ខមជ្ឈការ** *ន.* ការធ្វើឱ្យឃ្លាតចេញពីទីកណ្ដាល :

❖ គេចោទថាប្រទេសបែលហ្សិកបានធ្វើវិមជ្ឈការចំពោះនយោបាយនៅប្រទេសកុងហ្គោ។ (សេដ្ឋកិច្ចនិងច្បាប់) ប្រព័ន្ធរដ្ឋបាលដែលអនុញ្ញាតឱ្យសមូហភាពរបស់ក្រុមមនុស្ស (វិមជ្ឈការដែនដី) ឬផ្នែកនៃកិច្ចការមួយ (វិមជ្ឈការបច្ចេកទេស) គ្រប់គ្រងដោយខ្លួនឯង (ដោយបោះឆ្នោតជ្រើសរើសអ្នក

គ្រប់គ្រង) ក្រោមការត្រួតពិនិត្យរបស់រដ្ឋដោយផ្តល់ឱ្យនូវបុគ្គលិកលក្ខណៈគតិយុត្ត អំណាចផ្ទាល់ខ្លួន និងធនធាន។

**ទំហំត្រ** *ន.* វិសាលភាព (ទំហំ) នៃអង្គធាតុមួយទៅតាមទិសដែលបានពិនិត្យ ដូចជា បណ្តោយ ទទឹង កម្ពស់ កម្រាស់ វិជ្ឈមាត្រ...។

**ទំហំត្រអតបរមា** *ន.* វិមាត្រតូចបំផុតដែលគេអនុញ្ញាតក្នុងការផលិតគ្រឿងមួយចំនួន។

**ទំរុទ្ធទាន** *ន.* លិខិតយថាភូតដែលធ្វើឡើងដោយអាជ្ញាសាលាឬដោយសារការីតាមពាក្យស្នើសុំរបស់គាហកៈនៃពាណិជ្ជបត្រដើម្បីកត់សម្គាល់ជាផ្លូវការ :

- ✍ ការមិនព្រមទទួលរូបិយាណត្តិដោយមហារិត
- ✍ ការមិនបង់ប្រាក់នូវពេលផុតរយៈពេលនៃពាណិជ្ជបត្រ។

**ទំលីនភាព** *ន.* ភាពដែលអាចមានជាសាច់ប្រាក់សម្រាប់ទូទាត់ប្តូរផ្តោះបានភ្លាមៗ, ភាពអាចជម្រះបញ្ជីបាន។

**ទំសមតា** *ន.* ការបាត់បង់សមតា, ការបាត់បង់ស្ថិរភាព។

**ទំសមរូបសព្ទ** *ន.* បម្លាស់ប្តូររបស់រូបសព្ទតាដែលអាស្រ័យទៅនឹងបរិបទ។

**ទំសមសទ្ទ** *ន.* បម្លាស់ប្តូរសូររបស់សទ្ទតាតែមួយក្នុងពេលដែលវាផ្សំជាមួយនឹងសទ្ទដទៃទៀតក្នុងទីតាំងខុសគ្នា។

**វិសមអក្ខរៈ** *ន.* រូបតំណាងរូបីឬរូបតំណាងរូបីមួយក្នុងចំណោមរូបតំណាងរូបីរបស់អក្ខរតា។ លក្ខណៈរូបរបស់វិសមអក្ខរៈអាស្រ័យទៅនឹងអ្វីដែលនៅជុំវិញវា។

**វិសមានកម្ម** *ន.* បម្រែបម្រួលសូរដើម្បីសង្កត់ធ្ងន់ឬបង្កើតឱ្យមានភាពខុសគ្នារវាងសទ្ទតាពីរដែលស្រដៀងមិនដូចគ្នា។

**វិសមិត** *ន.* របស់អ្វីពីរដែលមិនចុះសម្រុងគ្នានៅពេលណាដែលការរួមរស់ជាមួយគ្នាបង្កឱ្យមានការលំបាកទាំងសងខាងដូចជា បង្កើតឱ្យមានទំនាស់ជាដើម។ ការចុះសម្រុងគឺជាឧបករណ៍ម្យ៉ាងសម្រាប់វិភាគទំនាស់ដោយផ្តោតទៅលើគោលដៅឬអាកប្បកិរិយា ដែលមិនចុះសម្រុងគ្នាអាចនឹងបង្កលក្ខណៈដែលបង្កើតនូវទំនាស់បង្កប់ទំនាស់ខាងក្រៅនិងទំនាស់ចំហតែម្តង។

**វិសមិតភាព** *ន.* ភាពដែលមិនអាចមានឬមិនអាចធ្វើការចូលគ្នាបាន។ អលទ្ធភាពតាមគន្លងច្បាប់ ដែលមិនអាចឱ្យមនុស្សម្នាក់បំពេញមុខងារពីរកន្លែងបាន។ ការទាស់ចិត្តដែលមិនចុះសម្រុងគ្នា ជាសារវន្តដែលញ៉ាំងវត្ថុពីរមិនស្រុះស្រួលគ្នា :

- ចៅក្រមណាដែលបានស៊ើបអង្កេតសំណុំរឿងព្រហ្មទណ្ឌណាមួយហើយមិនអាចឡើងជំនុំជម្រះចំពោះរឿងព្រហ្មទណ្ឌនោះបានទេ។ ហៅថាចៅក្រមមានវិសមិតភាព។ សាលក្រមណាដែលចៅក្រមមានវិសមិតភាពជាអ្នកវិនិច្ឆ័យសេចក្តីសាលក្រមនោះត្រូវបដិសេធ។

**វិសម្ពាធសេដ្ឋកិច្ច** *ន.* ដំណើរធ្លាក់ចុះនៃសេដ្ឋកិច្ចឬវិបត្តិសេដ្ឋកិច្ច។

**វិសសាស្ត្រ** *ន.* វិទ្យាសាស្ត្រដែលសិក្សាអំពីថ្នាំពុលនិងឥទ្ធិពលរបស់វាទៅលើសរីរាង្គកាយមានជីវិត។

**វិសិដ្ឋការ** *ន.* ការធ្វើឱ្យសម្រេចបរិបូរឡើង, ការបំពេញឱ្យគ្រប់គ្រាន់ឡើង :

❖ សូមលោកធ្វើវិសិដ្ឋការចំពោះរឿងដីនោះឱ្យឆាប់ៗឡើង។

**វិសិដ្ឋភាព** *ន.* ភាវៈនៃការសម្រេចគ្រប់គ្រាន់, ភាវៈពេញបរិបូរ :

❖ រឿងសុំបើកសាលារៀននោះប្រកបដោយវិសិដ្ឋភាពហើយ។

**វិសុណ្ឋាប័ន** *ន.* អ្នកដែលតុលាការឬបុគ្គលដែលគេចាត់តាំងឡើងដើម្បីរក្សានូវទ្រព្យសម្បត្តិដែលកំពុងវិវាទ។

**វិសុណ្ឋាបនកម្ម** *ន.* ការឃុំឃាំងជនណាម្នាក់ឬច្រើននាក់ដោយខុសច្បាប់។ វិសុណ្ឋាបនកម្មជាប្រភេទបទល្មើសមួយហៅថា បទល្មើសឃុំមនុស្សខុសច្បាប់ ឬ បទវិសុណ្ឋាបនកម្ម។

**វិសុណ្ឋាបនិក** *ន.* អ្នកប្រគល់វត្ថុកើតដំណើរដោយឱ្យតតិយជនណាមួយរក្សាទុកជាបណ្ដោះអាសន្ន :

❖ វិសុណ្ឋាបនិកនឹងទុកជាត្រឹមត្រូវបានលុះត្រាតែគូវិវាទទាំងអស់យល់ព្រម។ តុលាការអាចបង្គាប់ឱ្យធ្វើវិសុណ្ឋាបនិកដោយឯកឯងបាន។

**វិសេសានុមាន** *ន.* ការទាញយកសភាពទូទៅចេញពីការសង្កេតឬពិចារណារកហេតុផលលើករណីពិសេសៗមួយចំនួន។

**វិសោធនកម្ម** *ន.* ការផ្លាស់ប្តូរកែប្រែច្បាប់ដែលបានអនុម័តរួចហើយដូចជាសេចក្តីព្រាងច្បាប់ឬរដ្ឋធម្មនុញ្ញ។

**វេទយិត** *គុ.* ដែលទទួលអារម្មណ៍ឆាប់រហ័ស, ដែលដឹងនូវសម្ពស្សភ្លាមៗ :

❖ ខួរក្បាលទទួលវេទនារម្មណ៍ដោយប្រសាទវេទយិត។

**វេទយិតភាព** *ន.* ភាពដែលដឹងនូវសម្ពស្សភ្លាមៗ, ភាពដែលទទួលអារម្មណ៍យ៉ាងឆាប់រហ័សបំផុត :

❖ អណ្តាតមានវេទយិតភាពជាងស្បែក។

**វេវចនានាម** *ន.* នាមដែលអាចប្រើផ្លាស់ប្តូរគ្នាបាន :

❖ សិស្សច្រើនច្រឡំនូវពាក្យជាសទិសនាមនឹងវេវចននាម។

**សកម្មជន** *ន.* អ្នកដែលធ្វើការដើម្បីនាំឱ្យមានការផ្លាស់ប្តូរក្នុងនយោបាយនិងសង្គម ជាពិសេសដោយចូលជាសមាជិកសកម្មក្នុងអង្គការណាមួយ។

**សក្តានុពល** *ន.* កម្លាំងដែលអាចប្រើបាន។

**សក្តិលេខ** *ន.* ឯកតាមូលដ្ឋាន, លេខប្រព័ន្ធសំណេរគំនិតរបស់ជនជាតិអេហ្ស៊ីបជំនាន់ដើម។

**សង្គ្រុបកម្ម** *ន.* អំពើបះបោរ, អំពើជ្រួលជ្រើម, ការចលាចល។

**សង្គមនិយមមនោគត** *ន.* លទ្ធិរួបរួមជាសង្គមប្រកបដោយឧត្តមគតិ, របៀបគ្រប់គ្រងប្រទេសដោយយកប្រយោជន៍រួមជាធំ :

❖ គេថាប្រជាមានិតចិនប្រកាន់នូវសង្គមនិយមមនោគតិ។

**សង្គមនិយមប្រត្យក្ស** *ន.* លទ្ធិប្រកាន់ជាសង្គមយ៉ាងទៀងទាត់ :

❖ ប្រទេសហុងគ្រីហាក់ដូចជាប្រកាន់សង្គមនិយមប្រត្យក្សខ្លាំង។

**សង្គមមាត្រវិធី** *ន.* វិធីស្ទង់បាតុភូតរបស់សង្គម។

**សង្គមិក** *ន.* អ្នកចូលហ៊ុនជាមួយ, អ្នកចូលរួមក្នុងសង្គមអ្វីមួយ :

❖ លោកតាំងជាសង្គមិកក្នុងក្រុមហ៊ុនរបស់ខ្ញុំដែរ។

**សង្គមី** *ន.* ការប្រមូលផ្តុំនៃសំឡេង, សំឡេងតន្ត្រីដែលលេងច្រើនគ្រឿង។

**សង្គមូបនីយកម្ម** *ន.* ការធ្វើឱ្យចូលទៅក្នុងសង្គម, ការធ្វើឱ្យចុះចូលទៅក្នុងសង្គមណាមួយ :

❖ នៅប្រទេសសង្គមនិយមច្រើនធ្វើនយោបាយសង្គមូបនីយកម្មដល់ប្រទេសទូទៅ។

**សង្គហធន១** *ន.* ធនសម្រាប់ជួយឧបត្ថម្ភគ្នាទៅវិញទៅមក។

**សង្គហធន២** *ន* ស្ថាប័នឬអង្គភាពដែលប្រមូលប្រាក់ពីវិនិយោគិនតូចៗទៅឱ្យវិនិយោគនៅក្នុងផ្សារហ៊ុន ហើយទទួលខុសត្រូវចំពោះប្រតិបត្តិការនេះ។ ប្រការនេះ ធ្វើឱ្យវិនិយោគិនតូចៗអាចចូលរួមក្នុងការទិញលក់ហ៊ុននានាបានច្រើនយ៉ាងនិងបានទទួលផលកម្រៃ ព្រោះគេត្រូវបានដឹកនាំដោយអ្នកស្ទាត់ជំនាញផ្នែកនេះ។

**សង្គហបទ** *ន.* សេចក្តីឬឃ្លាដែលស្រង់ពីអត្ថបទរបស់អ្នកនិពន្ធណាមួយ :

❖ សេចក្តីមួយឃ្លានេះគឺជាសង្គហបទរបស់លោក **នោត-ច័ន្ទវិបុល**។

**សន្តហានឥណទាន** *ន.* ការជួយគ្នាទៅវិញទៅមកផ្នែកឥណទាន។

**សង្ឃ្រ័ដ** *ន.* ការឈ្លោះទាស់ទែងគ្នា, ជម្លោះ, វិវាទ :

❖ ប្រជាជនលាវនិងលាវមានសង្ឃ្រ័ដរវាងគ្នានិងគ្នា។

**សន្ទារ័ណ** *ន.* ការប្រមូលទំនិញ, ផលានុផលស្បៀងអាហារក្ដីឱ្យមូលមកនៅតែលើដៃនៃជនម្នាក់ឬជនមួយក្រុមដោយមានចេតនាទុច្ចរិត ថាឱ្យវត្ថុដែលបានប្រមូលនោះដល់ពេលលក់ទៅវិញ មានតម្លៃផ្សេងពីតម្លៃធម្មតា គឺមានតម្លៃថោកឬថ្លៃលើសពីតម្លៃធម្មតារបស់វា។

**សច្ចការតណ្ឋា** *ន.* របស់បញ្ចាំសម្រាប់ដាក់ធានា ដើម្បីអាចខ្ចីប្រាក់បានដូចជាប្លង់ដី ភាគហ៊ុន...។

**សច្ចធារណ៍និរទោស** *ន.* ការចាត់ទុកជនជាប់ចោទពីបទព្រហ្មទណ្ឌណាមួយថាគ្មានទោសអ្វីទាំងអស់បើពុំមានសាលក្រមជាប់ទោសពីតុលាការនោះទេ :

❖ ជនជាប់ចោទត្រូវទទួលសច្ចធារណ៍និរទោសមុនពេលកាត់ក្ដី។

**សជ្ឈន្តិកៈ** *គុ.* ដែលមានគុណភាពនៅក្នុង, ដែលមានគុណវិសេសយ៉ាងប្រពៃ (ច្រើននិយាយចំពោះគ្រឿងមាស ពេជ្រ កែវ កង) :

❖ គ្រឿងផ្ដិលប្រាក់នេះប្រកបដោយគុណភាពសជ្ឈន្តិកៈ។

**សញ្ជ័យ** *ន.* សេចក្ដីសុភាព, ភាពនឹងហ្ន៎, ការមិនសូវនិយាយស្ដី :

❖ គេថាប្អូនស្រីខ្ញុំជាស្រីមានសញ្ជ័យ។

**សញ្ជ្រាកម្ម** *ន.* សកម្មភាពល្មើសច្បាប់របស់បុគ្គលដែលជំរុញគេឱ្យធ្វើពេស្យាចារឬទាញយកកម្រៃពីពេស្យាចារនោះ។

**សញ្ជាតូបនីយកម្ម** *ន.* ការធ្វើឱ្យជនបរទេសបានសញ្ជាតិនៃប្រទេសដែលជននោះរស់នៅ, ការសុំចូលសញ្ជាតិ :

❖ ក្រោយពីបានរស់នៅក្នុងប្រទេសខ្មែរអស់រយៈពេល៧ឆ្នាំមកជនជាតិថៃម្នាក់បានប្តូរសញ្ជាតិរបស់ខ្លួនមកជាសញ្ជាតិខ្មែរ។

**សញ្ញាការ** *ន.* ការឱ្យសញ្ញា, ការធ្វើជាគ្រឿងសម្គាល់ :

❖ នគរបាលបានធ្វើសញ្ញាការឱ្យរថយន្តបត់ទៅស្តាំ។

**សនិសភាព** *ន.* ភាពស្របគ្នា។

**សនិសានុញ្ញាត** *ន.* សេចក្តីយល់ព្រមរបស់អាជ្ញាធររដ្ឋបាលឬអាជ្ញាធរតុលាការចំពោះលិខិតណាមួយដែលត្រូវធ្វើតាមផ្លូវច្បាប់, សច្ចានុម័តិ, ការយល់ព្រម។ ន័យម្យ៉ាងទៀត គឺជានីតិវិធីដែលតុលាការបញ្ចេញឱ្យមានការយល់ព្រមទៅលើលិខិតអ្វីមួយ ដើម្បីឱ្យលិខិតនោះមានកម្លាំងយកទៅអនុវត្តបាន។

**សទ្ទពិម្ព** *ន.* ថាសភ្លេង, ថាសចម្រៀង :

❖ នៅហាងមួយនោះមានលក់សទ្ទពិម្ពរបស់ខ្មែរយ៉ាងពីរោះ។

**សទ្ទពិម្ពាល័យ** *ន.* កន្លែងទុកថាសម៉ាស៊ីនផ្សេងៗ :

❖ នៅក្នុងក្រសួងឃោសនាការមានសទ្ទពិម្ពាល័យមួយកន្លែងដែរ។

**សន្និធានីយភាព** *ន.* ភាពត្រឹមត្រូវតាមវិចារណញ្ញាណឬតាមការគណនា។

**សន្តតកម្ម** *ន.* ការបញ្ជូនតាមផ្លូវច្បាប់នូវទ្រព្យរបស់អ្នកស្លាប់ឱ្យទៅអ្នករស់, មត៌កឬទ្រព្យសម្បត្តិរបស់ខ្មោចដែលត្រូវបានប្រគល់ឱ្យទៅទាយាទ។ ការផ្ទេរបេតិកភណ្ឌនៃបុគ្គលណាម្នាក់ ដែលស្លាប់ឱ្យទៅជនម្នាក់ទៀតឬច្រើននាក់ដែលហៅថា ទាយាទឬសន្តតិជន។ សន្តតិកម្ម ដែលផ្ទេរទៅតាមច្បាប់ហៅថា សន្តតិកម្មឥតបណ្ដាំ។ សន្តតិកម្ម ផ្ទេរតាមឆន្ទៈរបស់ខ្មោចហៅថា សន្តតិកម្មមានបណ្ដាំ។ សន្តតិកម្ម ត្រូវចែកក្រោយថ្ងៃដែលម្ចាស់ទ្រព្យនោះស្លាប់និងនៅទីដែលជាលំនៅក្រោយបង្អស់របស់ខ្មោច។ អ្នកដែលអាចទទួល សន្តតិកម្មបានគឺមនុស្សដែលមានជីវិតរស់នៅមានសមត្ថភាព និងមិនទាន់កាត់កាលថាជា អនព្វជន។

**សន្និកេតន៍** *ន.* កន្លែងរបស់ជនអ្នកស្ងប់ស្ងាត់ :

- ❖ ទីវត្ត គឺជាសន្តនិកេតន៍របស់ព្រះសង្ឃ។

**សន្តិភាវូបនីយកម្ម** *ន.* ការធ្វើឱ្យមានភាពស្ងប់ស្ងៀម, ការបញ្ចប់ភាពជ្រួលច្របល់, ការបញ្ចប់សង្គ្រាម។

**សន្ធិដ្ឋិភាព** *ន.* ភាពព្រមព្រៀងគ្នាដោយរបៀបយ៉ាងណាក៏ដោយរវាងអ្នករាជការផងគ្នាឬរវាងអ្នកតំណាងអាជ្ញាធរសាធារណៈផងគ្នា ក្នុងគោលបំណងប្រកាន់យកវិធានការទាំងឡាយណាដែលផ្ទុយនឹងច្បាប់ឬបទបញ្ជា, ការព្រមព្រៀងគ្នា, ការសន្មតគ្នាដោយប្ដេជ្ញាយ៉ាងស្ងាត់។

**សន្ធានកម្ម** *ន.* ការនាំឱ្យស្រុះស្រួល។ វិធីដោះស្រាយតាមផ្លូវនយោបាយនូវទំនាស់អន្តរជាតិដោយមានអន្តរាគមន៍របស់ប្រទេសទីបី ដែលមិនគ្រាន់តែបញ្ចុះបញ្ចូលគូវិវាទឱ្យស្រុះស្រួលគ្នាប៉ុណ្ណោះទេ គឺថែមទាំងមានលើកឡើងនូវដំណោះស្រាយទៀតផង។

**សន្ធិច្ឆេទកម្ម** *ន.* អំពើកាត់ទី-ត គឺអំពើរបស់ចោរដែលលបកាត់ជញ្ជាំងផ្ទះជាដើមហើយចូលលួចទ្រព្យគេ : ចោរធ្វើសន្ធិច្ឆេទកម្ម។ (ពាក្យច្បាប់) អំពើវះកាត់, ការកាប់គាស់ទម្លុះទម្លាយ ជាអំពើដែលធ្វើឱ្យធ្លាយឬបំណាងដែលធ្វើឱ្យធ្លាយនូវគ្រឿងបិទឬបំផ្លាញឱ្យខូចនូវគ្រឿងបិទនោះ ដើម្បីនឹងឱ្យមនុស្សណាម្នាក់អាចចូលទៅក្នុងកន្លែងដែលគេបិទនោះ ឬដើម្បីយករបស់ដែលគេទុកក្នុងទីបិទបាំងនោះ។ ការប្រើកូនសោក្លែងឬកូនសោដែលលាក់ពីម្ចាស់គេមកឬការប្រើគ្រឿងផ្សេងៗដើម្បីបើកនូវគ្រឿងបិទរបស់គេ ក៏រាប់បញ្ចូលទៅក្នុងសន្ធិច្ឆេទកម្មផងដែរ។

**សន្ធិយោគ** *ន.* សន្លាក់ឆ្អឹង, គន្លាក់ឆ្អឹងដែលជាតំណគ្នា :

❖ នៅកែងដៃមានសន្ធិយោគមួយកន្លែងដែរ។

**សភានុព័ន្ធ** *ន.* កិច្ចការដែលត្រូវទាក់ទងជាមួយនឹងសភា :

❖ គេចាត់ទុកលោក ម៉ូ ឱ្យធ្វើសភានុព័ន្ធក្នុងគណៈរដ្ឋមន្ត្រីថ្មីនេះ។

**សភាពាណិជ្ជកម្ម** *ន.* អង្គការស្ម័គ្រចិត្តដែលបានរៀបចំឡើងដោយក្រុមពាណិជ្ជករ ឧស្សាហករ តាមរយៈអង្គការនេះពួកគេបង្ហាញនូវគោលបំណងរួមដែលពួកគេចង់បានជូនទៅរដ្ឋាភិបាល។

**សភាវនីត** *ន.* ច្បាប់ដែលកើតឡើងឯង :

❖ ច្បាប់ធម្មជាតិជាសភាវនីតិថែមទៀតផង។

**សភាសហភាព** *ន.* ទីប្រជុំរបស់ជាតិរួម, ទីប្រជុំរួមគ្នា :

❖ ក្រុងប៉ារីសមានសភាសហភាពមួយដែលជាសំណង់យ៉ាងល្អ។

**សមតាកម្ម** *ន.* ការធ្វើឱ្យមានសមតា។

**សមតាចិរវន្ត** *ន.* ភាពដែលមានលំនឹងស្ថិតស្ថេរ។

**សមសក្តានុភូត** *គុ.* ដែលមានសក្តានុភាពស្មើគ្នា។

**សមាច័យធុន** *ន.* ការប្រមូលផ្តុំការវិនិយោគសុទ្ធដោយដករំលស់ចេញ។ សញ្ញាណនៃសមាច័យជាទូទៅសម្រាប់គ្រប់គ្រងសេដ្ឋកិច្ច ប៉ុន្តែពាក្យនេះច្រើនប្រើប្រាស់នៅក្នុងទ្រឹស្តីម៉ាក្សស៊ីល។

**សមានកម្ម** *ន.* ដំណើរបំប្លែងសារធាតុពីមជ្ឈដ្ឋានក្រៅឱ្យទៅជាធាតុផ្ទាល់របស់សរីរាង្គកាយ។

**សមានាចារ្យ** *ន.* អ្នកដែលមានគ្រូជាមួយគ្នា, សិស្សរៀនរួមគ្រូជាមួយគ្នា :

❖ លោក **អ៊ុន-សុភា** ជាសមានាចារ្យជាមួយនឹងខ្ញុំ។

**សមាហរណកម្ម** *ន.* ការចូលរួមទៅក្នុងក្រុមឬសង្គមដទៃទៀតដោយសម្របសម្រួលខ្លួនទៅតាមក្រុមឬសង្គមនោះ។ ការបញ្ចូលខ្លួនទៅក្នុងផ្នែកឬស្ថាប័នដែលធំជាង :

❖ ការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាចូលទៅក្នុងចរន្តនៃសេដ្ឋកិច្ចពិភពលោក។

**សមីបតា** *ន.* ភាពជាអ្នកនៅជិតខាងគ្នា, ការនៅជិតខាងគ្នា :

❖ លោកថៃមានសមីបតានឹងខ្ញុំ។

**សមូហនិយម** *ន.* ប្រព័ន្ធសេដ្ឋកិច្ចដែលឈរលើកម្មសិទ្ធិសមូហភាពមធ្យោបាយផលិតកម្ម។

**សមូហភាពមូលដ្ឋាន** *ន.* ប្រភេទសមូហភាពដែនដីដែលអាជ្ញាធរគ្រប់គ្រងត្រូវបានប្រជាជនបោះឆ្នោតជ្រើសរើសសម្រាប់រយៈពេល (អាណត្តិ) មួយជាកំណត់។ សមូហភាពមូលដ្ឋាននេះមានតែក្នុងប្រព័ន្ធរដ្ឋបាលវិមជ្ឈការទេ។

**សមូហភាវូបនីយកម្ម** *ន.* ការធ្វើឱ្យទៅជាសមូហភាព។

**សម្បទានិក** *ន.* អ្នកកាន់កាប់ដាច់មុខ, ជនអ្នកថែរក្សាអ្វីមួយដាច់មុខ :

❖ លោកវ៉ាម៉ែនជាសម្បទានិកលើដីប្រាំពាន់ហិកតានៅស្រែក្រោម។

**សម្បូរណភាព** *ន.* ភាពនៃវត្ថុដែលមានរូបរាងគ្រប់គ្រាន់ឥតមានខ្វះខាត។

**សម្បូរណាញ្ញាសិទ្ធិរាជ** *ន.* អំណាចព្រះមហាក្សត្រដែលសម្រេចកិច្ចការតាមព្រះរាជតម្រិះតែមួយអង្គឯង :

❖ ក្នុងរបបរាជានិយមផ្តាច់ការព្រះមហាក្សត្រទ្រង់ក្រសោបយកអំណាចទាំងបីរបស់រដ្ឋ (អំណាចតុលាការ អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ ដោយមិនបានរំលែកអំណាចដល់អង្គការណាមួយឡើយ)។ ហេតុដូចនេះ ព្រះមហាក្សត្រមានសម្បូណ៌ាជ្ញាសិទ្ធិរាជ។

**សម្ពន្ធជន** *ន.* ភាគីដែលពាក់ព័ន្ធ។

**សម្ពោធភាព** *ន.* ភាពសមហេតុផល។

**សម្មតបុគ្គល** *ន.* បុគ្គលដោយសម្មតិ, មនុស្សដោយសម្មតិ :

❖ ស្ត្រីម្នាក់អារឥតកូនហើយទៅសូមឱ្យមន្ត្រីអត្រានុកូលដ្ឋានចុះក្នុងបញ្ជីជាតិថាខ្លួនមានកូនឈ្មោះនេះឬឈ្មោះនោះ។ កូនដែលមានតែឈ្មោះយ៉ាងនេះហៅថា សម្មតិបុគ្គល។

**សម្មាភាគ** *ន.* ដំណឹងរាយការណ៍, សេចក្តីរាយការណ៍, ភាពដែលមានស្មើគ្នា :

❖ លោកស្នងការតំបន់ព្រះមុនិវង្សបានធ្វើសម្មាភាគពីរច្បាប់ផ្ញើទៅក្រសួងយុត្តិធម៌។

**សល្យកម្ម** *ន.* ការងារខាងវះកាត់, កិច្ចការពេទ្យសម្រាប់វះកាត់ :

❖ គ្រូពេទ្យចេះស្ទាត់នូវសល្យកម្ម។

**សល្យពេទ្យ** *ន.* ពេទ្យវះកាត់, ពេទ្យមើលជំងឺវះកាត់, ពេទ្យខាងសល្យកម្ម, គ្រូពេទ្យជាអ្នកព្យាបាលជំងឺខាងសល្យកម្ម "ការវះកាត់"។

**សវនកម្ម** *ន.* ទម្រង់ការនៃការត្រួតពិនិត្យលើគណនេយ្យនិងការគ្រប់គ្រងរបស់ស្ថាប័នណាមួយ។

**សវនករ** *ន.* អ្នកទទួលបេសកកម្មធ្វើសវនកម្ម។

**សហកម្មសិទ្ធិ** *ន.* កម្មសិទ្ធិរួមគ្នាលើវត្ថុណាមួយកម្មសិទ្ធិតែមួយជារបស់ជនច្រើននាក់ :

❖ ជន៤នាក់រួមគ្នាទិញរថយន្តមួយ។ រថយន្តនោះជាសហកម្មសិទ្ធិរបស់ជនទាំង៤នាក់ដែលទិញនោះ។ អ្នកទាំង៤នោះជាសហកម្មសិទ្ធិករ។

**សហកម្មសិទ្ធិករ** *ន.* ម្ចាស់សហកម្មសិទ្ធិ, អ្នកដែលមានសហកម្មសិទ្ធិ, អ្នកមានសិទ្ធិដូចគ្នាលើវត្ថុតែមួយ :

❖ សហកម្មសិទ្ធិករទាំងអស់នៃរថយន្តនោះត្រូវចូលមកដោះស្រាយនៅថ្ងៃស្អែក។

**សហគត** *គុ.* ដែលប្រព្រឹត្តទៅដោយរួមគ្នា, ដែលមានដំណើរទៅរួមជាមួយគ្នា :

❖ ការប្រព្រឹត្តរបស់វៀតកុងនិងហ្វាហាវជាកិច្ចសហគតរបស់គេ។

**សហចារី** *ន.* បុគ្គលច្រើននាក់ដែលបានព្រមព្រៀងប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់។ បុគ្គលច្រើននាក់ដែលបានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទល្មើសដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក។

**សហទាយាទ** *ន.* អ្នកដែលត្រូវចូលរួមក្នុងការទទួលមត៌កណាមួយ, មនុស្សជាអ្នកទទួលមត៌កជាមួយនឹងជនឯទៀត។

**សហសន្តិជីវភាព** *ន.* ភាពជាអ្នកមានការរួមរស់នៅជាមួយគ្នាជាសុខសាន្ត, ការរួមគ្នារស់នៅដោយសុខសប្បាយ :

❖ ប្រទេសក្នុងលោកខំស្វែងរកនូវសហសន្តិជីវភាពគ្រប់ៗប្រទេស។

**សហសភា** *ន.* ឈ្មោះសភារបស់សហរដ្ឋអាមេរិកដែលរួមមានព្រឹទ្ធសភា និងសភាតំណាងរាស្ត្រ។ គេហៅព្រឹទ្ធសមាជិកឬសមាជិកសភាតំណាងរាស្ត្រនៃសហរដ្ឋអាមេរិកថា សមាជិកសហសភា។

**សហសេវក** *ន.* អ្នកកាន់ឧត្តមគតិដូចគ្នា, អ្នកមានចិត្តគំនិតត្រូវគ្នា :

❖ លោកឫទ្ធិជាសហសេវករបស់ខ្ញុំ។

**សាជីវកម្ម** *ន.* ក្រុមហ៊ុនឬសមាគមអ្នកជំនួញដែលមានរបររកស៊ីដូចគ្នា :

❖ ក្រុមជាងមាសប្រាក់បានបង្កើតសាជីវកម្មមួយដើម្បីធ្វើគ្រឿងមាសប្រាក់ទុកលក់។

**សាជីវកម្មពហុជាតិ** *ន.* សាជីវកម្មដែលមានប្រជាជាតិច្រើនចូលរួមនិងដែលធ្វើប្រតិបត្តិការនៅច្រើនប្រទេស ព្រោះដោយសារមានមូលហេតុជាច្រើនដូចជា ការផ្គត់ផ្គង់វត្ថុធាតុដើម ការប្រើប្រាស់កម្លាំងពលកម្មថោក និងការឆ្លងរបាំងគាំពារនិយមពន្ធគយជាដើម។

**សាធនភាព** *ន.* ភាពដែលមានប្រាក់សងបំណុលគេបាន។

**សាធនភាពឥណទាន** *ន.* ភាពដែលអតិថិជនអាចសងប្រាក់ឥណទានបាន។

**សាធនីយ** *ន.* មធ្យោបាយឬប្រាក់ដើម្បីបង់ឬសងចំពោះម្ចាស់បំណុល។

**សាមីបរិវត្តន៍** *ន.* ការផ្ទេរសិទ្ធិលើកម្មសិទ្ធិ, ការលក់ឬការផ្ទេរសិទ្ធិមួយផ្នែក។

**សាយភត្ត** *ន.* ការបរិភោគអាហារពេលល្ងាច :

❖ គេបានលៀងសាយភត្តមួយដ៏ឱឡារិក។

**សារការី** *ន.* មន្ត្រីមានភារៈខាងតែលិខិតលក់ដូរនិងកិច្ចសន្យាផ្សេងៗឱ្យមានយថាភាពចំពោះមុខតុលាការ :

❖ អ៊ីប៉ូតែកជាកិច្ចសន្យា ដែលធ្វើនៅសារការីបើមិនដូច្នេះទេត្រូវទុកជាមោឃៈដាច់ខាត។

**សារណា១** *ន.* ស្មារតី, អ្វីដែលអាចរលឹកឃើញ :

❖ សូមឱ្យខ្មែរមានសារណាស្នេហាជាតិគ្រប់ៗគ្នាឡើង។

**សារណា២** *ន.* អត្ថបទវិទ្យាសាស្ត្រដែលគេសរសេរអំពីប្រធានបទមួយច្បាស់លាស់ហើយត្រូវតែយកទៅការពារនៅមុខក្រុមប្រឹក្សាបណ្ឌិត ឬគណៈកម្មការវាយតម្លៃដើម្បីទទួលបាននូវកម្រិតសិក្សាវិទ្យាសាស្ត្រមួយ។

**សិក្ខាគារ** *ន.* សាលារៀន, ផ្ទះបង្រៀន :

❖ គេនឹងសង់សិក្ខាគារបន្ថែមទៀតនៅខាងក្នុងវិទ្យាល័យព្រះមុនិវង្សខេត្តបាត់ដំបង។

**សិក្សាភិរក្ស** *ន.* អ្នកត្រួតត្រាការសិក្សានៅក្នុងសាលាមធ្យមសិក្សា :

❖ មានសិក្សាភិរក្សបាវាំងម្នាក់ពុំល្អសោះ។

**សិប្បកោសល្យ** *ន.* ភាពជាអ្នកឈ្លាសវៃក្នុងសិល្បៈ, ការប៉ិនប្រសប់ខាងកិច្ចការជាជាងសិប្បកម្ម :

❖ អ្នកដែលមានសិប្បកោសល្យច្រើនតែប្រកបមុខរបរបានចម្រើន។

**សិសុទិវា** *ន.* ថ្ងៃធ្វើបុណ្យជាថ្ងៃកម្សាន្តដល់ពពួកកុមារកុមារី :

❖ រាល់ខែចេត្រនៃឆ្នាំនីមួយៗ គេតែងធ្វើពិធីបុណ្យសិសុទិវានៅក្នុងបរិវេណនៃវិទ្យាល័យស៊ីសុវត្ថិ។

**សុទ្ធិកម្មធម្មជាតិ** *ន.* ទំនោររួមរបស់មជ្ឈដ្ឋានទឹកក្នុងការសម្អាតសំណល់សរីរាង្គដោយខ្លួនឯងតាមរយៈខនិជកម្ម។

**សុពលភាព** *ន.* គុណភាពនៃអ្វីៗដែលនៅមាំនៅមានតម្លៃជារបស់ត្រឹមត្រូវ, ភាពជាអ្នកមានកម្លាំងពលំល្អអាចធ្វើការរកស៊ីបាន។

**សុទ្ធិកម្មដី** *ន.* ការប្រើប្រាស់នូវបច្ចេកទេសនិងសារធាតុនានាសំដៅកែលម្អលក្ខណៈគីមីនិងលក្ខណៈជីវសាស្ត្ររបស់ដីកសិកម្ម។

**សូចនាករ** *ន.* អ្នកចង្អុលបង្ហាញ, សញ្ញានៃការចង្អុលបង្ហាញ។

**សូរវិទ្យា** *ន.* វិទ្យាសាស្ត្រដែលសិក្សាអំពីសូរសំឡេងរបស់ភាសាក្នុងផ្នែកបញ្ចេញសូរដោយសរីរាង្គសម្រាប់និយាយ និងផ្នែកទទួលសូរដោយសរីរាង្គសម្រាប់ស្តាប់។

**សេដ្ឋកិច្ចមជ្ឈការ** *ន.* សេដ្ឋកិច្ចប្រមូលផ្តុំ, សេដ្ឋកិច្ចគ្រប់គ្រងតាមបែបផែនរបស់រដ្ឋ។

**សេដ្ឋកិច្ចមាត្រដ្ឋាន** *ន.* ការកាត់បន្ថយថ្លៃដើមនៃផលិតផលមួយសម្រាប់រយៈពេលវែងដោយវិធីបង្កើនចំនួនផលិតចេញ។

**សេតជាត** *ន.* ជាតិ-សដែលនៅក្នុងពង, សភាវៈសដែលនៅក្នុងអណ្ឌៈ :

❖ កាលបើគេបំបែកពងមាន់នឹងឃើញសេតជាតិរបស់វា។

**សេរីនិយម** *ន.* លទ្ធិប្រកាន់នូវរបៀបជាសេរី, ការប្រកាន់នូវបែបជាសេរី :

❖ ប្រទេសលោកសេរីប្រកាន់នូវសេរីនិយម។

**សេរីភាវូបនីយកម្ម** *ន.* ដំណើរការធ្វើឱ្យមានសេរីភាពទូលំទូលាយដល់បុគ្គលម្នាក់ៗ ក្នុងការចាត់ចែងកិច្ចការសង្គមដោយកាត់បន្ថយអន្តរាគមន៍របស់រដ្ឋ។

**សេវកិច្ច** *ន.* ភារៈដែលតម្រូវលើអចលនទ្រព្យណាមួយដើម្បីជាអត្ថប្រយោជន៍នៃអចលនវត្ថុមួយផ្សេងទៀតដែលជាកម្មសិទ្ធិរបស់អ្នកណាម្នាក់ :

❖ ស្រែក្រោមមានសេវកិច្ចខាងទទួលទឹកជាស្វ័យប្រវត្តិពីស្រែលើ។

**សេវកិច្ចរដ្ឋបាល** *ន.* កាតព្វកិច្ចទាំងឡាយណាដែលតម្រូវលើអចលនវត្ថុជាកម្មសិទ្ធិឯកជន ដើម្បីជាអត្ថប្រយោជន៍នៃសម្បត្តិសាធារណៈឬដើម្បីគោលដៅនៃប្រយោជន៍ទូទៅ :

❖ រាជការមានសិទ្ធិយកដីកម្មសិទ្ធិឯកជនមកប្រើប្រាស់ជាបណ្ដោះអាសន្នដើម្បីកសាងផ្លូវថ្នល់មួយនៅជាប់ដីនោះ។

**សេវនកិច្ច** *ន.* ការសេពគប់, ការស្និទ្ធស្នាល។ ក្នុងច្បាប់ព្រហ្មទណ្ឌមានន័យថាប្រុសនិងស្រីសេពសន្ថវៈនឹងគ្នាដល់ទីជម្រៅ :

❖ មាត្រា៤៤៩ ក.ព.ទ. ឆ្នាំ១៩៦៩ ចែងថាកាលបើបុរសរួមសេវនកិច្ចនឹងស្ត្រីផិតនោះមានសំអាងថា ខ្លួនមិនបានដឹងថាស្ត្រីមានប្តីខាន់ស្លាទេ បុរសនោះមិនត្រូវទុកជាអ្នកសមគំនិតក្នុងបទផិតក្បត់ទេ។

**សោធនកាលិក** *ន.* ប្រាក់ចំណាយតាមគ្រោងការដែលមានកំណត់ទុកតាមកាលវេលា :

❖ ការចាយកំណត់ឆ្នាំនីមួយៗនៃរតនាគារជាតិហៅថា សោធនកាលិក។

**សោធនពិការភាព** *ន.* ប្រាក់បំណាច់ព្រោះមានពិការ :

❖ ក្នុងពេលបំពេញបេសកកម្មហើយ ស្រាប់តែមានគ្រោះថ្នាក់ធ្លាក់ពិការខ្លួនទើបរាជការឱ្យនូវសោធនពិការភាព។

**សោធនអតីតភាព** *ន.* ប្រាក់បំណាច់ព្រោះខ្លួនបានធ្វើការអស់ពេលដ៏យូរ :

❖ អ្នកធ្វើការយូរក៏ត្រូវបានសោធនអតីតភាពដែរ។

**សោធនិក** *ន.* អ្នកទទួលនូវសោធន, អ្នកទទួលនូវប្រាក់ឈ្នួលផ្ទះនិងអាហារ :

❖ អ្នករាជការភាគច្រើនដែលជាសោធនិក។

**សំយោគបទ** *ន.* ការរួបរួមនៃបទ, បទបាឋដែលត្រូវរួមបញ្ចូលគ្នា :

❖ អ្នកវេយ្យាករណ៍ខំរិះរកពន្យល់សិស្សឱ្យងាយពីសំយោគបទ។

**សំយោគិន** *គុ.* ដែលមានសណ្ឋានជាធាតុផ្សំ, ដែលមានទម្រង់ជាធាតុផ្សំ :

❖ ប្រេងលាបសក់គឺជាវត្ថុសំយោគិន។

**សំយោគី** *គុ.* ដែលអាចរួបរួមបញ្ចូលគ្នាបាន, ដែលអាចលាយផ្សំគ្នាបាន :

❖ ថ្នាំពេទ្យមួយបែបនេះជាថ្នាំសំយោគី។

**សំវិធានការ** *ន.* ការផ្ដល់នូវស្បៀងឬនូវវត្ថុដែលបម្រុងទុក, ការផ្ដល់នូវជំនួយគ្រាន់បន្តកិច្ចការតទៅទៀត :

❖ បរទេសបានធ្វើសំវិធានការដល់ប្រជាជន។

**ស្ថានអធិការបតី** *ន.* កន្លែងធ្វើការអ្នកតំណាងអង្គទូត :

❖ ប្រទេសចិនមានស្ថានអធិការបតីមួយនៅប្រទេសគុយបា។

**ស្ថាបត្យកម្ម** *ន.* វិទ្យាសាស្ត្រនិងសិល្បៈនៃការគូរប្លង់ក្នុងការសាងឬតាក់តែងដែលបង្កប់គំនិតបង្កើតថ្មីស្របតាមមុខងារនិងតួនាទី ដែលមានអត្ថន័យក្នុងវិស័យវប្បធម៌ សេដ្ឋកិច្ច នយោបាយ និងការអប់រំជាដើម។

❖ សូមស្ញើចសរសើរស្ថាបត្យកម្មនៃប្រាសាទនគរវត្ត។

**ស្ថាបត្យករ** *ន.* អ្នកដែលមានអាជីពខាងនិម្មាបនកម្ម។ អ្នកកាន់កាប់មុខការខាងសម្របសម្រួលនិងត្រួតពិនិត្យរាល់ទិដ្ឋភាពនៃសំណង់អគារ។

**ស្ថាបត្យវិទូ** *ន.* អ្នកប្រាជ្ញមានជំនាញឯកទេសខាងនិម្មាបនកម្មឬស្ថាបត្យកម្ម។

**ស្ថាប័នរូបិយវត្ថុ** *ន.* ស្ថាប័នឯកទេសដែលទទួលឬផ្ដល់ការធានាដល់រូបិយវត្ថុ។

**ស្ថាបនូបនីយកម្ម** *ន.* ការរៀបចំឱ្យក្លាយទៅជាស្ថាប័ន។

**ស្ថិរករ** *ន.* វិធានការប្រើប្រាស់នៅក្នុងសេដ្ឋកិច្ចសេរីដើម្បីទប់ការឡើងចុះនៃថ្លៃផលិតកម្មការងារ។

**ស្ថិរវន្ត** *គុ.* ដែលឋិតថេរចេរកាល, ដែលតាំងនៅយ៉ាងមាំមួន :

❖ វត្ថុប្រើប្រាស់ទាំងអស់ក្នុងលោក មិនមែនជាវត្ថុ ស្ថិរវន្ត ឡើយ។

**ស្វ័យប្រវត្តិកម្ម** *ន.* ការប្រើប្រាស់នូវគ្រឿងយន្តទាំងស្រុងឬដោយផ្នែកឱ្យបំពេញមុខងារដោយមិនប្រើកម្លាំងមនុស្ស ឬកាត់បន្ថយកម្លាំងមនុស្សឱ្យមានកម្រិតទាប។

**ស្វ័យភាពហិរញ្ញវត្ថុ** *ន.* ការគ្រប់គ្រងចាត់ចែងកិច្ចការហិរញ្ញវត្ថុនិងទ្រទ្រង់ចំណូលចំណាយផ្នែកហិរញ្ញវត្ថុដោយខ្លួនឯង ដោយមិនពឹងពាក់លើជំនួយពីអ្នកដទៃ។

**ស្វ័យហិរញ្ញប្បទាន** *ន.* ការផ្តល់ឱ្យនូវប្រាក់ដោយទំនើង, ការផ្តល់ឱ្យនូវប្រាក់ដោយមិនបាច់អនុញ្ញាត :

❖ ដោយសារប្រាក់នេះជាប្រាក់សម្រាប់ចាយក្នុងឆ្នាំ២០០៧នេះទើបបានជាគេឱ្យស្វ័យហិរញ្ញប្បទានដល់ក្រសួងមហាផ្ទៃ។

**ហត្ថូបករណ៍** *ន.* គ្រឿងដែសម្រាប់ជាង, គ្រឿងធ្វើការដែលប្រើដោយដៃសម្រាប់ពួកជាង :

❖ កាំបិត, ពូថៅ, ពន្លាក គឺជាហត្ថូបករណ៍របស់ជាង។

**ហានិភ័យ១** *ន.* ភាពប្រថុយប្រថាន, ការខាតបង់ដោយគ្រោះថ្នាក់ដែលនាំឱ្យអន្តរាយខូចខាតខ្ទេចខ្ទី :

❖ ប្រជាជនឡាវជួបនឹងហានិភ័យស្ទើរប្រាំខែហើយ។ ហានិភ័យជាកត្តាមួយសំខាន់ក្នុងការគណនាអត្រាការប្រាក់។

**ហានិភ័យ២** *ន.* ព្រឹត្តិការណ៍ជាយថាហេតុមិនប្រាកដដែលអាចនឹងកើតមានឡើងដោយមិនអាស្រ័យលើឆន្ទៈគូភាគីទេ ហើយដែលអាចបង្កឱ្យមានការអន្តរាយ :

❖ គ្រោះទឹកជំនន់ធំមួយក្នុងប្រទេសដែលនាំឱ្យភាគីមួយនៃកិច្ចសន្យាដឹកជញ្ជូនទំនិញមិនអាចអនុវត្តកិច្ចសន្យាបាន។ ករណីនេះហៅថា ហានិភ័យ។

**ហិតូបត្ថម្ភ** *ន.* ការជួយដល់នីតិជនខ្លះដែលច្បាប់ការពារដោយសារតែជននោះមានការអន់ខ្សោយខាងផ្លូវកាយឬផ្លូវចិត្ត។

**ហិរញ្ញប្បញ្ញត្តិ** *ន.* ច្បាប់ខាងក្រសួងហិរញ្ញវត្ថុ, ច្បាប់ខាងកិច្ចការប្រាក់ :

❖ ការមិនឱ្យបោះក្រដាសប្រាក់ក្លែងក្លាយ គឺជាហិរញ្ញប្បញ្ញត្តិ។

**ហេដ្ឋាភូមិ** *ន.* ថ្នាក់ផ្ទះផ្ទាល់ដី, ជាន់ផ្ទះដែលនូវផ្ទាល់ដី (ជាន់ទី១) :

❖ បណ្ណាគាររបស់ខ្ញុំតាំងនៅហេដ្ឋាភូមិនៃផ្ទះល្វែងផ្សារធំថ្មី។

**ហេដ្ឋារចនាសម្ព័ន្ធ១** *ន.* ដែលជាប្រដាប់ប្រដាគ្រប់បែបសម្រាប់សង់អ្វីមួយដែលមានផ្ទៃរាប។

**ហេដ្ឋារចនាសម្ព័ន្ធ** *ន.* មធ្យោបាយនិងទំនាក់ទំនងផលិតកម្មដែលជាមូលដ្ឋាននៃសង្គមដូចជា ផ្លូវ ស្ពាន ព្រែកជីក ព្រលានយន្តហោះ រោង ចក្រ អគ្គិសនី...។

**ហេតុយុត្តិភាព** *ន.* កាលៈទេសៈខាងសម្ភារៈឬខាងគតិយុត្តដែលធ្វើឱ្យបាត់ការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដូចជាការការពារខ្លួនដោយស្របច្បាប់ស្ថានភាពចាំបាច់...ហើយមានប្រភពចេញពីឆន្ទៈរបស់អង្គការធ្វើច្បាប់។

**ហេមជល** *ន.* ដំណក់ទឹកសន្សើម :

❖ នៅបារិតកាលបើព្រឹកព្រហាមស្រាងៗឡើងគេនឹងឃើញហេមជលស្រក់ជោកដំបូលផ្ទះ។

**អគ្គនាយកដ្ឋាន** *ន.* កន្លែងធ្វើការនៃអគ្គនាយក, ទីចាត់ការនៃអ្នកត្រួតត្រាការទូទៅ :

❖ អគ្គនាយកដ្ឋានមន្ទីររដ្ឋសហគ្រាសតាំងនៅ មហាវិថីព្រះប្រាទនរោត្តម។

**អគ្គលេខាធិការដ្ឋាន** *ន.* កន្លែងធ្វើការរបស់អគ្គលេខាធិការ :

❖ អគ្គលេខាធិការដ្ឋាននៃក្រុមកាកបាទក្រហមកម្ពុជាមានទីតាំងនៅវិថីព្រះអង្គនន់។

**អគ្គសវនករ** *ន* អគ្គនាយកប្រតិបត្តិនៃអាជ្ញាធរសវនកម្មជាតិទទួលខុសត្រូវលើការអនុវត្តគោលនយោបាយ គោលដៅ គោលបំណងអាជ្ញាធរសវនកម្មជាតិ។

អគ្គសវនករមានសិទ្ធិអំណាចក្នុងការបំពេញសវនកម្ម កិច្ចបញ្ជីការគណនេយ្យ ប្រព័ន្ធការត្រួតពិនិត្យកិច្ចប្រតិបត្តិការនិងកម្មវិធីរបស់បណ្ដាស្ថាប័នរដ្ឋាភិបាល។

**អគ្គហោរញ្ញិក** *ន.* អ្នកកាន់ហិបប្រាក់ទូទៅ, អ្នកថែរក្សាហិបប្រាក់ជាន់ខ្ពស់ :

❖ ពូខ្ញុំជាអគ្គហោរញ្ញិកនៃក្រុមកាកបាទក្រហមកម្ពុជា។

**អគ្គិសនីវិភាគ** *ន.* ប្រតិកម្មបំបែកនៃអង្គធាតុដែលកើតមានក្នុងអេឡិកត្រូនិក ក្រោមអំពើនៃចរន្តអគ្គិសនីជាប់។

**អគ្យន្តរាយ** *ន.* សេចក្ដីអន្តរាយកើតមកពីភ្លើង។ ពាក្យសាមញ្ញហៅថា អគ្គិភ័យ។

**អង្គការលេខ** *ន.* រូបគំនូររចនាសម្ព័ន្ធនៃការរៀបចំគ្រប់គ្រងរបស់អង្គការឬស្ថាប័នណាមួយ :

❖ អង្គការលេខសមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរ។

**អង្គការសម្ភារៈ** *ន.* ទម្រង់ការងារដែលទាក់ទងខាងគ្រឿងប្រើប្រាស់ :

❖ នៅក្នុងកងយោធពលយើងមានអង្គការសម្ភារៈសម្រាប់ជួយផ្ដល់សម្ភារៈទៅដល់កងទ័ព។

**អចលកម្ម** *ន.* ធាតុដែលមិនចល័តចេញពីទ្រព្យសកម្មនៃសហគ្រាសណាមួយ :

❖ អគារ ដីធ្លី គ្រឿងម៉ាស៊ីន សម្ភារៈ ប្រកាសនីយបត្រ មូលនិធិពាណិជ្ជកម្ម...។

**អច្ចយទាន** *ន.* កេរដំណែល, សម្បត្តិជាកេរដំណែល, មត៌ក។

**អច្ចយទាយក** *ន.* ម្ចាស់មត៌ក។

**អច្ចយលាភី** *ន.* អ្នកទទួលអច្ចយទាន, អ្នកទទួលមត៌ក។

**អញ្ញមញ្ញសង្គ្រោះ** *ន.* ការសង្គ្រោះគ្នាទៅវិញទៅមក, ការជួយផ្តល់គ្នាទៅវិញទៅមក :

❖ មនុស្សត្រូវតែមានអញ្ញមញ្ញសង្គ្រោះគ្រប់ៗគ្នា។

**អឌ្ឍមាស** *ន.* កន្លះខែ, ពាក់កណ្តាលខែ, រវាង១៥ថ្ងៃ :

❖ នៅអឌ្ឍមាសនៃខែមិថុនានេះនឹងបើកធ្វើនៅសមាជជាតិ។

**អឌ្ឍសិទ្ធិ** *ន.* ការមានសិទ្ធិពាក់កណ្តាលម្នាក់ដែលជារបស់ជនពីរនាក់និងជាព្រំនៃកម្មសិទ្ធិនៃជនទាំងពីរនាក់នោះផង :

❖ ជញ្ជាំងអឌ្ឍសិទ្ធិគឺជញ្ជាំងរបស់ជនពីរនាក់ដែលមានផ្ទះជាប់គ្នា។

**អតិក្រម** *ន.* ការប្រព្រឹត្តល្មើសក្រៃពេក, ការប្រមាថមើលងាយដល់សរណវត្ថុមានរូបសំណាកព្រះពុទ្ធឬវត្ថុទាំងឡាយដែលកប់ក្នុងផ្នូរឬក្នុងទីស្មសាន :

❖ ជនណាធ្វើអតិក្រមឬបំណងធ្វើអតិក្រមក្នុងទីស្មសានជននោះត្រូវមានទោសមជ្ឈិមថ្នាក់ទី៣។

**អតិប្រមាណកម្ម** *ន.* កម្រិតតម្លៃថ្នាក់ខ្ពស់លើផលរបរទូទៅ, កម្រិតតម្លៃហួសប្រមាណ :

❖ ក្រសួងពាណិជ្ជកម្មក្រៅប្រទេសពិនិត្យនូវអតិប្រមាណកម្មលើផលទំនិញទូទៅរបស់ប្រទេស។

**អតិធរណា** *ន.* សភាពការណ៍ឬបាតុភូតនៃការឡើងថ្លៃជាទូទៅរបស់ទំនិញ ឬសេវានានានិងការកើនចំនួនក្រដាសប្រាក់ក្នុងចរាចរណ៍។

**អតិពលកម្ម** *ន.* ការងារដែលប្រើចំនួននិយោជិតឬកម្មករច្រើន :

❖ ក្នុងការស្តារនិងអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជាគេត្រូវការការវិនិយោគ ដែលមានលក្ខណៈអតិពលកម្ម។

**អតិភារភាព** *ន.* ភាពដែលមានអំណាចយ៉ាងខ្ពស់, ភារៈមានអំណាចលើគេ :

❖ ប្រជាពលរដ្ឋខ្មែរថ្វាយអតិភារភាពដល់ព្រះមហាក្សត្ររបស់ខ្លួន។

**អតិសេដ្ឋភាព** *ន.* ភាពដ៏វិសេសវិសាល, ភាពដ៏ប្រសើរបំផុត :

❖ ការអភិវឌ្ឍប្រទេសខ្មែរឈ្មោះថាប្រកបដោយលទ្ធផលអតិសេដ្ឋភាព។

**អត្តាធិបតេយ្យ** *ន.* អំណាចផ្តាច់ការរបស់បុគ្គលតែម្នាក់។

**អត្តាពិគ្រោះ** *ន.* ការរៀនពិនិត្យឬពិចារណាដោយខ្លួនឯង (ខាងចិត្តវិជ្ជា) :

❖ វីរបុរសតែងមានអត្តាពិគ្រោះជាលក្ខណៈមួយដ៏ពិសេស។

**អត្ថភាហក** *ន.* អ្នកទទួលផល។

**អថិរវន្ត** *គុ.* ដែលមិននឹងហ្ន៎, ដែលមិនស្ថិតស្ថេរ, ដែលមិនមាំមួន :

❖ វីឯតំណែងជាប្រតិភូក្រុមមឿងប្រចាំពោធិចិនតុងនៃលោកម្នាក់នោះ ក៏ជា អថិរវន្ត ដែរ។

**អធិការបតី** *ន.* អ្នកធំបំផុតខាងតុលាការក្នុងសម័យរាជាធិបតេយ្យ, ភ្នាក់ងារ ធ្វើការនៅក្នុងស្ថានកុងស៊ុល :

❖ លោកអធិការបតីអាមេរិកម្នាក់ទើបមកដល់ប្រទេសកម្ពុជាថ្មីៗនេះ។

**អធិបត្រ** *ន.* លិខិតឬឯកសារដែលបញ្ជាក់ត្រឹមត្រូវថាទំនិញបានផ្ញើទុកនៅឃ្លាំងសាធារណៈណាមួយ។ លិខិតនេះបានបញ្ជាក់យ៉ាងច្បាស់លាស់នូវមុខទំនិញដែលអាចធ្វើការផ្ទេរកម្មសិទ្ធិបាន គឺតាមរយៈ បិដ្ឋិលេខកម្ម។

**អធិមុត្ត** *ន.* អ្នកធ្វើឱ្យហួសពីការពិត, អ្នកមានអធ្យាស្រ័យហួសហេតុ :

❖ គេហៅគាត់ថាអធិមុត្តដែរ។

**អនន្តានុភាព** *ន.* អានុភាពទូទៅ, អានុភាពពេញលេញ :

❖ ប្រទេសសង្គមនិយមហាក់ដូចជាមានអនន្តានុភាពលើសកលលោក។

**អនីតសំវាស** *ន.* ភាពនៃបុរសនិងស្ត្រីដែលរួមរស់នៅជាមួយគ្នាដូចប្តីប្រពន្ធដោយឥតរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។

**អនីតសំវាសនី** *ន.* នារីដែលរួមរស់នៅជាមួយនឹងបុរសម្នាក់ដូចប្តីប្រពន្ធតែគ្មានសំបុត្រអាពាហ៍ពិពាហ៍ទេ។

**អនីតសំវាសី** *ន.* បុរសដែលរួមរស់នៅជាមួយនឹងនារីម្នាក់ដូចប្តីប្រពន្ធតែគ្មានសំបុត្រអាពាហ៍ពិពាហ៍ទេ។

**អនីត្យានុកូល** *គុ.* ដែលផ្ទុយនឹងច្បាប់។

**អនុទ្ទេស** *ន.* សេចក្តីបង្គាប់, ការសម្តែង, ការពន្យល់, ការឱ្យព័ត៌មានដើម្បីឱ្យធ្វើតាមនៅក្នុងច្បាប់ព្រហ្មទណ្ឌ។ អនុទ្ទេស គឺជាព័ត៌មានដែលអ្នកឱ្យបាន

ដឹងច្បាស់ជាមុន ថាខ្លួនឱ្យព័ត៌មាននេះដើម្បីឱ្យចារីយកទៅប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសនោះ :

❖ ការរួមប្រព្រឹត្តដោយប្រយោលឬសមគំនិតនឹងអាចធ្វើទោសបានលុះត្រាតែអំពើនោះធ្វើឡើងដោយសារជននោះជាអ្នកឱ្យអនុទ្ទេស។

**អនុបស្សុព្យាបាល** *ន.* អ្នកជំនួយក្នុងការថែទាំជំងឺសត្វ។

**អនុប្បទានីយភាព** *ន.* ភាពដែលអាចបញ្ឈប់ឱ្យមានសកម្មភាពតទៅទៀត, ភាពគួរលែងឱ្យមានតទៅទៀត :

❖ រីឯការចរចារវាងសៀមវិញក៏ដល់នូវអនុប្បទានីយភាពដែរ។

**អនុប្រភេទ** *ន.* ផ្នែកនានារបស់ប្រភេទក្នុងមូលដ្ឋានសាំងតាក់ម៉ា :

❖ ក្នុងភាសាបារាំងអនុប្រភេទនៃកំណត់គឺជាអាកទិចដើមអាកទិចក្រោយអាកទិច។ ប្រភេទរងរបស់ប្រភេទពាក្យនៅក្នុងសាំងតាក់ម៉ា។

**អនុព័ន្ធពាណិជ្ជកម្ម** *ន.* មន្ត្រីតំណាងក្រសួងពាណិជ្ជកម្មរបស់ប្រទេសណាមួយនៅបរទេស។ មន្ត្រីនោះមានតួនាទីផ្សព្វផ្សាយគោលនយោបាយពាណិជ្ជកម្ម ទំនាក់ទំនង ដោះស្រាយកិច្ចការនានាពាក់ព័ន្ធនឹងពាណិជ្ជកម្ម ធ្វើរបាយការណ៍ជូនក្រសួងពាណិជ្ជកម្ម។

**អនុវត្តនាការ** *ន.* សេចក្ដីអនុវត្តការប្រព្រឹត្តទៅ, ការប្រតិបត្តិតាម :

❖ ដោយសារគេមិនធ្វើអនុវត្តនាការយ៉ាងនេះហើយទើបបានជាប្រទេសពេញទៅដោយអំពើកខ្វក់។

**អនុសារសាលក្រម** *ន.* សេចក្ដីចម្លងអំពីមូលសាលក្រមដែលតាមធម្មតាគ្មានកត់ត្រាបញ្ជាក់រូបមន្តបង្គប់ឱ្យសម្រេចទេ។

**អន្តរការី** *ន.* អ្នកជ្រៀតចូលកិច្ចការអ្នកដទៃ, មនុស្សឬស្ថាប័នដែលមានសកម្មភាពជាភ្នាក់ងារឬឈ្នួញកណ្ដាលសម្រាប់ភាគីនានា ដើម្បីកិច្ចការជំនួញ។ ជនដែលដឹកនាំមនុស្សឱ្យជួបនឹងអ្នកលក់ឬអ្នកទិញ, ជនអ្នកទទួលប្រាក់ពីអ្នកលេងល្បែងយកទៅចាក់ល្បែងឱ្យ។

**អន្តរក្រសួង** *គុ.* ដែលមានក្រសួងជាច្រើនរួមគ្នាដើម្បីធ្វើការអ្វីមួយ។

**អន្តរជាតូបនីយកម្ម** *ន.* ការធ្វើឱ្យទៅជាអន្តរជាតិ, ការយករបៀបឱ្យទៅជាអន្តរជាតិ :

❖ គេស្លាបនាវាលចំណតអាកាសយានឱ្យទៅជាអន្តរជាតូបនីយកម្ម។

**អន្តរប្បញ្ញត្តិ** *ន.* បទបញ្ញត្តិផ្សេងៗ, ច្បាប់ដែលតែងតាំងឡើងម្ដងម្កាល :

❖ ច្បាប់ស្ដីពីការបង់ពន្ធចំណោញទូទៅជាអន្តរប្បញ្ញត្តិ។

**អន្តរោកាស** *ន.* ឱកាសជាចន្លោះ, ពេលជាចន្លោះ :

❖ សន្និសីទនៅហ្សឺណែវជាអន្តរោកាសមួយសម្រាប់អ្នកនយោបាយ។

**អន្តេវាសិកភាព** *ន.* ភាពដែលរស់នៅក្នុងសាលា, ភាពនៃការនៅក្នុងសេចក្ដីឧបត្ថម្ភរបស់រាជការក្នុងសាលា :

❖ កាលខ្ញុំនៅរៀនវិទ្យាល័យស៊ីសុវត្ថិខ្ញុំពុំបានអន្តេវាសិកភាពទេ។

**អន្តោនិយាល** *ន.* កិច្ចត្រួតត្រាខាងក្នុងប្រទេស, ការគ្រប់គ្រងនាផ្ទៃប្រទេស :

❖ រដ្ឋាភិបាលយើងមានអន្តោភិបាលយ៉ាងប្រសើរបំផុត។

**អបុរិស** *ន.* ទម្រង់ដែលគ្មានបុរសជាក់លាក់ឬមានប្រធានជាបុរិសសទ្ទនាមទី៣នបុំសកលិង្គដូចជា ឧប្បត្តិហេតុមួយកើតឡើង កិរិយាសព្ទគ្មានប្រធានទេ។

**អប្បជនាធិបតេយ្យ** *ន.* របបនយោបាយដែលអំណាចស្ថិតនៅក្នុងដៃរបស់ជនមួយចំនួនតូចជាអាទិរបស់វណ្ណៈមួយ ជាវណ្ណៈអភិជនឬរបស់អ្នកមានធនធានច្រើនជាងគេ (ធនិកាធិបតេយ្យ)។

**អប្បជនាធិបតេយ្យហិរញ្ញវត្ថុ** *ន.* របបដែលមូលធនហិរញ្ញវត្ថុត្រូវប្រមូលផ្តុំក្នុងកណ្តាប់ដៃរបស់ក្រុមមនុស្សមួយចំនួនតូច ត្រួតត្រាលើគ្រប់មែកធាងនៃសេដ្ឋកិច្ចទូទាំងប្រទេស។

**អប្បលោហិត** *ន.* ភាពមានឈាមតិច, រោគខ្វះឈាម :

❖ ម្តាយធំខ្ញុំមានអប្បលោហិត។

**អប្បហារ** *ន.* ទឹកប្រាក់ដែលទទួលបានឬយល់ព្រមនៅពេលមានការទូទាត់មុនឥណប្រតិទានកម្រៃ ដែលបង្វិលឱ្យអ្នកដែលសងមុនពេលកំណត់ការបញ្ចុះតម្លៃ។

**អប្បហារពាណិជ្ជកម្ម** *ន.* ការបញ្ចុះថ្លៃតាមបញ្ជីដែលបានកំណត់ដើម្បីផ្តល់ទៅឱ្យអ្នកបែងចែកបន្តសម្រាប់ការងារដែលពួកគេនឹងអនុវត្ត។

**អប្បហាររដូវ** *ន.* ការបញ្ចុះថ្លៃផ្តល់ឱ្យអ្នកទិញដើម្បីលើកទឹកចិត្តគេឱ្យទិញស្តុកជាមុនជាជាងទិញនៅពេលត្រូវការ។

**អប្រតិសកម្មភាព** *ន.* លក្ខណ៍ការណ៍ដែលតាមនោះបទដ្ឋានគតិយុត្តថ្មីមិនត្រូវយកទៅអនុវត្តលើអំពើទាំងឡាយណា ដែលកើតឡើងមុនបទដ្ឋានចូលជាធរមាន។

**អប្សរា** (អង់គ្លេស APSARA, បារាំង APSARA) *ន.* អក្សរកាត់ Authority for the Protection of the Site And Management of the Region of Angkor ប្រែថាអាជ្ញាធរដើម្បីការពាររមណីយដ្ឋាននិងរៀបចំតំបន់អង្គរ។ អប្សរាជាអាជ្ញាធរដែលបានបង្កើតឡើងដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ។ អាជ្ញាធរនេះមានបេសកកម្មគិតគូរដឹកនាំការងាររៀបចំនិងអភិវឌ្ឍន៍ទេសចរណ៍តំបន់សៀមរាបអង្គរ។ អប្សរា ជាគ្រឹះស្ថានសាធារណៈមួយប្រកបដោយបុគ្គលភាពគតិយុត្តមានស្វ័យភាពរដ្ឋបាលនិងហិរញ្ញវត្ថុ។

**អផាសុកភាព** *ន.* ភាពមិនសុខសប្បាយ, ភាពមិនសប្បាយរីករាយ :

- ❖ ទីកន្លែងទូទៅនៃផ្ទះនោះប្រកបដោយអផាសុកភាព។

**អផុសនីយសម្បត្តិ** *ន.* សម្បត្តិមានលក្ខណៈជាសិទ្ធិមិនមែនជាវត្ថុរូបវន្តទេ :

- ❖ គណនីធនាគារសន្និធិ។

**អព្ភន្តរញ្ញាណពាណិជ្ជកម្ម** *ន.* ការធ្វើពាណិជ្ជកម្មដោយមិនបានធ្វើការស្រាវជ្រាវច្បាស់លាស់។

**អព្ភូតហេតុ** *ន.* អ្វីដែលជាហេតុអស្ចារ្យ, អ្វីដែលមិនកើតធ្លាប់មាន, សភាពដែលផ្ទុយពីធម្មជាតិ :

❖ កាលខែមុនមានកើតអព្ភូតហេតុមួយយ៉ាងអស្ចារ្យនៅក្នុងប្រទេស។

**អព្យាក្ត** *ន.* ភាសាឥណ្ឌូអឺរ៉ុបឯកតាសូរដែលមិនអាចមាននាទីជាធាតុសំខាន់ចាំបាច់របស់ព្យាង្គ។

**អគារវកម្ម** *ន.* អំពើមិនគួរសម, ការប្រមាថមើលងាយដល់សរណវត្ថុឬវត្ថុជាទីសក្ការបូជា មានរូបសំណាកព្រះពុទ្ធ ព្រះសង្ឃជាដើម។

**អភិក្រមពហុមាត្រដ្ឋាន** *ន.* មាត្រដ្ឋានរួមសម្រាប់វាស់ស្ទង់កម្រិតនៃការអភិវឌ្ឍ។ មស្សិរភាពនៃគុណភាពជីវិតមិនអនុញ្ញាតឱ្យយើងវាស់ស្ទង់វាតែតាមរយៈសូចនាករសង្គមសេដ្ឋកិច្ចចំនួនបួនដប់នោះបានឡើយ។ គ្រាន់តែការរៀបចំស្ថិតិស្ដីពីកំណើនផលិតផលក្នុងស្រុកសរុប ឬកំណើននៃចំណូលសម្រាប់ប្រជាជនម្នាក់ដែលមានរូបមន្ត និងមូលដ្ឋានច្បាស់លាស់សម្រាប់អនុវត្តនោះ វាក៏ជាការលំបាកណាស់ទៅហើយសម្រាប់ប្រទេសអន់ថយដែលគ្របដណ្ដប់ដោយសេដ្ឋកិច្ចយថាផល។

**អភិជនាធិបតេយ្យ** *ន.* វណ្ណៈអភិជន, ពួកខុនណាង, ភាពជាជនខ្ពង់ខ្ពស់ថ្លៃថ្នូរ, រដ្ឋាភិបាលឬការគ្រប់គ្រងដែលបង្កើតឡើងដោយវណ្ណៈអភិជន ដែលសម្អាងលើដើមកំណើតទ្រព្យសម្បត្តិឋានៈក្នុងសង្គម។

**អភិជ្ឈាវិសមលោភ** *ន.* សេចក្ដីសម្លក់សម្លឹងរំពៃចង់តែបានរបស់គេ, សេចក្ដីលោភលន់ពន់ប្រមាណ :

❖ មនុស្សណាអភិជ្ឈាវិសមលោភតែងក្លាយទៅជាមនុស្សមានទុក្ខ។

**អភិបាលប្រធាន** *ន.* សមាជិកនៃក្រុមប្រឹក្សាភិបាលដែលទទួលបន្ទុកបំពេញមុខងារជាប្រធានក្រុមប្រឹក្សាភិបាលក្នុងករណី ដែលប្រធានពេញសិទ្ធិមានធុរៈបណ្ដោះអាសន្នឬស្លាប់។

**អភិបាលវលញ្ជ័ន** *ន.* ការត្រួតត្រានូវប្រាក់, ការពិនិត្យកិច្ចការខាងប្រាក់ :

❖ ដោយសារតែការធ្វេសប្រហែសមិនបានធ្វើអភិបាលវលញ្ជ័នទើបអាឡាបាត់អាចលួចប្រាក់ជាតិបាន។

**អយបថ** *ន.* ផ្លូវដែក, ផ្លូវរថភ្លើង :

❖ គេប្រុងនឹងស្ថាបនាអយបថទៅកាន់ទីរួមខេត្តក្រចេះទៀត។

**អរូបសិទ្ធិ** *ន.* សិទ្ធិដែលមិនមែនស្ដីពីវត្ថុមានរូបដូចជាសិទ្ធិបាតិបុគ្គល សិទ្ធិអ្នកនិពន្ធ សិទ្ធិលើតក្កកម្មជាដើម។

**អវបរិតជន** *ន.* ជនដែលមិនរំខានដល់សង្គម។

**អវិភាគកម្ម** *ន.* អំពើមិនអាចបំបែកចេញបាន, អំពើដែលចែកគ្នាមិនបាន។ អវិភាគកម្មនេះបើនិយាយអំពីកំផែងឬជញ្ជាំងហៅថា អឌ្ឍសិទ្ធិភាព :

❖ ការជួសជុលនិងការធ្វើជញ្ជាំងអឌ្ឍសិទ្ធិណាមួយឡើងវិញ គឺជាភារៈនៃអ្នកទាំងឡាយ ដែលមានសិទ្ធិលើរបស់នោះតាមសមាមាត្រនៃសិទ្ធិរបស់នោះតាមសមាមាត្រនៃសិទ្ធិរបស់ខ្លួនម្នាក់ៗ។

**អវសាទនភាព** *ន.* ភាពជាអ្នកមិនក្លៀវក្លា, ភាពជាអ្នកមិនអង់អាច, ភាពមិនរីករាយត្រេកអរ, ភាពមិនសប្បាយ :

❖ ពួកលេខាធិការខ្លះមានអវិសារទភាពចំពោះឧត្តមគតិជាតិខ្លួន។

**អសន្ទិ** *ន.* កៅអីទម្រេត :

❖ នៅក្នុងផ្ទះខ្ញុំមានអសន្ទិពីរសម្រាប់ទម្រេតខ្លួន។

**អសមត្ថជន** *ន.* ជនដែលច្បាប់ឬសេចក្ដីសម្រេចរបស់តុលាការដាក់ឱ្យទទួលរងនូវអសមត្ថភាពខាងការប្រើប្រាស់សិទ្ធិ ឬអសមត្ថភាពខាងការអាស្រ័យផលនៃសិទ្ធិ :

❖ អនីតិជននិងនីតិជនដែលល្ងីល្ងើជាអសមត្ថជន។

**អសមានកម្ម** *ន.* ដំណើរបំបែកអង្គធាតុសរីរាង្គសាំញ៉ាំនៅក្នុងសព៌ាង្គកាយឱ្យទៅជាធាតុងាយៗដោយបញ្ចេញនូវថាមពលព្រមទាំងសំណល់។

**អសាធន** *ន.* សេចក្ដីសម្រេចលើកទោសព្រហ្មទណ្ឌ។ សេចក្ដីសម្រេចរបស់តុលាការដែលកាត់ឱ្យជនជាប់ចោទរួចខ្លួន ព្រោះមានកាលៈទេសៈណាមួយនាំឱ្យផុតពីទោសទោះបីមានពិរុទ្ធលើជននោះក៏ដោយ។

**អសាធនភាព** *ន.* ភាពដែលគ្មានធនធាននឹងបង់ពន្ធដារឬសំណងដល់គេបាន។ ភាពដែលសងបំណុលគេមិនបាន, ភាពដែលគ្មានប្រាក់បង់។

**អសាធនីយ** *គុ.* ដែលគ្មានប្រាក់សម្រាប់សងបំណុល, ដែលមិនអាចសងបំណុលគេបាន, ដែលបំពេញកាតព្វកិច្ចពុំបាន :

❖ ជនអសាធនីយត្រូវមានលិខិតបញ្ជាក់ពីចៅសង្កាត់ដាក់ជូនតុលាការ។

**អសារកម្មសិទ្ធិ** *ន.* កម្មសិទ្ធិដែលឥតឱ្យផលដល់ម្ចាស់កម្មសិទ្ធិដោយហេតុថាម្ចាស់កម្មសិទ្ធិនោះឱ្យសិទ្ធិខ្លួនទៅអ្នកដទៃស៊ីផលនៃកម្មសិទ្ធិនោះទាំងអស់។

**អស្ថិរវន្ត** *គុ.* ដែលមិនឋិតថេរ, ដែលមិនមាំមួន :

❖ នយោបាយជិះជាន់គេជានយោបាយ អស្ថិរវន្ត។

**អហិវាតរោគ** *ន.* រោគចុះក្អួត, អាសន្នរោគ :

❖ សូមកុំឱ្យប្រទេសខ្មែរយើងមានអហិវាតរោគឱ្យសោះ។

**អហេតុកភ័យ** *ន.* ការភ័យឬការភ្ញាក់ផ្អើលដោយឥតហេតុផល, ការភ័យខ្លាចដោយឥតហេតុផល។

**អហេតុកភ័យហិរញ្ញវត្ថុ** *ន.* អហេតុកភ័យហិរញ្ញវត្ថុឬការភ័យផ្អើលខាងហិរញ្ញវត្ថុ គឺជាសភាពការណ៍ដែលកើតមានឡើងនៅពេលដែលអ្នកផ្ញើប្រាក់ជាច្រើននាក់ ទៅដកយកប្រាក់ពីធនាគារមកវិញនៅក្នុងពេលជាមួយគ្នានូវចំនួនទឹកប្រាក់ដ៏ច្រើនរបស់ខ្លួន។

**អាកាសកម្ម** *ន.* ការបញ្ជូនខ្យល់នៅក្នុងមជ្ឈដ្ឋានណាមួយ (ទឹកដី...) ដោយធម្មជាតិដោយការកូរ ដើម្បីបង្កើនផ្ទៃស្រូបខ្យល់ដោយការបាញ់ខ្យល់ទៅក្នុងមជ្ឈដ្ឋាននោះឬដោយការបាញ់វត្ថុរាវសាចទៅក្នុងខ្យល់។

**អាកាសធាតុវិទ្យា** *ន.* វិទ្យាសាស្ត្រដែលសិក្សាអំពីអាកាសធាតុ។

**អាកាសនាវាវិទ្យា** *ន.* វិទ្យាសាស្ត្រស្ដីពីប្រតិបត្តិការនិងការហោះហើររបស់អាកាសយាន។

**អាកាសខេត្រា** *ន.* សាខាឧតុភូតវិទ្យាដែលសិក្សាបរិយាកាសតាមរយៈការសង្កេតពិនិត្យដោយប្រើពោងហោះ អាកាសយាន...។

**អាជ្ញាធរសវនកម្មជាតិ** *ន.* ស្ថាប័នជាតិទទួលខុសត្រូវចំពោះកិច្ចប្រតិបត្តិការមុខងារសវនកម្មឯករាជ្យរបស់រដ្ឋាភិបាល។

**អាជ្ញាបណ្ណ** *ន.* ការអនុញ្ញាតចាំបាច់ឱ្យបុគ្គលឬស្ថាប័នណាមួយដើម្បីធ្វើការអ្វីមួយប្រើបុព្វសិទ្ធិអ្វីមួយឬប្រកបដោយអាជីវកម្មណាមួយមានភាពស្របច្បាប់ :

❖ អាជ្ញាបណ្ណអនុញ្ញាតឱ្យនាំអង្ករចេញ។ ស្មើនឹងពាក្យ អាជ្ញាបត្រ ដែរ។

**អាជ្ញាបត្រ** *ន.* សំបុត្របង្គប់ជាផ្លូវរាជការ។ សំបុត្រអនុញ្ញាតមានកំណត់កាលគឺកំណត់ខែឆ្នាំ ដែលរាជការរដ្ឋាភិបាលចេញឱ្យដល់អ្នកដែលទទួលដេញយកមុខការរបរណាមួយផ្ទាល់ពីរាជការឬសំបុត្រ ដែលរដ្ឋាភិបាលអនុញ្ញាតឱ្យរកស៊ីដោយកំណត់ខែឆ្នាំត្រឹមត្រូវ។

**អាជ្ញាយុកាល១** *ន.* អាជ្ញាយុកាលជាសេចក្ដីបង្គាប់ផ្លូវការដែលផ្ដល់ទៅឱ្យបុគ្គលឬអង្គភាពណាមួយ ដើម្បីមានសិទ្ធិធ្វើការអ្វីមួយបន្ត។ ប្រទេសបារាំងអាជ្ញាយុកាលនៃនីតិពាណិជ្ជកម្ម១០ឆ្នាំ ច្បាប់នេះគឺគ្រាន់តែទាមទារឱ្យអ្នកជំពាក់បំណុលមានគុណភាពជាពាណិជ្ជករ។ ដូច្នេះវាក៏អាចអនុវត្តក្នុងកាតព្វកិច្ចចម្រុះប្រសិនបើជាម្ចាស់បំណុលមិនមែនជាពាណិជ្ជករ។

**អាជ្ញាយុកាល២** *ន.* រយៈពេលដែលមានសិទ្ធិប្ដឹង, រយៈពេលដែលដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិប្ដឹងទាមទារពីកូនបំណុល។

**អាជ្ញាយុកាល៣** *ន.* រយៈពេលដែលដើមបណ្ដឹងព្រហ្មទណ្ឌមានសិទ្ធិប្ដឹងពីជនល្មើសឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។

**អាណត្តិកិច្ច** *ន.* ការធ្វើនូវអាណត្តិ, ការចេញអាណត្តិ :

❖ សាលាក្រុងមិនទាន់ធ្វើអាណត្តិកិច្ចប្រគល់មកឱ្យខ្ញុំទេ។

**អាណត្តិគាហកៈ** *ន.* អ្នកដែលទទួលអាណត្តិដើម្បីធ្វើអ្វីមួយ។ អាណត្តិគាហកៈមិនគោរពប្រតិបត្តិដោយផ្ទាល់នូវកាតព្វកិច្ច ដែលខ្លួនបានចុះក្នុងនាមនិងដើម្បីផលប្រយោជន៍នៃអាណត្តិទាយករបស់ខ្លួនទេ។

**អាណត្តិដីកា** *ន.* លិខិតដែលតាមនោះបុគ្គលម្នាក់ត្រូវបានទទួលភារកិច្ចតំណាងបុគ្គលម្នាក់ទៀតដើម្បីបំពេញលិខិតគតិយុត្តអ្វីមួយ។

**អាណត្តិទាយក** *ន.* អ្នកដែលប្រគល់អាណត្តិទៅឱ្យអ្នកណាមួយដើម្បីធ្វើអ្វីមួយឱ្យខ្លួននិងក្នុងនាមខ្លួន។ អាណត្តិទាយកត្រូវតែប្រតិបត្តិចំពោះតតិយជននូវរាល់ពាក្យសន្យាដែលបានធ្វើក្នុងនាមខ្លួន។ អ្នកផ្ញើអាណត្តិទៅឱ្យអ្នកដទៃ, អ្នកចេញអាណត្តិឱ្យគេ :

❖ បើខ្ញុំផ្ញើអាណត្តិទៅឱ្យប្អូនខ្ញុំគេហៅខ្ញុំថាអាណត្តិទាយក។

**អាណត្តិនយោបាយ** *ន.* បេសកកម្មដែលពលរដ្ឋប្រគល់ឱ្យតំណាងរបស់ខ្លួនប្រើអំណាចក្នុងនាមខ្លួននិងដើម្បីផលប្រយោជន៍ខ្លួន :

❖ ការបោះឆ្នោតរើសតំណាងរាស្ត្រ ជាការប្រគល់អាណត្តិនយោបាយរបស់ប្រជារាស្ត្រដល់តំណាងរាស្ត្រ។

**អាណត្តិបណ្ណ** *ន.* សន្លឹកអាណត្តិ, ក្រដាសសម្រាប់បើក :

❖ មុននឹងផ្ញើប្រាក់ទៅប្អូនខ្ញុំ ខ្ញុំបានបំពេញលក្ខណៈលើអាណត្តិបណ្ណជាដំបូងសិន។

**អាណាប័ក** *ន.* អ្នកបញ្ជាចំណាយ។ អាជ្ញាធរដែលមានសិទ្ធិគ្រប់គ្រាន់តាមផ្លូវច្បាប់ក្នុងការបញ្ជាឱ្យគណនេយ្យករសាធារណៈ ប្រមូលឬបង់មូលនិធិក្នុងនាមអង្គការសាធារណៈ (ទន្ទឹមនឹងនេះជាទូទៅអាណាប័កក៏ជាអាជ្ញាធរដែលមានសិទ្ធិគ្រប់គ្រាន់តាមផ្លូវច្បាប់ក្នុងការចុះសន្យា ចំណាយទាំងឡាយរបស់អង្គការទាំងនោះដែរ)។

**អាណាបណ្ណ** *ន.* លិខិតរដ្ឋបាលដែលអនុលោមទៅតាមលទ្ធផលនៃការជម្រះបញ្ជី បង្គាប់ការដល់គណនេយ្យករសាធារណៈឱ្យសងបំណុលរបស់បុគ្គលសាធារណៈដែលជំពាក់គេ។

**អានុភាព** *ន.* វិសាលភាព, ការពង្រីកទំហំ, ការឈានដល់, ការចូលដល់, ការចាប់យកបាន។

**អាទិចារី** *ន.* អ្នកនាំអាទិប្រព្រឹត្ត, អ្នកមេគេ។

**អាទិភាព** *ន.* ភាពដែលមានប្រៀបជាងគេ, អាការៈដែលអាចធ្វើអ្វីៗបានរហ័សមុនអ្នកដទៃ :

❖ អ្នកធំតែងតែមានអាទិភាពជាងអ្នកតូច។

**អាទេសកម្មបុគ្គល** *ន.* ការយកបុគ្គលម្នាក់មកជំនួសបុគ្គលម្នាក់ទៀត។

**អាយតនភាព១** *ន.* ភាពតានតឹងក្នុងអារម្មណ៍ មនោសញ្ចេតនា ឬពេលរំពឹងចាំអ្វីមួយ។

**អាយតនភាព២** *ន.* ស្ថានការណ៍ឬទំនាក់ទំនងដែលមានភាពតឹងតែង គឺនៅពេលណាដែលទំនាស់បង្កើតនូវអារម្មណ៍នៃការមិនទុកចិត្ត និងការប្រឈមមុខដាក់គ្នាដែលអាចរីករាលដាល។

**អាយតនភាព** *ន.* ភាពដែលតឹងតែង, ការគិតជញ្ជឹងខ្លាំង :

❖ អ្នកជំងឺនេះមានអាយតនភាពលើសកម្រិត។

**អារក្ខទេវី** *ន.* ទេវតាស្រីជាអ្នកថែរក្សាទឹកដី។

**អាវសថាគារ** *ន.* មន្ទីរទទួលថែរក្សាក្មេងកំព្រា, មនុស្សចាស់ជរានិងមនុស្សពិការ :

❖ នៅចម្ការមនមានអាវសថាគារមួយកន្លែង។

**អាវុធគ្រាស** *ន.* ការកាន់កាប់អាវុធគំនាប់, ការដង្ហែក្បួនដោយកាន់អាវុធ :

❖ គេនឹងធ្វើពិធីអាវុធគ្រាសនៅមុខព្រះបរមរាជវាំងនៅខែមុខនេះ។

**អាវុធហត្ថដ្ឋាន** *ន.* មន្ទីរចាត់ការឬកន្លែងធ្វើការរបស់ពួកអាវុធហត្ថ :

❖ អាវុធហត្ថដ្ឋាននៅក្រុងភ្នំពេញតាំងនៅខាងក្រោយផ្សារធំថ្មី។

**អាវុធិក** *ន.* អ្នកលក់ឬអ្នកធ្វើគ្រឿងអាវុធ។

**អាស៊ាន** *ន.* (អង់គ្លេស ASEAN) សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍។ សមាគមប្រទេសស្ថិតនៅទ្វីបអាស៊ីអាគ្នេយ៍បង្កើតឡើងឆ្នាំ១៩៦៧ ដើម្បីធានាសន្តិភាព

ស្ថិរភាព នយោបាយ និងសេដ្ឋកិច្ច។ សមាជិកអាស៊ានបច្ចុប្បន្នមាន១០ ប្រទេស : កម្ពុជា ថៃ ម៉ាឡេស៊ី សិង្ហបុរី ឥណ្ឌូណេស៊ី ព្រុយណេ ភីលីពីន វៀតណាម ភូមា ឡាវ។

**អាហរណកម្ម** *ន.* ការនាំចូលនៃទំនិញនិងសម្ភារៈមានតម្លៃផ្សេងៗទៀតពីបរទេសដើម្បីលក់នៅទីផ្សារក្នុងប្រទេសអាហារិន។ អាហរណកម្មរបស់ប្រទេសមួយ ឆ្លើយឆ្លងទៅនឹងនីហរណកម្មផលិតផលទាំងនោះដោយប្រទេសមួយទៀត។ គេនាំចូលទំនិញទាំងឡាយដែលមានប្រភពបរទេសដោយមានដើមកំណើតមកអំពីប្រទេសផលិតឬប្រទេសអន្តរការី។ វាត្រូវបានទុកសម្រាប់ប្រើប្រាស់ឯកជន ឧស្សាហកម្ម កសិកម្ម...។ ចំពោះការធ្វើបំប្លែងដើម្បីអាចនឹងប្រើប្រាស់បាននៅក្នុងប្រភេទអាហារិនឬសម្រាប់នាំចេញទៅប្រទេសទី៣។

**អាហារណីយ** *គុ.* ដែលទាក់ទងដោយអាហារ។

**អាហារសោធន** *ន.* អាហារឬប្រាក់ដែលជនម្នាក់ត្រូវឱ្យទៅជនម្នាក់ទៀតដើម្បីចិញ្ចឹមជីវិត (អាហារកិច្ច)។ បុរាណហៅថា សោធនអាហារណីយ។

**ឥណទាយី** *ន.* អ្នកដែលមានប្រាក់ឱ្យគេខ្ចី។

**ឥណទេយ្យ** *ន.* សិទ្ធិដែលបុគ្គលណាម្នាក់ (ម្ចាស់បំណុល) អាចទាមទារអ្វីមួយពីអ្នកណាម្នាក់ទៀត (កូនបំណុល)។

**ឥណប្រតិទាន** *ន.* ថ្ងៃខែដែលគេត្រូវបង់ប្រាក់, កាលបរិច្ឆេទដែលកូនបំណុលត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន ពោលគឺសងបំណុល :

❖ នៅថ្ងៃដាច់ឆ្នាំនេះត្រូវអ្នកជំនួញខាងអង្ករចូលទៅបង់ឥណប្រតិទានជូនរាជការកុំខាន។

**ឧភាសទាន** *ន.* ការបញ្ជារបស់អាជ្ញាធរតុលាការក្នុងស្រុកឱ្យអនុវត្តសាលក្រមរបស់តុលាការបរទេស :

❖ លិខិតដែលទទួលស្គាល់ឋានៈជាផ្លូវការរបស់កុងស៊ុលបរទេស ហើយអនុញ្ញាតឱ្យកុងស៊ុលនេះបំពេញមុខងាររបស់ខ្លួន

❖ ការបញ្ជារបស់អាជ្ញាតុលាការឱ្យអនុវត្តសេចក្ដីសម្រេចរបស់អង្គការយុត្តិធម៌ឯកជន សេចក្ដីសម្រេចរបស់អាជ្ញាកណ្ដាល។

**ឧក្រិដ្ឋនិច្ឆ័យ** *ន.* មុខវិជ្ជាវិទ្យាសាស្ត្រដែលរួមចំណែកក្នុងការជួយឱ្យអាជ្ញាធរខាងនគរបាលតុលាការ កំណត់នូវកាលៈទេសៈពិតប្រាកដនៃការប្រព្រឹត្តបទល្មើសនិងស្រាវជ្រាវរកឱ្យឃើញជនល្មើសដូចជា នីតិវេជ្ជសាស្ត្របច្ចេកទេសខាងស្នាមម្រាមដៃ។

**ឧច្ចិដ្ឋៈ** *ន.* ភាគ, សំណល់, របស់ដែលសល់ :

❖ សូមកុំបោះឧច្ចិដ្ឋៈផ្សេងៗនៅលើផ្លូវសាធារណៈនៃទីក្រុង។

**ឧត្តមដ្ឋាន** *ន.* ថ្នាក់ខ្ពស់បំផុតខាងបឋមសិក្សាបំពេញវិជ្ជា :

❖ ប្អូនស្រីខ្ញុំរៀននៅថ្នាក់ឧត្តមដ្ឋាន។

**ឧត្តមនាវីទោ** *ន.* នាយទាហានជើងទឹកដែលមានឋានន្តរសក្តិទាបជាងឧត្តមនាវីឯក។

**ឧត្តមនាវីឯក** *ន.* នាយទាហានជើងទឹកដែលមានឋានន្តរសក្តិខ្ពស់ជាងឧត្តមនាវីទោ។

**ឧត្តរាធិការ** *ន.* ការបន្តមត៌ករបស់អ្នកស្លាប់ទៅឱ្យអ្នកដែលមានសិទ្ធិទទួល។

☞ *មើល.* សន្តតិកម្ម។

**ឧត្ថានកម្ម** *ន.* ការផ្សាយនូវចំណេះវិជ្ជា, ការផ្សាយនូវរបស់ថ្មី :

❖ អ្នកប្រាជ្ញជាតិរុស្ស៊ីខំប្រឹងធ្វើឧត្ថានកម្មដើម្បីបង្កើលពិភពលោក។

**ឧត្ថានការិនី** *ន.* ស្ត្រីអ្នកផ្សាយនូវចំណេះវិជ្ជា, ស្ត្រីអ្នកផ្សាយនូវវត្ថុថ្មី :

❖ ស្ត្រីអ្នកវិទ្យាសាស្ត្រ គឺជាឧត្ថានការិនី។

**ឧត្ថានការី** *ន.* បុរសអ្នកផ្សាយនូវចំណេះវិជ្ជា, បុរសអ្នកផ្សាយនូវវត្ថុថ្មី :

❖ អ្នកវិទ្យាសាស្ត្រ គឺជាឧត្ថានការី។

**ឧទ្ទាមកម្ម** *ន.* អំពើហិង្សាប្រព្រឹត្តទៅលើអ្នករាជការឬក៏តំណាងអាជ្ញាធរសាធារណៈ, រឹងទទឹងនឹងអាជ្ញាធរ។ ឧទ្ទាមកម្ម ជាប្រភេទបទល្មើសមួយដែលប្រឆាំងទៅនឹងអាជ្ញាធរដោយប្រើហិង្សា។

**ឧទ្ទេសជន** *ន.* អ្នកចាត់តាំង, អ្នកតែងតាំង។

**ឧទ្ទេសិតជន** *ន.* អ្នកទទួលការតែងតាំង, បេក្ខជនចាត់តាំងឬជ្រើសតាំង។

**ឧបឃាត** *ន.* ការប្រព្រឹត្តអំពើហិង្សាមួយឬច្រើនក្នុងគោលបំណងបង្កឱ្យមានគ្រោះថ្នាក់ដល់ស្ថាប័នព្រះរាជាណាចក្រកម្ពុជា ឬនាំឱ្យមានការប៉ះពាល់ដល់បូរណភាពនៃដែនដីជាតិ។

**ឧបត្ថម្ភកធន** *ន.* ជំនួយហិរញ្ញវត្ថុដែលរដ្ឋឬស្ថាប័នសាធារណៈជួយចំពោះបុគ្គលឬស្ថាប័នឯកជន ដើម្បីលើកស្ទួយឬទ្រទ្រង់សកម្មភាពឱ្យមានដំណើរការទៅមុខបានល្អ។

**ឧបត្ថម្ភកធននីហរណៈ** *ន.* ការជួយបំពេញខាតចំពោះការនាំចេញឬការជួយកាត់បន្ថយពន្ធផ្សេងៗសម្រាប់នាំចេញ ដើម្បីជំរុញការនាំចេញទំនិញទៅបរទេសឱ្យបានកាន់តែច្រើនឡើង។

**ឧបទោសកម្ម** *ន.* អំពើមិនត្រឹមត្រូវរបស់បុគ្គលម្នាក់ ប៉ុន្តែប្រព្រឹត្តឡើងដោយគ្មានចេតនាធ្វើឱ្យមានការខូចខាត តែអំពើនោះបណ្ដាលឱ្យមានការអន្តរាយដល់អ្នកដទៃ ហើយតម្រូវឱ្យម្ចាស់អំពើនោះទទួលខុសត្រូវគឺត្រូវតែជួយជួសជុលសោហ៊ុយខូចខាតដល់ជនរងគ្រោះ។

**ឧបនាយករដ្ឋមន្ត្រី** *ន.* រដ្ឋមន្ត្រីជានាយកបន្ទាប់, រដ្ឋមន្ត្រីបន្ទាប់នាយករដ្ឋមន្ត្រី :

- ❖ គណៈរដ្ឋមន្ត្រីនេះពុំមានឧបនាយករដ្ឋមន្ត្រីទេ។

**ឧបនិធាន** *ន.* កិច្ចសន្យាបញ្ចាំអសង្ហារិមភណ្ឌ។ កិច្ចសន្យាដែលកូនបំណុលបានប្រគល់អសង្ហារិមភណ្ឌឱ្យទៅម្ចាស់បំណុលកាន់កាប់ ដើម្បីយកផលពីអសង្ហារិមនោះសម្រាប់បង់ការប្រាក់ និងរំលស់ប្រាក់ដើមរហូតដល់គ្រប់ចំនួនឯម្ចាស់នូវរក្សាសិទ្ធិ។

**ឧបបទ** *ន.* ពាក្យឬកន្សោមពាក្យ ដែលគេដាក់បន្ទាប់ពីនាមបញ្ជាក់ន័យរបស់នាមនោះក៏ប៉ុន្តែដោយប្រើរបៀបផ្សេង ហើយក្នុងភាសានិយាយអ្នកនិយាយតែងតែបង្អង់សម្ដីបន្តិច :

❖ សុខក្ដួយប្រុសខ្ញុំជាក្មេងឧស្សាហ៍។ ក្នុងប្រយោគនេះ « ក្ដួយប្រុសខ្ញុំ » ជាឧបបទ។

**ឧបរិរចនាសម្ព័ន្ធ** *ន.* ផ្នែកខាងលើនៃសំណង់, គ្រឿងប៉ែកខាងលើនៃផ្ទះ, គ្រឿងប៉ែកខាងលើនៃអគារ :

❖ អគារនេះទ្រេតហើយត្រូវតែវាយចេញឧបរិរចនាសម្ព័ន្ធ។

**ឧបសន្យា** *ន.* កិច្ចសន្យាដែលតុលាការតម្រូវឱ្យភាគីមួយធ្វើក្នុងករណីពិសេសដើម្បីចៀសវាងកុំឱ្យភាគីម្ខាងទទួលប្រយោជន៍ ហើយភាគីម្ខាងទៀតខាតប្រយោជន៍ដោយគិតសមហេតុផល។

❖ ករណីដែលតុលាការតម្រូវឱ្យជនរងគ្រោះសន្លប់បាត់ស្មារតីពេលភ្លើងឆេះផ្ទះ បង់ថ្លៃឈ្នួលព្យាបាលខ្លួន។ អំពើនេះហៅថាឧបសន្យា។

**ឧបសម្ព័ន្ធ** *ន.* អ្វីដែលនៅជាប់អាស្រ័យនឹងគេ, ការតភ្ជាប់នឹងគេ :

❖ នៅក្នុងមណ្ឌលគរុកោសល្យមានសាលាឧបសម្ព័ន្ធសម្រាប់កុមារនិងកុមារីសិក្សា។

**ឧបសម្ព័ន្ធកម្មការ** *ន.* ការភ្ជាប់ដែនដីថ្មីមួយទៅនឹងរដ្ឋមួយ។ អំពើបែបនេះច្រើនកើតឡើងបន្ទាប់ពីសង្គ្រាម   អ្នកចាញ់ត្រូវគេបង្ខំឱ្យចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាពដែលកាត់ផ្តាច់ពីដែនដីរបស់ខ្លួន។

**ឧបសាធន** *ន.* គ្រឿងបន្ទាប់បន្សំ, របស់បន្ទាប់បន្សំ :

❖ គ្រឿងឧបសាធនសម្រាប់រថយន្តក្រុងសម្បូរជាងរថយន្តដទៃ។

**ឧបាគមន៍** *ន.* សិទ្ធិទទួលកម្មសិទ្ធិលើវត្ថុផ្សេងៗដែលក្លាយទៅជាចំណែកមួយនៃវត្ថុដើមដែលជាកម្មសិទ្ធិមានពីមុនមកហើយ។

**ឧបាទេសកម្ម** *ន.* ការផ្ទេរអំណាចខ្លួនជាម្ចាស់បំណុលឱ្យទៅជនម្នាក់ទៀតកាន់កាប់ឬប្រើអំណាចនោះជួសខ្លួន, ការចេញមុខជំនួសដើម្បីបំពេញកិច្ចការផ្សេងៗដើម្បីកាន់កាប់បន្តនូវសិទ្ធិឬចាត់ចែងការជំនួសជនណាម្នាក់។

**ឧបាទេសកម្មបាតបុគ្គល** *ន.* ការតែងតាំងឬដាក់បញ្ចូលបុគ្គលម្នាក់ដើម្បីជំនួសបុគ្គលម្នាក់ទៀត។

**ឧបាទេសកម្មវត្ថុនិក** *ន.* ការដាក់វត្ថុមួយជំនួសវត្ថុមួយទៀត។

**ឧបាស្រ័យ** *ន.* បណ្តឹងដែលធ្វើឡើងក្នុងករណីវិវាទរដ្ឋបាល។ ជាធម្មតាឧបាស្រ័យមានពីរបែប គឺឧបាស្រ័យរដ្ឋបាលនិងឧបាស្រ័យយុត្តាធិការ។

**ឧម្មត្តករោគ** *ន.* រោគឆ្កួត។

**ឧយ្យោគ** *ន.* ការដេញតាម, ការតាមឃ្លាំមើល :

❖ តុលាការបានសុំធ្វើឧយ្យោគចំពោះរាជការម្នាក់។

**ឧស្សាហកម្មហត្ថពលនិយោគ** *ន.* ឧស្សាហកម្មដែលប្រើប្រាស់កម្លាំងកម្មករច្រើនដូចជា រោងចក្រកាត់ដេរសម្លៀកបំពាក់ជាដើម។

**ឯកជនូបនីយកម្ម** *ន.* ការលក់ទ្រព្យសម្បត្តិរបស់រដ្ឋដែលភាគច្រើនជារោងចក្រ សហគ្រាស អង្គភាពរបស់រដ្ឋទៅឱ្យឯកជនកាន់កាប់។

**ឯកតោភាគី** *គុ.* ដែលធ្វើឡើងឬដែលមានផលប៉ះពាល់ទៅលើក្រុមតែម្ខាងក្នុងចំណោមក្រុមដទៃទៀតដែលមានការពាក់ព័ន្ធគ្នា។

**ឯកត្តកម្ម** *ន.* ការធ្វើឱ្យទៅជាម្នាក់ឯង, ការធ្វើឱ្យទៅជាតែមួយ :

- ❖ នយោបាយខ្លះរបស់ប្រទេសលោកសេរីជាឯកត្តកម្ម។

**ឯកត្តភាព** *ន.* ភាពតែឯង, ភាពតែម្នាក់ឯងគត់ :

- ❖ អាណត្តិបើកប្រាក់របស់អ្នករាជការខ្លះធ្វើទៅជាឯកត្តភាព។

**ឯកត្តនិយម** *ន.* របៀបនិយមតែខ្លួនឯង, លទ្ធិប្រកាន់នូវរបៀបតែម្នាក់ឯង :

- ❖ គេថាអ្នកនយោបាយជាតិខ្លះប្រកាន់នូវឯកត្តនិយម។

**ឯកត្តភូត** *ន.* បុគ្គលម្នាក់ៗ, រូបជននីមួយៗ :

- ❖ អ្នកខ្លះចូលចិត្តតែនៅជាឯកត្តភូត។

**ឯកត្តលក្ខណៈ** *ន.* លក្ខណៈរបស់ជនម្នាក់ៗ, លក្ខណៈនៃបុគ្គលនីមួយៗ :

- ❖ គេពិពណ៌នាអំពើឯកត្តលក្ខណៈនៃរដ្ឋបុរសរបស់ប្រទេសទូទៅ។

**ឯកទេសកម្ម** *ន.* ការធ្វើឱ្យវិសេសឡើង, ការធ្វើឱ្យប្លែកឡើង :

- ❖ ឧស្សាហករខំរិះរកធ្វើឯកទេសកម្មនូវវត្ថុប្រើប្រាស់ទូទៅ។

**ឯកធារ** *ន.* ផ្លូវតែមួយ :

❖ ក្នុងចំណោទនេះមានរបៀបជាឯកធារ។

**ឯកទប្បកម្ម** *ន.* ការលក់ទ្រព្យសម្បត្តិរដ្ឋ ភាគច្រើនជារោងចក្រ សហគ្រាស អង្គភាពរបស់រដ្ឋទៅឱ្យឯកជនកាន់កាប់។

**ឯកសារដ្ឋាន** *ន.* កន្លែងទុកឯកសារក្បួនខ្នាតបណ្ណសារដ្ឋាន។

**ឯកាធិកម្ម** *ន.* សកម្មភាពនៃការរកស៊ីផ្ដាច់មុខតែឯង។

**ឯកាធិភាព** *ន.* សិទ្ធិធ្វើឬលក់របស់អ្វីមួយផ្ដាច់មុខតែម្នាក់ឯងអ្នកផងនឹងធ្វើឬក៏លក់ដែរមិនបាន, សិទ្ធិផ្ដាច់មុខ។

**ឱនាភិវឌ្ឍន៍** *ន.* សភាពខ្វះខាតមិនរីកចម្រើន, ភាពមិនគ្រប់គ្រាន់សម្រាប់សេចក្ដីត្រូវការ។

**ឱភាសភាព** *ន.* ភាពដែលមានជាទូទៅឬដែលមានភាគច្រើន។

**ឱសារណកម្ម** *ន.* ការចូលមកជាថ្មី, ការបញ្ចូលឱ្យចូលធ្វើការជាថ្មី :

❖ អ្នករាជការម្នាក់ទើបនឹងសុំឱសារណកម្ម ដើម្បីចូលធ្វើការជាថ្មី។

# គន្ថនិទ្ទេស

១- **ជួន-ណាត** វចនានុក្រមខ្មែរ បោះពុម្ពគ្រាទី៥ ព.ស. ២៥១១-២៥១២
គ.ស. ១៩៦៧-១៩៦៨, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
២- ព្រឹត្តិបត្រលេខ១ ២០០៨ការផ្សាយរបស់គណៈកម្មាធិការជាតិភាសាខ្មែរ
៣- ព្រឹត្តិបត្រលេខ២ ២០០៩ការផ្សាយរបស់គណៈកម្មាធិការជាតិភាសាខ្មែរ
៤- ព្រឹត្តិបត្រលេខ៣ ២០១០ការផ្សាយរបស់គណៈកម្មាធិការជាតិភាសាខ្មែរ
៥- ព្រឹត្តិបត្រលេខ៤ ២០១២ការផ្សាយរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ
៦- ព្រឹត្តិបត្រលេខ៥ ២០១៣ការផ្សាយរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ
៧- សទ្ទានុក្រមភាសាវិទ្យានិងអក្សរសិល្ប៍ខ្មែរ-អង់គ្លេស-បារាំង២០១៣ ការផ្សាយរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ
៨- ឈ្មោះប្រទេសនិងរាជធានីរដ្ឋធានី២០១៣ ការផ្សាយរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ
៩- **ច័ន្ទ សំណាង** (១៩៩៩) វិជ្ជមានន័យ អវិជ្ជមានន័យ និងបរិធាតុរបស់វា
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
១០- **ច័ន្ទ សំណាង** (២០០២) គោលការណ៍នៃការបង្កើតពាក្យនិងកម្ចីពាក្យ
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
១១- **ច័ន្ទ សំណាង** (២០០៣) ធាតុវេយ្យាករប្រើសម្រាប់បង្កើតពាក្យក្នុង
ភាសាខ្មែរ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

១២- **ច័ន្ទ សំណាញ**(២០០៦) ការកំណត់ប្រភេទពាក្យក្នុងភាសាខ្មែរ : តួនាទីនៃបុរេបទ **ភាវ** និងផ្នត់ដែក [-**អម/ណា**-] / [-**អិម/ន**-] សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

១៣- ព្រះគ្រូមុនីសោភ័ណ **សេខ-នាគ** សារញ្ញាណោ,បាលីវេយ្យាករណ៍, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព. ស. ២៥៤៤ គ. ស. ២០០០

១៤- ព្រះគ្រូសិរីសោភ័ណ **ភិម-ត្វ**, បទានុក្រមធម្មបទភាគទី១, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព. ស. ២៥៣៨ គ. ស. ១៩៩៤

១៥- ព្រះគ្រូសិរីសោភ័ណ **ភិម-ត្វ**, បទានុក្រមធម្មបទភាគទី២, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព. ស. ២៥៣៨ គ. ស. ១៩៩៤

១៦- ព្រះគ្រូសិរីសោភ័ណ **ភិម-ត្វ**, បទានុក្រមធម្មបទភាគទី៣, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព. ស. ២៥៣៨ គ. ស. ១៩៩៤

១៧- **អៀវ-កើស** ភាសាខ្មែរ

១៨- វចនានុក្រមខ្មែរ KHMER DICTIONARY, ការផ្សាយបណ្ណាគារអង្គរធំ ព. ស. ២៥៥៥ គ. ស. ២០១១

១៩- ធាតុសង្គ្រោះ

២០- សទ្ទានុក្រមពាក្យច្បាប់និងរដ្ឋបាល (អង់គ្លេស-បារាំង-ខ្មែរ)

២១- វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ, ការផ្សាយរបស់វិទ្យាស្ថានភាសាជាតិ

២២- **ហ៊ីង-ធីឫទ្ធិ** អត្ថាធិប្បាយវចនានុក្រមច្បាប់